សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរំលាយកិច្ចសន្យាលក់ទិញ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះៈ **ពិន ពិទូរខ្សី**
**អ៊ុំខ មហា**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ពិន ពិទូរខេវ៉ី** និងនាងខ្ញុំឈ្មោះ **អ៊ុខ មហា** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក និងអ្នកម្តាយ ជាទីគោរពស្រលាញ់ ដឹងគុណរបស់កូន ដែលលោកទាំងពីរមានគុណធំធេងជាទីបំផុត ដែលពុំអាចមានអ្វីមកប្រៀបផ្ទឹមបានឡើយ។ ចាប់តាំងពីកូនបានចាប់កំណើតក្នុងផ្ទៃរបស់អ្នកម្តាយ រហូតបានប្រសូតមក លោកឪពុកអ្នកម្តាយ តែងតែយកចិត្តទុកដាក់ ទំនុកបំរុង ចិញ្ចឹមបីបាច់ ស្រលាញ់ថ្នាក់ថ្នម ប្រៀនប្រដៅ ថែរក្សាកូនស្មើនឹងគ្រាប់ភ្នែក ព្រមទាំងចាត់ទុកដូចជាដួងព្រលឹងរបស់លោកទាំងពីរ និងដើម្បីឱ្យកូនក្លាយជាពលរដ្ឋដល់ល្អក្នុងសង្គម។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ជូន **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដោយលោកបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងយ៉ាងម៉ត់ចត់ ធ្វើយ៉ាងណាឱ្យសាកលវិទ្យាល័យមួយនេះ មានការរីកចម្រើន និងអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។ ហើយសូមគោរពអរគុណដល់ លោកគ្រូ អ្នកគ្រូ ដែលជាសាស្រ្តាចារ្យ ដែលបានយកចិត្តទុកដាក់ ក្នុងការបង្ហាត់បង្រៀន ចែករំលែកចំណេះដឹងបទពិសោធន៍ និងដំបូន្មានល្អៗ ចាប់តាំងពីឆ្នាំមូលដ្ឋាននៃការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តរហូតដល់បានបញ្ចប់នៃការសិក្សាឆ្នាំទី៤នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ អ្នកគ្រូ **ម៉ូលី ចញ្ញា** ដែលជាសាស្រ្តាចារ្យទទួលបន្ទុកដឹកនាំសារណារបស់យើងខ្ញុំ លោកបានខិតខំបង្ហាត់បង្ហាញអស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃ ដើម្បីផ្តល់ជាគំនិតផ្តួចផ្តើមដ៏ច្រើនក្នុងការជំរុញ ណែនាំដល់ក្រុងយើងខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងសារណានេះឡើងរហូតដល់បានបញ្ចប់ជាស្ថាពរ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណយ៉ាងក្រៃលែង និងសូមបួងសួងដល់បារមីស័ក្តិសិទ្ធិទាំងពួងលើលោកនេះ ជួយតាមថែរក្សាអស់លោកអ្នកមានគុណទាំងអស់ ឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា កុំបីឃ្លៀងឃ្លាតឡើយ ជាពិសេសជៀសឆ្ងាយផុតពីជម្ងឺទាំងពួង។

# អារម្ភកថា

ក្នុងរយៈពេល ៤ ឆ្នាំ នៃការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពួកយើងខ្ញុំបានទទួលចំណេះដឹងជាច្រើនពីសំណាក់លោក និងលោកស្រីសាស្ត្រាចារ្យ ជាពិសេសអំឡុងពេលនៃការសិក្សា ពួកយើងខ្ញុំទទួលបានទាំងភាពសប្បាយរីករាយ និងកើតទុក្ខលាយឡំបញ្ចូលគ្នា។ នៅក្នុងការសិក្សាផ្នែកនីតិសាស្ត្រ គេបានបែងចែកនីតិជាពីរប្រភេទ គឺនីតិឯកជន និងនីតិសាធារណៈ ដែលនីតិទាំងពីរប្រភេទនេះ សុទ្ធតែមានសារៈប្រយោជន៍សម្រាប់ទទួលយកជាចំណេះដឹង។ ក្នុងចំណោមមុខវិជ្ជាទាំងអស់ដែលកម្មវិធីសាលាបានដាក់ឱ្យពួកយើងធ្វើការសិក្សា គឺពួកយើងខ្ញុំពេញចិត្តទៅលើផ្នែកនីតិឯកជនជាខ្លាំង។

ជាក់ស្តែង នៅក្នុងដំណើររស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ កិច្ចសន្យាបានដើរតួនាទីយ៉ាងសំខាន់គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ជាពិសេសកិច្ចសន្យាលក់ទិញ ដែលជាប្រភេទកិច្ចសន្យាមួយដែលត្រូវបានចាត់ទុកថា ជាប្រភេទកិច្ចសន្យាដែលមិនអាចខ្វះបាននៅក្នុងសង្គម ដោយហេតុថាវាជាតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងសង្គម។ ត្បិតតែកិច្ចសន្យាលក់ទិញត្រូវបានប្រើប្រាស់ជាប្រចាំមែន ប៉ុន្តែលក្ខណៈច្បាប់នៃកិច្ចសន្យាលក់ទិញមិនទាន់បានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណៈជនដើម្បីអនុវត្តឡើយ។ ជាងនេះទៅទៀត ដោយហេតុមានកង្វះផ្នែកចំណេះដឹងអំពីកិច្ចសន្យាលក់ទិញបែបនេះ បានធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានបាត់បង់ផលប្រយោជន៍របស់ខ្លួន ក្នុងករណីដែលមានភាគីម្ខាងនៃកិច្ចសន្យាលក់ទិញមិនព្រមអនុវត្តករណីយកិច្ចរបស់ខ្លួន។ ដោយហេតុមើលឃើញថា នីតិឯកជនបានដើរតួនាទីយ៉ាងសំខាន់ក្នុងទំនាក់ទំនងរវាងបុគ្គលឯកជន ពួកយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានបទនៃផ្នែកនីតិឯកជន គឺ ការរំលាយកិច្ចសន្យាលក់ទិញ ដើម្បីធ្វើការបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំ។

ក្នុងនាមយើងខ្ញុំជាអ្នករៀបចំសារណានេះ សង្ឃឹមថាឯកសារនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទានព្រមទាំងផ្តល់ចំណេះដឹងបន្ថែម សម្រាប់ជាគន្លឹះក្នុងការយល់ដឹងអំពីការរំលាយកិច្ចសន្យាលក់ទិញដល់ប្អូនៗនិស្សិតជំនាន់ក្រោយៗទៀតឱ្យបានសិក្សាស្រាវជ្រាវបន្ត។

ជាចុងក្រោយ យើងខ្ញុំសូមខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គង ដែលកើតមានឡើងដោយអចេតនា ពីព្រោះថានៅក្នុងការសិក្សាស្រាវជ្រាវតែងតែមាននូវចំណុចខ្វះខាតមួយចំនួនជាក់ជាមិនខាន គ្រាន់តែខ្លះមានកំហុសតិច ឬច្រើនប៉ុណ្ណោះ ទាំងអក្ខរាវិរុទ្ធក្តី ទាំងពាក្យពេចន៍ក្តី និងទាំងអត្ថន័យក្តី។ ដូច្នេះហើយ យើងខ្ញុំរង់ចាំទទួលជានិច្ចនូវរាល់មតិរិះគន់ដើម្បីស្ថាបនាដោយសេចក្តីរីករាយពីសំណាក់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តៗអ្នកអានទាំងអស់ដែលនឹងកំពុងអាននូវសារណារបស់យើងខ្ញុំ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**

**១.លំនាំបញ្ហា** ........ ១

**២.ចំណោទបញ្ហា** ........ ១

**៣.ចំណោទបញ្ហា** ........ ២

**៤.គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ៣

**៦.សារៈសំខាន់នៃការស្រាវជ្រាវ** ........ ៣

**៧.វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ៤

**៨.រចនាសម្ព័ន្ធ** ........ ៤

**ជំពូកទី ១ សញ្ញាណទូទៅនៃការរំលាយកិច្ចសន្យាលក់ទិញ**

**១.អត្ថិភាពនៃការរំលាយកិច្ចសន្យាលក់ទិញ**

១.១.ខ្លឹមសារនៃការរំលាយកិច្ចសន្យាលក់ទិញ ........ ៥

១.២.លក្ខខណ្ឌនៃការរំលាយកិច្ចសន្យាលក់ទិញ ........ ៥

១.២.១.អត្ថិភាពនៃកិច្ចសន្យាលក់ទិញ ........ ៦

១.២.២.កិច្ចសន្យាអញ្ញមញ្ញ ........ ៩

១.២.៣.តាវកាលិកដល់កាលកំណត់ត្រូវអនុវត្ត ........ ១០

១.២.៤.ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ........ ១០

១.២.៥.ការបង្ហាញឆន្ទៈរំលាយ ........ ១១

**២.មូលហេតុនៃការរំលាយកិច្ចសន្យាលក់ទិញ**

២.១.ការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិមូលដ្ឋាន ........ ១២

២.១.១.ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវទោះបីជាមានការដាស់តឿន ........ ១២

២.១.២.ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវចំពោះសកម្មភាពកំណត់អំឡុងពេលចាំបាច់ ........ ១៤

២.១.៣.អលទ្ធភាពក្នុងការអនុវត្ត ........ ១៥

២.១.៤.ការបាត់បង់ទំនុកចិត្តរវាងគ្នា ........ ១៦

២.១.៥.ការបំពានកិច្ចសន្យាធ្ងន់ធ្ងរផ្សេងទៀត ........ ១៦

២.២.ការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញតិពិសេស ........ ១៧

២.២.១.កម្មវត្ថុនៃកិច្ចសន្យាលក់ទិញជារបស់អ្នកដទៃ ......១៧
២.២.២.ករណីដែលសិទ្ធិមួយភាគនៅក្នុងកិច្ចសន្យាលក់ទិញជារបស់អ្នកដទៃ ......១៩
២.២.៣.ករណីកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមានវិការៈ......២០
២.២.៤.ករណីសិទ្ធិរបស់អ្នកលក់ក្នុងការជួសជុល......២៤
២.២.៥.ករណីអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល......២៥
២.២.៦.ការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិរំលោះ......២៦
២.២.៧.ករណីពិសេសអនុវត្តចំពោះកម្មវត្ថុនៃកិច្ចសន្យាជាអចលនវត្ថុ......២៨
២.៣.ការរំលាយកិច្ចសន្យាលក់ទិញដោយការព្រមព្រៀងរបស់ភាគី ...... ៣២

## ជំពូកទី ២ ៖ នីតិវិធីនៃការរំលាយកិច្ចសន្យាលក់ទិញ

### ១.នីតិវិធីនៃការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាលក់ទិញ

១.១.ការរំលាយកិច្ចសន្យាលក់ទិញតាមផ្លូវតុលាការ ...... ៣៥
១.២.ការរំលាយកិច្ចសន្យាលក់ទិញក្រៅប្រព័ន្ធតុលាការ...... ៤០

### ២.ការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញ

២.១.មូលហេតុដែលនាំឱ្យរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញ...... ៤២
២.១.១.ការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញដោយសារសកម្មភាពរបស់ភាគី...... ៤២
២.១.២.ការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញដោយអាជ្ញាយុកាល...... ៤៣
២.២.អានុភាពនៃការរលត់សិទ្ធិរំលាយ...... ៤៤

## ជំពូកទី៣៖ អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញ

### ១.ទ្រឹស្តីអានុភាពនៃការរំលាយកិច្ចសន្យា

១.១.គោលការណ៍ប្រតិសកម្ម...... ៤៧
១.២ .គោលការណ៍មិនប្រតិសកម្ម...... ៤៨

### ២.អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញចំពោះភាគី

២.១.ការរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា...... ៤៩
២.២.ករណីយកិច្ចក្នុងការធ្វើបដិទាន...... ៥០
២.២.១.ការអនុវត្តព្រមគ្នានូវករណីយកិច្ចធ្វើបដិទាន...... ៥០
២.២.២.ទំហំនៃករណីយកិច្ចធ្វើបដិទាន...... ៥១
២.២.៣.ករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាតបង់...... ៥២

**៣.អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញចំពោះតតិយជន**
២.១.គោលការណ៍ប្រតិសកម្មនៃការរំលាយកិច្ចសន្យា ..... ៥៤
២.២.គោលការណ៍មិនប្រតិសកម្មនៃការរំលាយកិច្ចសន្យា ..... ៥៦
**សេចក្ដីសន្និដ្ឋាន** ..... ៥៨
**អនុសាសន៍** ..... ៦០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

សង្គម ជាបណ្តុំនៃប្រភពមនុស្សដ៏សំបូរបែប ដែលមានលក្ខណៈខុសគ្នា ស្រដៀងគ្នា ឬដូចគ្នាជាច្រើនដែលកំពុងរស់នៅលាយឡំជាមួយគ្នា។ ដោយការយល់ឃើញ និងការចាត់ទុកសង្គមជាបណ្តុំនៃមនុស្សបែបនេះ ដើម្បីទទួលបាន និងគ្រប់គ្រងសង្គមមួយឱ្យប្រកបដោយចីរភាព និរន្តរភាព និងភាតរភាព អ្នកនីតិនិពន្ធបានតាក់តែងបញ្ញត្តិស្តីពីកិច្ចសន្យាដើម្បីបម្រើជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នាក្នុងសង្គម។ ជាក់ស្តែងក្នុងសង្គមសព្វថ្ងៃ កិច្ចសន្យាបានដើរតួនាទីយ៉ាងសំខាន់ ដូចទៅនឹងអ្វីដែលអ្នកនីតិនិពន្ធរំពឹងទុកយ៉ាងច្បាស់មែន មនុស្សគ្រប់គ្នាបានទាញយកផលប្រយោជន៍ពីកិច្ចសន្យាក្នុងលក្ខខណ្ឌ និងគោលបំណងខុសៗគ្នា។ អ្នករកស៊ីប្រើប្រាស់កិច្ចសន្យាលក់ទិញ ដើម្បីជួយសម្រួលនិងធានាការបំពេញករណីយកិច្ចរវាងអ្នកលក់ និងអ្នកទិញ រីឯអ្នកធ្វើការ បានប្រើប្រាស់កិច្ចសន្យាការងារដើម្បីបង្កើត ឬធានាសិទ្ធិ នងករណីយកិច្ចដែលមានសម្រាប់និយោជិត និងនិយោជក។ ដើម្បីរៀបចំកិច្ចសន្យាមួយឱ្យមានសុពលភាពនិងអានុភាពទៅបាន លុះត្រាតែភាគីនៃកិច្ចសន្យាបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវ។ ក្រោយពីបានបង្កើតលក្ខខណ្ឌសុពលភាពនិងអានុភាពនៃកិច្ចសន្យា ភាគីចាំបាច់ត្រូវអនុវត្តកិច្ចសន្យាដែលខ្លួនបានបង្ហាញឆន្ទៈដើម្បីបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ចនោះ។[1] ការអនុវត្តកិច្ចសន្យារបស់ភាគី ត្រូវឈរលើគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់ជាសំខាន់ ដើម្បីធានាមិនឱ្យមានការរំលោភបំពានផលប្រយោជន៍របស់ភាគីណាម្ខាងឡើយ។ ក្រមរដ្ឋប្បវេណី បានបញ្ជាក់យ៉ាងច្បាស់អំពីលទ្ធភាពនៃការអនុវត្តកិច្ចសន្យាដោយភាគី កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា ព្រមទាំងគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់។[2] បើកាតព្វកិច្ចត្រូវបានអនុវត្តតាមការកំណត់របស់ភាគីក្នុងកិច្ចសន្យា ត្រូវចាត់ទុកថាជាការសង ដែលនាំឱ្យកាតព្វកិច្ចត្រូវបានរលត់។

## ២.ចំណោទបញ្ហា

ប្រសិនបើកាតព្វកិច្ចដែលបានកំណត់ក្នុងកិច្ចសន្យានោះ ពិតជាបានអនុវត្តដោយភាគីតាមច្បាប់ ករណីនេះនាំឱ្យកាតព្វកិច្ចត្រូវបានរលត់ ដែលមិនតម្រូវ ឬបង្ខំឱ្យភាគីណាម្ខាងចាំបាច់ត្រូវអនុវត្តកាតព្វកិច្ចនោះទេ។ ប៉ុន្តែបញ្ហាចោទត្រង់ថា ភាគីមិនអនុវត្តកាតព្វកិច្ចដែលខ្លួនបានបង្ហាញឆន្ទៈព្រមព្រៀង ដើម្បីការបង្កើតក្នុងកិច្ចសន្យានោះ។ ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា។[3] ឧទាហរណ៍៖ ក្នុងកិច្ចសន្យាលក់ទិញរវាងលោក ក (អ្នកទិញ) និងកញ្ញា ខ (អ្នកលក់) ចំពោះម៉ូតូមួយ

[1] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី។

[2] មាត្រា ៣៨៤ នៃក្រមរដ្ឋប្បវេណី។

[3] មាត្រា ៣៨៩ នៃក្រមរដ្ឋប្បវេណី។

គ្រឿង ក្នុងតម្លៃ ២៥០០ ដុល្លារអាមេរិក។ លោក ក បានប្រគល់លុយគ្រប់ចំនួនហើយទៅកាន់កញ្ញា ខ ប៉ុន្តែនាងបានប្រគល់ម៉ូតូផ្សេងទៅឱ្យលោក ក ទៅវិញ។

ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចមានដូចជា ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ ឬអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ឬការមិនអនុវត្តកាតព្វកិច្ចឱ្យបានពេញលេញតាមខ្លឹមសារនៃកិច្ចសន្យា និងករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។ អាស្រ័យលើឧទាហរណ៍ខាងលើ ករណីនេះអាចចាត់ទុកថាកញ្ញា ខ មិនបានអនុវត្តកាតព្វកិច្ចក្រោមរូបភាពនៃការអនុវត្តកាតព្វកិច្ចមិនពេញលេញ ដែលសំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ចតែការផ្តល់តាវលិកមិនពេញលេញតាមខ្លឹមសារនៃកិច្ចសន្យា។[4] ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ម្ចាស់បំណុលនឹងទទួលរងការខូចខាតជាច្រើនក្រោមរូបភាពនៃការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលនោះ។

តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី បានការពារម្ចាស់បំណុលនៃកិច្ចសន្យាលក់ទិញពីការខូចខាតក្រោមរូបភាពនៃការបំពានកាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរពីសំណាក់កូនបំណុលនៃកិច្ចសន្យាលក់ទិញ ដោយការអនុវត្តវិធានសង្គ្រោះកិច្ចសន្យាលក់ទិញ ដែលមានការអនុវត្តដោយបង្ខំ ការរំលាយកិច្ចសន្យាលក់ទិញ និងការទាមទារសំណងនៃការខូចខាត ប៉ុន្តែអត្ថបទនេះ នឹងបកស្រាយអំពីការរំលាយកិច្ចសន្យាលក់ទិញតែប៉ុណ្ណោះ។

## ៣.ចំណោទបញ្ហា

អាស្រ័យទៅលើចំណួលបញ្ហាដែលបានបង្ហាញមុននេះ តើម្ចាស់បំណុល អាចរំលាយកិច្ចសន្យាលក់ទិញនោះបានឬទេ? តើមូលហេតុអ្វីដែលអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិរំលាយកិច្ចសន្យាលក់ទិញ? តើនីតិវិធីនៃការរំលាយកិច្ចសន្យាលក់ទិញត្រូវធ្វើឡើងដោយវិធីណា? តើកិច្ចសន្យាលក់ទិញដែលត្រូវបានរំលាយមានអានុភាពយ៉ាងណាដែរ?

## ៤.គោលបំណងនៃការស្រាវជ្រាវ

យើងខ្ញុំទាំងពីរនាក់ បានជ្រើសរើសប្រធានបទ ស្តីពី ការរំលាយកិច្ចសន្យាលក់ទិញ និងបានរៀបចំចងក្រងអត្ថបទសារណានេះឡើង ក្នុងគោលបំណងដើម្បីឱ្យអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តច្បាប់ ក៏ដូចជាសាធារណជនទូទៅ ដែលមានគំនិតចង់ឈ្វេងយល់អំពីច្បាប់ទាំងអស់បានស្គាល់នូវប្រព័ន្ធនៃការរំលាយកិច្ចសន្យាដែលបញ្ញត្តិដោយក្រមរដ្ឋប្បវេណីជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសកិច្ចសន្យាលក់ទិញ ដែលក្នុងនោះរួមមានមូលហេតុជាមូលដ្ឋាននៃការរំលាយកិច្ចសន្យាលក់ទិញ មូលហេតុពិសេសនៃការរំលាយកិច្ចសន្យាលក់ទិញ និងការព្រមព្រៀងរំលាយកិច្ចសន្យាលក់ទិញ។ ប្រសើរជាងនេះទៅទៀត អត្ថបទសារណានេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីពង្រីក និងពង្រឹងសមត្ថភាពរបស់ពួកខ្ញុំដែលជាអ្នកតាក់តែងនិងរៀបចំ ឱ្យកាន់តែស្គាល់

[4] មាត្រា ៣៩៤ នៃក្រមរដ្ឋប្បវេណី។

ច្បាស់អំពីការរំលាយកិច្ចសន្យាលក់ទិញ ដែលវានឹងមានគុណប្រយោជន៍សម្រាប់ពួកខ្ញុំក្នុងឱកាសប្រកបវិជ្ជាជីវៈនាពេលអនាគត។

## ៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ត្បិតតែការរំលាយកិច្ចសន្យាលក់ទិញមានលក្ខខណ្ឌទូលំទូលាយ ដោយមានការកំណត់ដោយឡែកទាំងនៅក្នុងច្បាប់ជាមូលដ្ឋាន និងបញ្ញត្តិពិសេស ហើយមានការចងក្រងតាក់តែងដោយអ្នកច្បាប់ដទៃជាច្រើនទៀតមែន ប៉ុន្តែក្នុងការឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តិដែលបានលើកឡើងខាងលើ ពួកខ្ញុំបានខិតខំរៀបចំអត្ថបទស្រាវជ្រាវនេះដោយផ្អែកជាចម្បងលើឯកសារជាមូលដ្ឋានដែលមានជាច្បាប់សារធាតុ គឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

នៅក្នុងអត្ថបទសារណាបញ្ចប់ការសិក្សានេះ ពួកខ្ញុំនឹងផ្តោតសំខាន់អំពីដំណើរនៃការរំលាយកិច្ចសន្យាលក់ទិញតែប៉ុណ្ណោះ ដោយមិនបានសិក្សាទៅលើប្រភេទនៃការរំលាយកិច្ចសន្យាពិសេសផ្សេងៗទៀតនៅក្នុងគន្ថីទី៥ នៃក្រមរដ្ឋប្បវេណីឡើយ។ ក្រៅពីនេះពួកខ្ញុំ ក៏បានដកស្រង់អត្ថបទខ្លីៗដែលមានខ្លឹមសារល្អ ដែលរៀបចំឡើងដោយសាស្ត្រាចារ្យជាច្រើន ដែលកំពុងបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងករណីសិក្សាជាក់ស្តែងអំពីការរំលាយកិច្ចសន្យាលក់ទិញ ដែលបានផ្ទាល់មកពីអ្នកអនុវត្តច្បាប់ដើម្បីជាទឡ្ហីករណ៍ដ៏ល្អសម្រាប់គាំទ្រអត្ថបទសារណារបស់ពួកខ្ញុំ ដែលនឹងដាក់ភ្ជាប់ក្នុងឧបសម្ព័ន្ធខាងក្រោយនៃអត្ថបទសារណានេះ។

ដូចបានបញ្ជាក់ខាងលើ អត្ថបទសារណានេះ នឹងមិនគ្របដណ្តប់ ឬបានឆ្លើយតប និងស្រាយគ្រប់ចម្ងល់របស់អ្នកអាននោះទេ ហេតុដូច្នេះយើងខ្ញុំសង្ឃឹមថាអ្នកអាននឹងចូលរួមដោយក្តីអនុគ្រោះ និងសូមបន្តការសិក្សាស្រាវជ្រាវ ហើយវិភាគដើម្បីស្រាយចម្ងល់ដោយខ្លួនឯង។ បន្ថែមពីនេះ យើងខ្ញុំសូមលើកទឹកចិត្តអ្នកអានដទៃទៀត ក្នុងការចងក្រងសរសេរជាអត្ថបទទាក់ទងនឹងច្បាប់ផ្សេងៗទៀត ដើម្បីចូលរួមជួយពង្រឹង ពង្រីក និងអភិវឌ្ឍវិស័យយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៦.សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសមិទ្ធផលនៃការស្រាវជ្រាវមួយនេះ ពួកខ្ញុំបានសង្ឃឹមយ៉ាងមុតមាំថានឹងអាចជួយដល់បងប្អូន ក៏ដូចជាសិស្សានុសិស្ស និងអ្នកអានទាំងអស់ផ្សេងទៀតសម្រាប់ទុកជាទុន ឬជាអាហារជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវរបស់ខ្លួន ដើម្បីពង្រីកពង្រឹងសមត្ថភាពខាងសកម្មភាព និងចំណេះដឹងអំពីដំណើរនៃការរំលាយកិច្ចសន្យាលក់ទិញឱ្យកាន់តែមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធិភាពប្រសើរឡើង ជាពិសេសស្របតាមស្មារតីនៃបទបញ្ញត្តិច្បាប់ជាធរមាន។

## ៧.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរអត្ថបទសារណាមួយនេះ រូបខ្ញុំទាំងពីរនាក់បានធ្វើការរៀបចំនិងតាក់តែង ក្រោមការសិក្សាស្រាវជ្រាវ អានអត្ថបទ មេរៀន សិក្ខាសាលា និងអត្ថបទសារណារបស់រាមច្បងជំនាន់មុន ជាងនេះទៅទៀត អត្ថបទសារណានេះ ផ្តេកផ្តួលខ្លាំងទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី និងសេចក្តីកំណត់មាត្រាក្រមរដ្ឋប្បវេណីដែលរៀបចំតាក់តែងដោយ JICA តែម្តង។ ម៉្យាងវិញទៀត អត្ថបទសារណានេះ ក៏បានរួមបញ្ចូលកិច្ចសន្យាលក់ទិញដែលជាទឡ្ហីករណ៍ សម្រាប់ការបញ្ជាក់អំពីដំណើរការនៃការរំលាយកិច្ចសន្យាលក់ទិញ ក្នុងការអនុវត្តផងដែរ។

ប៉ុន្តែអត្ថបទសារណានេះ មិនបានធ្វើឡើងដោយឈរលើគោលការណ៍អនុវត្តផ្ទាល់ ឬរបាយការណ៍ដែលសិក្សាដោយផ្ទាល់ជាមួយភាគី ឬស្ថាប័នអនុវត្តនោះទេ។

## ៨.រចនាសម្ព័ន្ធ

**ជំពូកទី ១ មូលហេតុនៃការរំលាយកិច្ចសន្យាលក់ទិញ** ដែលនឹងពិភាក្សាអំពីលក្ខខណ្ឌដែលជាមូលហេតុនៃការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិជាមូលដ្ឋាន ការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិពិសេស និងការរំលាយកិច្ចសន្យាលក់ទិញដោយការព្រមព្រៀងរបស់ភាគី។

**ជំពូកទី ២ នីតិវិធីនៃការរំលាយកិច្ចសន្យាលក់ទិញ** ដែលនឹងបង្ហាញអំពីអានុភាពនៃការបង្ហាញឆន្ទៈរំលាយរបស់ភាគី និងនីតិវិធីបណ្តឹងក្នុងករណីដែលភាគីម្ខាងទៀតមិនទទួលស្គាល់ការបង្ហាញឆន្ទៈរំលាយ ឬមិនព្រមបដិទាននូវកម្មវត្ថុនៃកិច្ចសន្យាលក់ទិញត្រឡប់មកវិញ។ បន្ថែមពីនេះ ក្នុងចំណុចនេះ នឹងលើកយកមកបង្ហាញអំពីមូលហេតុដែលសិទ្ធិរំលាយត្រូវបានរលត់ និងអានុភាពនៃការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញផងដែរ។

**ជំពូកទី ៣ អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញ** ដែលនឹងបង្ហាញអំពីទ្រឹស្តីសំខាន់ៗអំពីការអនុវត្តការរំលាយកិច្ចសន្យាលក់ទិញ ករណីយកិច្ចដែលកើតឡើងរវាងភាគីនៃកិច្ចសន្យា និងតតិយជនក្រោយពេលមានការរំលាយកិច្ចសន្យាលក់ទិញ។

# ជំពូកទី ១ សញ្ញាណទូទៅនៃការរំលាយកិច្ចសន្យាលក់ទិញ

## ១.អត្ថិភាពនៃការរំលាយកិច្ចសន្យាលក់ទិញ

### ១.១.ខ្លឹមសារនៃការរំលាយកិច្ចសន្យាលក់ទិញ

ការរំលាយកិច្ចសន្យាជាវិធានមួយក្នុងចំណោមបី ដែលភាគីអាចយកមកប្រើបាន ក្នុងករណីភាគីម្ខាងទៀតមិនបានអនុវត្តកាតព្វកិច្ចដែលកំណត់ក្នុងកិច្ចសន្យា។ និយមន័យនៃការរំលាយកិច្ចសន្យា ត្រូវបានកំណត់តាមមាត្រា ៤១១ កថាខណ្ឌទី ១ ដែលសំដៅទៅលើសកម្មភាពឯកតោភាគី ដែលធ្វើឱ្យភាគីទាំងសងខាងនៃកិច្ចសន្យារួចផុតពីករណីយកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងសំណងនៃការខូចខាតតែប៉ុណ្ណោះ។ ការរំលាយកិច្ចសន្យាអាចធ្វើដោយភាគីតែម្ខាងនៃកិច្ចសន្យា ដោយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ព្រោះការរំលាយកិច្ចសន្យាជាសកម្មភាពឯកតោភាគី ដែលជាសកម្មភាពនៃការបង្កើត ការកែប្រែ ឬការរំលត់កាតព្វកិច្ច ដោយការបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។[5]

ក្នុងន័យម៉្យាងទៀត ការរំលាយកិច្ចសន្យា កើតមានឡើងនៅពេលដែលភាគីម្ខាង បានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយស្របគ្នានេះភាគីម្ខាងទៀតបដិសេធក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ហេតុដូច្នេះ ភាគីដែលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន អាចសុំទាមទាររំលាយកិច្ចសន្យាបានដោយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតឡើយ។[6]

ទន្ទឹមគ្នានេះការរំលាយកិច្ចសន្យា ជាការបង្ហាញឆន្ទៈលុបចោលនូវអានុភាពនៃកិច្ចសន្យាដោយភាគីម្ខាងដោយផ្អែកទៅលើមូលហេតុកំណត់មួយដែលកើតឡើងក្រោយពេលធ្វើកិច្ចសន្យា។[7]

### ១.២.លក្ខខណ្ឌនៃការរំលាយកិច្ចសន្យាលក់ទិញ

ជាទូទៅកិច្ចសន្យា អាចត្រូវបានរំលាយ លុះត្រាតែកិច្ចសន្យានោះ ជាកិច្ចសន្យាអញ្ញមញ្ញដែលមានចំណងករណីយកិច្ចរវាងគ្នា ហើយកិច្ចសន្យានេះមានអានុភាព និងសុពលភាពតាមផ្លូវច្បាប់។ ម៉្យាងវិញទៀត ក្រោយពេលដែលកិច្ចសន្យាអញ្ញមញ្ញមានសុពលភាព និងអានុភាពតាមផ្លូវច្បាប់ ហើយកិច្ចសន្យានេះត្រូវបានបំពានយ៉ាងធ្ងន់ធ្ងរ ទើបភាគីដែលមានសិទ្ធិរំលាយអាចអនុវត្តសិទ្ធិរំលាយរបស់ខ្លួនបាន។

[5] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី, ទំព័រទី ១៧៦។

[6] សាស្ត្រាចារ្យ ជិន វណ្ណារ៉ា, នីតិកិច្ចសន្យា, ឆ្នាំ២០១៣, ទំព័រទី ១៧៧-១៧៨។

[7] សមិទ្ធផលរបស់គម្រោងនៃប្រព័ន្ធច្បាប់ និងតុលាការ, ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ ១ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ បោះពុម្ពលើក ទី១ ខែធ្នូ ឆ្នាំ២០១៥)។

### ១.២.១.អត្ថិភាពនៃកិច្ចសន្យាលក់ទិញ

ជាគោលការណ៍ និងដូចបានបញ្ជាក់ខាងលើ កិច្ចសន្យាលក់ទិញ អាចបង្កើតបានលុះត្រាតែបុគ្គលពីរនាក់ ឬច្រើននាក់ មានឆន្ទៈត្រូវគ្នាដើម្បីបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ចពាក់ព័ន្ធនឹងការលក់ទិញនូវកម្មវត្ថុ ឬទ្រព្យសម្បត្តិណាមួយ។ កាលណាកិច្ចសន្យាលក់ទិញមានអានុភាព និងសុពលភាពតាមផ្លូវច្បាប់ ភាគីមានកាតព្វកិច្ចក្នុងការអនុវត្តកិច្ចសន្យានោះ។ ប្រសិនបើកិច្ចសន្យានោះ ពុំមានអានុភាព ឬសុពលភាពទេ កិច្ចសន្យានោះពុំបានចង ឬបង្ខំឱ្យភាគីនៃកិច្ចសន្យាចាំបាច់ត្រូវអនុវត្តកិច្ចសន្យាតាមការព្រមព្រៀងនោះទេ។ ហើយជាធម្មតា ដើម្បីមានសិទ្ធិរំលាយកិច្ចសន្យាណាមួយបាន មិនថាជាកិច្ចសន្យាលក់ទិញ ឬកិច្ចសន្យាដទៃផ្សេងទៀតទេ ជាចាំបាច់កិច្ចសន្យានោះត្រូវមានអានុភាព និងសុពលភាពតាមផ្លូវច្បាប់ជាមុនសិន ដើម្បីធានាអំពីអត្ថិភាពនៃកិច្ចសន្យានោះ បើមិនដូច្នោះទេវិធាននៃការរំលាយកិច្ចសន្យានឹងមិនត្រូវបានយកមកអនុវត្តឡើយ។

ម៉្យាងវិញទៀត ជាចាំបាច់កិច្ចសន្យាដល់កាលកំណត់ត្រូវអនុវត្ត ឬត្រូវបានអនុវត្តរួចរាល់ ប៉ុន្តែការអនុវត្តនោះបានបំពានបញ្ញត្តិជាមូលដ្ឋាននៃការរំលាយកិច្ចសន្យា ឬបញ្ញត្តិពិសេសនៃការរំលាយកិច្ចសន្យាលក់ទិញ ឬដោយការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាដើម្បីរំលាយកិច្ចសន្យា ទើបសិទ្ធិរំលាយកិច្ចសន្យាត្រូវបានផ្តល់ជូនសម្រាប់ភាគីដើម្បីអនុវត្ត។

ដើម្បីបង្កើតឱ្យកិច្ចសន្យាលក់ទិញមានអានុភាពទៅបាន លុះត្រាតែសំណើ និងស្វីការត្រូវរូវគ្នា ភាគីមានសមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព ហើយការបង្ហាញឆន្ទៈគ្មានវិការៈ។ ជាពិសេស កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ មិនផ្ទុយពីបញ្ញត្តិច្បាប់ ដែលនាំឱ្យមានការមោឃភាពនៃកិច្ចសន្យា។

+ សំណើ និងស្វីការ

យោងតាមមាត្រា ៣៣៦ កិច្ចសន្យានឹងបង្កើតអានុភាព កាលណាបើសំណើ និងស្វីការត្រូវរូវគ្នា។ ហើយដំណឹងអំពីស្វីកាចំពោះសំណើនោះ បានមកដល់អ្នកស្នើ។[8]

– សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនោះ។[9] ក្នុងន័យនេះសំណើ សំដៅទៅការបង្ហាញឆន្ទៈដើម្បីបង្កើត កែប្រែ ឬរំលត់ចំណងគតិយុត្តិអ្វីមួយ។ ឧទាហរណ៍៖ លោក ក បានដាក់ស្លាកដើម្បីលក់រថយន្តរបស់ខ្លួនក្នុងតម្លៃ ៥០០០ ដុល្លារអាមេរិក សកម្មភាពរបស់លោក ក អាចបញ្ជាក់បានថាគាត់មានឆន្ទៈបង្កើតសំណើ ឬសំណើដើម្បីលក់ឡានរបស់គាត់ត្រូវបានកើតឡើងរួចមកហើយ។ ត្បិតតែសំណើនោះបានកើតឡើងក៏ពិតមែន

[8] មាត្រា ៣៤០ នៃក្រមរដ្ឋប្បវេណី។

[9] មាត្រា ៣៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។

ប្រសិនបើសំណើមិនទាន់បានទៅដល់ភាគីម្ខាងទៀតទេ សំណើនោះនឹងមិនមានអានុភាពក្នុងការបង្កើតកិច្ចសន្យាឡើយ។[10]

– ស្វីការ

ដើម្បីឆ្លើយតបនឹងសំណើ ភាគីត្រូវបង្ហាញចម្លើយដែលស្របតាមឆន្ទៈរបស់ខ្លួននឹងសំណើដែលបានដាក់មកនោះ តាមក្រមរដ្ឋប្បវេណីស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[11] ក្នុងឧទាហរណ៍ខាងលើ លោក ក បានដាក់សំណើក្នុងការលក់រថយន្តរបស់ខ្លួន តម្លៃ ៥០០០ដុល្លារអាមេរិក ហើយលោកស្រី ខ ទទួលសំណើរបស់លោក ក ហើយលោកស្រី បានបង្ហាញឆន្ទៈយល់ព្រមចំពោះសំណើនោះផងដែរ ដោយការទិញរថយន្តនោះក្នុងតម្លៃ ៥០០០ដុល្លារអាមេរិក។ ប៉ុន្តែស្វីការនេះ នឹងមិនមានអានុភាពឡើយ ប្រសិនបើការបង្ហាញស្វីការនៃការព្រមព្រៀងចំពោះសំណើនេះ មិនបានទៅដល់អ្នកស្នើ ឬការបង្ហាញឆន្ទៈក្នុងការដកស្វីការបានទៅដល់ព្រមគ្នានឹងពេលស្វីការទៅដល់ ឬមុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើងឡើយ។[12]

+ ការលុបចោលកិច្ចសន្យា

ក្រមរដ្ឋប្បវេណី បានបញ្ញត្តិលក្ខខណ្ឌមួយចំនួនដើម្បីប្រគល់អំណាចឱ្យភាគី ដើម្បីមានសិទ្ធិសម្រាប់លុបចោលកិច្ចសន្យាបាន។ តាមក្រមរដ្ឋប្បវេណីមូលហេតុដែលនាំឱ្យភាគីមានសិទ្ធិលុបចោលកិច្ចសន្យាបាន មានដូចជាសមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និងវិការៈនៃការបង្ហាញឆន្ទៈ ។

– សមត្ថភាពខាងឆន្ទៈ

សមត្ថភាពខាងឆន្ទៈ សំដៅលើសកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន។[13]

– សមត្ថភាពក្នុងការធ្វើសកម្មភាព

អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមបបហិតូបត្ថម្ភ។[14] ក្រមរដ្ឋប្បវេណីបានកម្រិតសមត្ថភាពសម្រាប់ជនទាំងបីប្រភេទនេះ ប្រសិនបើជនទាំងបីប្រភេទនេះបានធ្វើសកម្មភាពរបស់ខ្លួនហួសដែនកំណត់ ឬលើសទៅនឹងអ្វីដែលបានកំណត់ដោយច្បាប់ ភាគីមានសិទ្ធិលុបចោលសកម្មភាពនោះបាន។

---

[10] មាត្រា ៣៣៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។

[11] មាត្រា ៣៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី។

[12] មាត្រា ៣៣៧ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី។

[13] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី។

[14] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី។

• អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[15]

• ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅចំពោះជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[16]

• ជននៅក្រោមរបបហិតូបត្ថម្ភ សំដៅចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[17]

– វិការៈនៃការបង្ហាញឆន្ទៈ

ទោះបីជាភាគីបានព្រមព្រៀងគ្នាតាមរយៈសំណើនិងស្វីការត្រូវរូវគ្នា និងភាគីមានសមត្ថភាពក្នុងការធ្វើសកម្មភាព ឬសមត្ថភាពខាងឆន្ទៈ ដើម្បីបង្កើតអានុភាពនៃកិច្ចសន្យាក៏ពិតមែន ប៉ុន្តែក្នុងករណីខ្លះប្រសិនបើការព្រមព្រៀងនេះមានវិការៈ ឬស្ថិតក្រោមស្ថានភាពពិសេសណាមួយ ដែលនាំឱ្យភាគីម្ខាងបានបង្ហាញឆន្ទៈដែលប៉ះពាល់ដល់ប្រយោជន៍ផ្ទាល់ខ្លួន។ ក្នុងករណីនេះច្បាប់បានផ្តល់សិទ្ធិឱ្យអ្នកដែលបានបង្ហាញឆន្ទៈស្ថិតក្នុងស្ថានភាពខាងលើ មានសិទ្ធិលុបចោលកិច្ចសន្យា ដើម្បីបញ្ឈប់អានុភាពនៃកិច្ចសន្យាបាន។

ក្រមរដ្ឋប្បវេណី បានបញ្ញត្តិអំពីករណីដែលភាគីអាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាមានដូចជា ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ការបង្ហាញឆន្ទៈត្រូវធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការណ៍មិនពិតរបស់ភាគីម្ខាងទៀត និងការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។[18]

\+ មោឃភាពនៃកិច្ចសន្យា

ក្រៅពីលក្ខខណ្ឌដែលបានបង្ហាញខាងលើ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យានោះ មិនត្រូវបានអនុញ្ញាត និងហាមឃាត់ដោយបញ្ញត្តិច្បាប់ ឬទម្រង់នៃកិច្ចសន្យាមិនត្រូវបានបំពេញ សិទ្ធិមោឃភាពកិច្ចសន្យាត្រូវបានកើតមានឡើង។ តាមក្រមរដ្ឋប្បវេណី ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានហាមឃាត់ដោយក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។[19]

[15] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី។
[16] មាត្រា ២៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។
[17] មាត្រា ២៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។
[18] មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី។
[19] មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី។

ក្រៅពីលក្ខខណ្ឌជាមូលដ្ឋានខាងលើ កិច្ចសន្យាលក់ទិញ អាចមានអានុភាពទៅបានលុះត្រាបំពេញលក្ខខណ្ឌទម្រង់ដែលកំណត់ដោយឡែក ដែលបង្ហាញអំពីចរិកលក្ខណៈខុសគ្នាពីកិច្ចសន្យាពិសេសដទៃទៀត ដែលបានកំណត់ក្នុងគន្ថីទី ៥ នៃក្រមរដ្ឋប្បវេណី។

លក្ខខណ្ឌទម្រង់ដែលញុំាងឱ្យកិច្ចសន្យាលក់ទិញមានអានុភាព ឬត្រូវបានបង្កើតឡើង គ្រាន់តែមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ នោះភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬលិខិតឯកជន ជាលក្ខខណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន។[20] ត្រង់ចំណុច "លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់" អ្នកនីតិនិពន្ធបានសំដៅដល់ការអនុវត្តសិទ្ធិលក់ដោយតុលាការ តាមវិធានការអនុវត្តដោយបង្ខំក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដើម្បីការពារ និងអនុវត្តកាតព្វកិច្ចជំនួសកូនបំណុលចំពោះម្ចាស់បំណុល។

ក្រោយពេលកិច្ចសន្យាបានបង្កើតឡើងដោយសំណើនិងស្វីការត្រូវគ្នា ហើយលក្ខខណ្ឌអានុភាពនៃសមត្ថភាពក្នុងការធ្វើសកម្មភាព សមត្ថភាពខាងឆន្ទៈត្រូវបានបំពេញ ព្រមទាំងធ្វើឡើងដោយគ្មានវិការៈ និងខ្លឹមសារ ឬសកម្មភាពមិនល្មើសនឹងបញ្ញត្តិច្បាប់ទេ ទើបកិច្ចសន្យានោះពិតជាបានបង្កើតអានុភាពដោយពិតប្រាកដ ដែលចងភាគីទាំងសងខាងចាំបាច់ត្រូវអនុវត្តកិច្ចសន្យានោះ បើមិនដូច្នោះទេភាគីម្ខាងទៀតអាចអនុវត្តសិទ្ធិរំលាយកិច្ចសន្យារបស់ខ្លួនក្រោមវិធានសង្គ្រោះកិច្ចសន្យាបាន ក្នុងករណីមានការមិនអនុវត្តកាតព្វកិច្ច។

### ១.២.២.កិច្ចសន្យាអញ្ញមញ្ញ

តាមមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

កិច្ចសន្យាអញ្ញមញ្ញ ជាកិច្ចសន្យាដែលភាគីទាំងសងខាងមានកាតព្វកិច្ច ដែលកាតព្វកិច្ចនោះមានទំនាក់ទំនងជាតម្លៃថ្នូរទៅវិញទៅមក។[21] កិច្ចសន្យាអញ្ញមញ្ញនឹងបង្កើតឱ្យមានកាតព្វកិច្ចទៅវិញទៅមក រវាងភាគីទាំងសងខាងនៃកិច្ចសន្យា ពោលគឺភាគីទាំងសងខាងជាម្ចាស់បំណុលផង និងជាកូនបំណុលផង។ កិច្ចសន្យាអញ្ញមញ្ញរួមមានកិច្ចសន្យាលក់ទិញ ភតិសន្យា កិច្ចសន្យាខ្ចីប្រើ កិច្ចសន្យាខ្ចីបរិភោគ។ល។

ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញរថយន្តរវាង A (អ្នកលក់) និង B (អ្នកទិញ) មានអានុភាពដោយការព្រមព្រៀងរវាងភាគី។ នៅពេលដែលកិច្ចសន្យាបង្កើតអានុភាព អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ឱ្យអ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចបង់ប្រាក់ថ្លៃទិញទៅឱ្យអ្នកលក់ ហេតុនេះ

[20] មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី។

[21] សាស្ត្រាចារ្យ Fukuoka Fumie និង Umemoto Yumi, បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, ទំព័រទី ៥។

កិច្ចសន្យាលក់ទិញជាប្រភេទកិច្ចសន្យាអញ្ញមញ្ញ ពីព្រោះថាភាគីទាំងសងខាងទទួលបន្ទុកក្នុងការអនុវត្ត ករណីយកិច្ចរៀងៗខ្លួន។

នៅក្នុងកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងបានព្រមព្រៀងដោយបង្កើតករណីយកិច្ច និងសិទ្ធិដែលមានភាពទាក់ទងគ្នា ឬចំណុះឱ្យគ្នាទៅវិញទៅមក។ ជាក់ស្តែង A (អ្នកលក់) បានព្រមព្រៀងប្រគល់រថយន្តរបស់ខ្លួនដោយការទទួលបាននូវប្រាក់ជាថ្លៃលក់មកវិញ ហើយទន្ទឹមនឹងនោះ B (អ្នកទិញ) ក៏បានបង្ហាញឆន្ទៈដូចគ្នាដោយព្រមទទួលរថយន្តពីអ្នកលក់ និងប្រគល់ប្រាក់ជាថ្លៃទិញទៅវិញ។ ដូចនេះ វាបានបង្កើតឱ្យមាននូវចំណងកាតព្វកិច្ចរវាងអ្នកលក់ និងអ្នកទិញដែលបណ្តាលឱ្យមានអានុភាពនៃកិច្ចសន្យាអញ្ញមញ្ញ។

ដូចបានបញ្ជាក់ខាងលើ ការរំលាយកិច្ចសន្យាជាវិធានសម្រាប់សង្គ្រោះកិច្ចសន្យា ប៉ុន្តែមិនមែនគ្រប់ប្រភេទនៃកិច្ចសន្យា អាចយកវិធានរំលាយកិច្ចសន្យាមកអនុវត្តបានទេ។ ដោយហេតុតែការរំលាយកិច្ចសន្យាគឺជាប្រព័ន្ធដែលភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ អាចរួចផុតពីការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយយកការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុ។

ផ្ទុយទៅវិញ សម្រាប់កិច្ចសន្យាមួយចំនួនដូចជាកិច្ចសន្យាខ្ចីប្រើ កិច្ចសន្យាប្រទានកម្មជាអាទិ៍ ជាប្រភេទនៃកិច្ចសន្យាឯកតោភាគី ពីព្រោះមានភាគីម្ខាងតែប៉ុណ្ណោះដែលទទួលបន្ទុកកាតព្វកិច្ច ហេតុនេះមិនអាចធ្វើការរំលាយកិច្ចសន្យាបានឡើយ។[22]

### ១.២.៣.គាចកាលិកដល់កាលកំណត់ត្រូវអនុវត្ត

ជាទូទៅកិច្ចសន្យាដល់កាលកំណត់ក្នុងការអនុវត្ត ហើយភាគីបានអនុវត្តតាមកាលកំណត់នោះ កាតព្វកិច្ច និងសិទ្ធិដែលត្រូវបានកើតឡើងក្រោមអានុភាពនៃកិច្ចសន្យា ត្រូវបានរលត់ក្រោមមូលហេតុនៃការសង។ ហើយបើកាតព្វកិច្ចមិនត្រូវបានអនុវត្តតាមកាលកំណត់នៃកិច្ចសន្យាទេ ភាគីមានសិទ្ធិរំលាយកិច្ចសន្យា ប៉ុន្តែប្រសិនបើកាលកំណត់សម្រាប់អនុវត្តកិច្ចសន្យា ពុំទាន់បានដល់ទេ ភាគីមិនអាចទាមទារឱ្យភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ចបានទេ ក្នុងន័យមួយទៀត ប្រសិនបើមិនទាន់ដល់កាលកំណត់ដើម្បីអនុវត្តកិច្ចសន្យាទេ ទោះភាគីម្ខាងណាមិនទាន់អនុវត្តកាតព្វកិច្ច ក៏ភាគីម្ខាងទៀតមិនអាចប្រើសិទ្ធិក្នុងការរំលាយកិច្ចសន្យាបានឡើយ។

### ១.២.៤.ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ

ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ច ភាគីនៃកិច្ចសន្យាដែលទទួលរងផលប៉ះពាល់ពីការមិនអនុវត្តកាតព្វកិច្ចនោះ មានសិទ្ធិរំលាយកិច្ចសន្យាបាន។ ត្បិតតែការមិនអនុវត្តកាតព្វកិច្ចជាប្រភព ដែលនាំឱ្យមានការអនុវត្តវិធានសង្គ្រោះកិច្ចសន្យាក៏ពិតមែន ប៉ុន្តែដើម្បីអនុវត្តវិធាននៃការរំលាយកិច្ចសន្យាបាន លុះត្រាតែការមិនអនុវត្តកាតព្វកិច្ចនោះ បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ដែលការបំពានកិច្ចសន្យាធ្ងន់ធ្ងរ សំដៅលើករណីដែលភាគី

[22] សាស្ត្រាចារ្យសេង នាង និងលោកស្រីមេធាវី ទេព បូផល, ការរំលាយកិច្ចសន្យា, ឆ្នាំ ២០១៩, ទំព័រទី ២៧។

ម្ខាង មិនបានសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ស្របតាមតាមបញ្ញត្តិនៃមាត្រា ៤០៨ ដែលបានកំណត់លក្ខណៈទូទៅដែលមូលហេតុចម្បងសម្រាប់អនុវត្តសិទ្ធិរំលាយកិច្ចសន្យាបាន។ ម៉្យាងវិញទៀត មូលហេតុនៃការរំលាយកិច្ចសន្យា ក៏ត្រូវបានបញ្ញត្តិដោយឡែកសម្រាប់វិធានអនុវត្តចំពោះកិច្ចសន្យាពិសេសនីមួយៗផងដែរ និងក្រៅពីនេះ មូលហេតុនៃការរំលាយកិច្ចសន្យា ក៏ត្រូវបានកើតឡើងដោយការព្រមព្រៀងរវាងគូភាគីផងដែរ។

ការរំលាយកិច្ចសន្យាមិនតម្រូវឱ្យការមិនអនុវត្តកាតព្វកិច្ចនេះ កើតឡើងដោយកំហុសនោះទេ។ ក្នុងករណីដែលការមិនអនុវត្តកាតព្វកិច្ចនេះបានបំពេញតាមលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ឬបញ្ញត្តិពិសេស ឬការព្រមព្រៀងរវាងភាគី ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ត្រូវបានចាត់ទុកថាកើតមានឡើង។

ឧទាហរណ៍៖ A បានបញ្ជាឱ្យជាងកាត់សំលៀកបំពាក់ B កាត់សំលៀកបំពាក់ អាពាហ៍ពិពាហ៍សម្រាប់ស្លៀកនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ ដែលជាថ្ងៃអាពាហ៍ពិពាហ៍របស់ខ្លួន។ ប៉ុន្តែមកដល់ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២១ B (ជាងកាត់សំលៀកបំពាក់ ) មិនទាន់កាត់សំលៀកបំពាក់រួចរាល់ទាន់ពេលវេលានោះទេ។ ក្នុងករណីនេះ A អាចរំលាយកិច្ចសន្យា ដោយមូលហេតុ B បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ជាក់ស្តែង A បានបញ្ជាទៅ B ដើម្បីកាត់សំលៀកបំពាក់អាពាហ៍ពិពាហ៍ឱ្យខ្លួន ប៉ុន្តែ B ពុំបានអនុវត្តទាន់ពេលនោះទេ។ ហេតុដូច្នេះវាមានលក្ខណៈច្បាស់លាស់ថា គោលបំណងនៃកាតព្វកិច្ចនេះ មិនត្រូវបានសម្រេចដោយហេតុថា B មិនបានអនុវត្តកាតព្វកិច្ចតាមកាលបរិច្ឆេទដែលបានកំណត់ ដោយផ្អែកតាមលក្ខណៈនៃខ្លឹមសារក្នុងកិច្ចសន្យាទេ។

### ១.២.៥.ការបង្ហាញឆន្ទៈរំលាយ

ត្បិតតែកិច្ចសន្យាត្រូវបានបំពានយ៉ាងធ្ងន់ធ្ងរ ស្របតាមមូលហេតុដែលបញ្ញត្តិដោយច្បាប់ក៏ដោយ ប្រសិនបើភាគីមិនបានអនុវត្តសិទ្ធិរំលាយរបស់ខ្លួនចំពោះកិច្ចសន្យានោះទេ អានុភាព និងអត្ថិភាពនៃកិច្ចសន្យានោះនៅតែមានដដែល។ ការអនុវត្តសិទ្ធិរំលាយរបស់ភាគីត្រូវធ្វើឡើង ឬមានអានុភាពដោយភាគីម្ខាងដែលមានសិទ្ធិរំលាយបានបង្ហាញឆន្ទៈថារំលាយកិច្ចសន្យាចំពោះភាគីម្ខាងទៀតតែប៉ុណ្ណោះ។

ទោះបីជាការរំលាយកិច្ចសន្យាជាវិធានសម្រាប់សង្គ្រោះកិច្ចសន្យាអញ្ញមញ្ញ ដែលកើតឡើងដោយការព្រមព្រៀងរវាងភាគី ប៉ុន្តែការបង្ហាញឆន្ទៈដើម្បីរំលាយកិច្ចសន្យាអញ្ញមញ្ញ ជាសកម្មភាពឯកតោភាគីដែលមិនតម្រូវឱ្យមានការព្រមព្រៀងពីភាគីម្ខាងទៀតឡើយ។

អាស្រ័យដូចមានបញ្ជាក់ក្នុងឧទាហរណ៍ខាងលើ A (អ្នកបញ្ជាទិញ) បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយមូលហេតុថា B (ជាងកាត់សំលៀកបំពាក់) ពុំបានអនុវត្តករណីយកិច្ចរបស់ខ្លួនទាន់ពេលវេលា ដែលជាហេតុធ្វើឱ្យគោលបំណងនៃកិច្ចសន្យារវាង A និងB ពុំអាចសម្រេចបាន។ ហេតុដូច្នេះ A បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាចំពោះ B ហើយអានុភាពនៃការរំលាយកិច្ចសន្យានេះ កើតឡើងនៅពេលដែលការបង្ហាញឆន្ទៈរបស់ A

បានទៅដល់ B។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ មិនចាំបាច់ត្រូវមានការយល់ព្រមពី B នោះទេ ដោយហេតុថាវាជាសកម្មភាពឯកតោភាគីដែលផ្តល់សិទ្ធិឱ្យភាគីដែលជាជនរងគ្រោះពីការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរមានសិទ្ធិដើម្បីការពារប្រយោជន៍របស់ខ្លួនតាមផ្លូវច្បាប់។

## ២.មូលហេតុនៃការរំលាយកិច្ចសន្យាលក់ទិញ

ការរំលាយកិច្ចសន្យាលក់ទិញ អាចកើតក្រោមមូលហេតុដែលបានកំណត់ដោយបញ្ញត្តិមូលដ្ឋាន (២.១) មូលហេតុនៃការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិពិសេស (២.២) និងការរំលាយកិច្ចសន្យាលក់ទិញដោយឆន្ទៈរបស់ភាគី (២.៣)។

### ២.១.ការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិមូលដ្ឋាន

#### ២.១.១.ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវនោះបីជាមានការដាស់តឿន

ភាគីម្ខាងនៃកិច្ចសន្យាបានដាស់តឿនឱ្យភាគីម្ខាងទៀត ដែលមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចនោះមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។[23] យោងទៅលើអត្ថន័យខាងលើនេះ យើងអាចកំណត់បានលក្ខខណ្ឌចំនួន០៤ (បួន) ដែលកើតមានឡើង៖

+ លក្ខខណ្ឌទី១៖ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច[24]

កូនបំណុលត្រូវចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងករណីដែលខ្លួនមិនអនុវត្តកាតព្វកិច្ច នៅពេលដែលបានកំណត់ដូចខាងក្រោម៖

- ករណីដែលមានកំណត់ពេលពិតប្រាកដ (កាលបរិច្ឆេទកំណត់ជាក់លាក់ក្នុងកិច្ចសន្យា)
- ករណីដែលមានពេលកំណត់មិនពិតប្រាកដ (ពេលណាមួយដែលត្រូវតែមកដល់ តែមិនដឹងច្បាស់ថាពេលណា)។ ឧទាហរណ៍៖ លោក **ក** បានសន្យាថានឹងសងប្រាក់មកឱ្យកញ្ញា **ខ** នៅពេលដែលលោកបានទទួលមត៌ក តាមរយៈសន្តតិកម្ម នោះពេលដែលលោក **ក** ដឹងថាលោកបានទទួលមត៌កហើយ បើលោកមិនសងប្រាក់មកកញ្ញា **ខ** វានឹងក្លាយទៅជាការការយឺតយ៉ាវក្នុងការអនុវត្ត។
- ករណីដែលមិនកំណត់អំឡុងពេល (តែកូនបំណុលទទួលបានការទាមទារឱ្យអនុវត្តកាតព្វកិច្ច)។

+ លក្ខខណ្ឌទី២៖ ការដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ

ដូច្នេះប្រសិនបើភាគីណាម្ខាងយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ភាគីម្ខាងទៀតត្រូវដាស់តឿនភាគីម្ខាងឱ្យអនុវត្តនូវកាតព្វកិច្ចនោះដោយកំណត់អំឡុងពេលសមរម្យ។ ចំពោះអំឡុងពេលសមរម្យនេះ គឺមិនមែនជាការ

[23] មាត្រា ៤០៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី។

[24] មាត្រា ៣៩១ នៃក្រមរដ្ឋប្បវេណី។

គណនាអំឡុងពេលចាំបាច់ ដើម្បីរៀបចំការអនុវត្តពីពេលដែលទទួលបានការដាស់តឿនរហូតដល់ការអនុវត្តស្ពាពរនោះទេ ប៉ុន្តែវាជាជាការគណនាអំឡុងពេលដោយសន្និដ្ឋានថា ការរៀបចំដើម្បីអនុវត្តមួយភាគធំធ្វើរួចរាល់ហើយ។ ម្យ៉ាងទៀតទោះបីជាការដាស់តឿននោះកំណត់អំឡុងពេលមិនសមរម្យ ឬមិនបានកំណត់អំឡុងពេល ក៏ការរំលាយកិច្ចសន្យានៅតែអាចធ្វើបានដែរ នៅពេលដែលអំឡុងពេលនោះបានកន្លងផុតទៅ។ ក្នុងន័យនេះចង់បញ្ជាក់ថា បើទោះបីជាគ្មានការដាស់តឿនក៏ដោយ ក៏កូនបំណុលត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅពេលកំណត់បានមកដល់ ហើយបើមានការយឺតយ៉ាវ ក៏ជាទូទៅកូនបំណុលក៏គួរតែបានរៀបចំនូវការអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានមួយភាគធំដែរ ទើបបញ្ញត្តិនេះបានផ្តល់អំឡុងពេលសមរម្យបន្ថែមក្រោយពីការដាស់តឿន ជាការគ្រប់គ្រាន់ទៅហើយ ដើម្បីឱ្យកូនបំណុលអាចបំពេញកាតព្វកិច្ចដែលខ្វះចំពោះម្ចាស់បំណុលបាន។[25]

+ លក្ខខណ្ឌទី៣៖ អំឡុងពេលសមរម្យបានកន្លងផុត

នៅពេលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលដាស់តឿននោះទេ បើទោះបីជាម្ចាស់បំណុលបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យក៏ដោយ នោះម្ចាស់បំណុលអាចធ្វើការរំលាយកិច្ចសន្យាបានដោយមិនចាំបាច់អះអាងអំពីការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលនៅពេលកំណត់ និងអំឡុងពេលដាស់តឿននោះទេ។ ប្រសិនបើកូនបំណុលចង់តវ៉ានោះ គប្បីវាជាកាតព្វកិច្ចរបស់កូនបំណុលក្នុងការរកសំអាងមកបញ្ជាក់ពីការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។[26]

+ លក្ខខណ្ឌទី៤៖ ការអនុវត្ត ឬសំណើផ្តល់ការសងកាតព្វកិច្ចរបស់ខ្លួន

ចំណុចនេះមិនបានកំណត់នៅក្នុងមាត្រានោះទេ ប៉ុន្តែនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ដើម្បីអាចចាត់ទុកបានថាភាគីយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដោយបំពានកិច្ចសន្យាធ្ងន់ធ្ងរនោះ លុះត្រាតែភាគីម្ខាងទៀតគប្បីត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន (ស្នើផ្តល់ការសង) ជាមុនសិន។[27]

ឧទាហរណ៍៖ ក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់អាចប្រកែកមិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុបានរហូតដល់ពេលដែលអ្នកទិញបានផ្តល់ការសង។ រីឯអ្នកទិញក៏អាចមិនព្រមបង់ថ្លៃទិញបានរហូតដល់ពេលដែលអ្នកលក់បានផ្តល់កម្មវត្ថុនៃកិច្ចសន្យារបស់ខ្លួន។ ដូចនេះបង្ហាញឱ្យឃើញថាភាគីមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ហើយភាគីក៏អាចបដិសេធក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានរហូតដល់ពេលដែលភាគីម្ខាងទៀតបានអនុវត្តកាតព្វកិច្ចចំពោះខ្លួនផងដែរ។

[25] សាស្ត្រាចារ្យ UMEMOTO YUMI, ការរំលាយកិច្ចសន្យា, ទំព័រទី១៣។
[26] សាស្ត្រាចារ្យ UMEMOTO YUMI, ការរំលាយកិច្ចសន្យា, ទំព័រទី១៥។
[27] សាស្ត្រាចារ្យ UMEMOTO YUMI, ការរំលាយកិច្ចសន្យា, ទំព័រទី១៦។

នៅពេលដែលកូនបំណុលរៀបចំសព្វគ្រប់នូវតាវកាលិកសម្រាប់សង និងទាមទារឱ្យម្ចាស់បំណុលទទួលការសង ហៅថា**សំណើផ្តល់ការសង**។[28] ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញរថយន្តមួយ អ្នកលក់បានប្រាប់ថ្ងៃដែលត្រូវប្រគល់រថយន្តដល់អ្នកទិញ ហើយបានត្រៀមឡាននោះនៅផ្ទះរបស់ខ្លួន។

### ២.១.២.ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវចំពោះសកម្មភាពកំណត់អំឡុងពេលចាំបាច់

ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីម្ខាងមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់។[29] ចំពោះសកម្មភាពដែលមានកំណត់អំឡុងពេលបែបនេះ ភាគីអាចរំលាយបានភ្លាមៗ ដោយមិនចាំបាច់មានការដាស់តឿន ព្រោះតែនៅពេលដែលមានការអនុវត្តកាតព្វកិច្ចក្រោយអំឡុងពេលនោះបានបញ្ចប់ទៅ ក៏វាគ្មានន័យសំរាប់ភាគីម្ខាងទៀតដែរ។ នៅក្នុងចំណុចនេះ វាមានកិច្ចសន្យា០២ ប្រភេទដែលចាំបាច់លើកយកមកពិភាក្សា៖[30]

+ ប្រភេទទី០១ គឺជាកិច្ចសន្យាដែលគោលបំណងរបស់វាមិនអាចសម្រេចបានសោះ តាមលក្ខណៈរបស់កិច្ចសន្យានោះ ប្រសិនបើការអនុវត្តកាតព្វកិច្ចពុំត្រូវបានធ្វើឡើងនៅអំឡុងពេលនោះ។ ឧទាហរណ៍៖ ការបញ្ជាឱ្យជាងដេរសម្លៀកបំពាក់ឯកសណ្ឋានត្រៀមសំរាប់ចូលរួមកម្មវិធីណាមួយ។
+ ប្រភេទទី០២ គឺកិច្ចសន្យាដែលត្រូវអនុវត្តកាតព្វកិច្ចនៅពេលកំណត់ ដោយស្របទៅតាមឆន្ទៈរបស់ភាគី។ ឧទាហរណ៍៖ ការបញ្ជាទិញម្ហូបអាហារសម្រាប់ពិធីជប់លៀងជួបជុំជាដើម។

លក្ខខណ្ឌចំនួន ០៤ ដែលសំខាន់សម្រាប់ការរំលាយកិច្ចសន្យាដែលកំណត់អំឡុងពេលក្នុងការអនុវត្តសកម្មភាពមាន៖

+ លក្ខខណ្ឌទី១៖ ការកំណត់អំឡុងពេល

ការព្រមព្រៀងបង្កើតកិច្ចសន្យា រួចកំណត់អំឡុងពេលជាក់លាក់ណាមួយដែលត្រូវអនុវត្តកាតព្វកិច្ច។ ព្រោះថាដើម្បីអាចអះអាងថាភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ទើបម្ចាស់បំណុលចាំបាច់ត្រូវប្រាប់អំពីកាលបរិច្ឆេទណាមួយជាក់លាក់ដើម្បីឱ្យកូនបំណុលអាចរៀបចំអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។

ឧទាហរណ៍៖ ករណីដែលភាគីម្ខាងសុំជាងកាត់ដេរឱ្យកាត់សម្លៀកបំពាក់ឱ្យបានមុនថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ សម្រាប់ចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១។

+ លក្ខខណ្ឌទី២៖ ការកន្លងផុតពេលកំណត់សម្រាប់អនុវត្ត

ដល់កាលបរិច្ឆេទកំណត់សម្រាប់អនុវត្ត ភាគីម្ខាងមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមការព្រមព្រៀង។

[28] មាត្រា ៤៥៣ នៃក្រមរដ្ឋប្បវេណី។
[29] មាត្រា ៤០៨ ចំណុច ខ នៃក្រមរដ្ឋប្បវេណី។
[30] សេចក្តីពន្យល់ក្រមក្រមរដ្ឋប្បវេណី, ទំព័រទី១៨១។

ឧទាហរណ៍៖ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ ជាងកាត់ខោអាវ មិនទាន់បានដេរសម្លៀកបំពាក់ឱ្យអ្នកទិញរួចរាល់នៅឡើយ។

\+ លក្ខខណ្ឌទី៣៖ គោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ

នៅពេលដែលមានការមិនអនុវត្តកាតព្វកិច្ចកើតឡើង ធ្វើឱ្យប៉ះពាល់ដល់ភាគីម្ខាងទៀតយ៉ាងធ្ងន់ធ្ងរ ដោយសារតែការកំណត់អំឡុងពេលឱ្យអនុវត្តកាតព្វកិច្ចគឺមានភាពចាំបាច់ ដើម្បីឱ្យគាត់អាចសម្រេចគោលបំណងដែលគាត់បានបង្កើតកិច្ចសន្យានេះឡើយ។

ឧទាហរណ៍៖ ពេលដែលជាងមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាននៅថ្ងៃដែលកំណត់នោះ ធ្វើឱ្យអ្នកទិញមិនមានសម្លៀកបំពាក់សម្រាប់ស្លៀកទៅចូលរួមកម្មវិធីអាពាហ៍ពិពាហ៍បានឡើយ។

\+ លក្ខខណ្ឌទី៤៖ ភាគីម្ខាងបានអនុវត្ត ឬស្នើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន

ជាទូទៅនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ដើម្បីអាចចាត់ទុកបានថាភាគី យឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដោយបំពានកិច្ចសន្យាធ្ងន់ធ្ងរនោះ លុះត្រាតែភាគីម្ខាងទៀតគប្បីត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន (ស្នើផ្តល់ការសង) ជាមុនសិន។

ឧទាហរណ៍៖ អ្នកទិញ បានស្នើសុំឱ្យជាងដេរផ្តល់សម្លៀកបំពាក់ដែលបានកម្ម៉ង់មកខ្លួន ដើម្បីពាក់ចូលរួមកម្មវិធី។

ផ្អែកលើលក្ខខណ្ឌទាំងបួនចំណុចនេះ បើគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចដោយសារតែការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង ភាគីម្ខាងទៀតមានសិទ្ធិរំលាយកិច្ចសន្យាបានភ្លាមៗ ព្រោះទោះបីជាកម្មវត្ថុនៃកិច្ចសន្យាបានសម្រេចនៅពេលក្រោយ ក៏មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបានឡើយ។ ជាក់ស្តែងទោះជាងដេរបានផ្តល់អាវឱ្យអ្នកទិញនៅពេលក្រោយក៏ពិតមែន ប៉ុន្តែកម្មវិធីដែលអ្នកទិញមានបំណងចង់ពាក់សម្លៀកបំពាក់នោះចូលរួម បានកន្លងផុតទៅហើយ។

### ២.១.៣.អលទ្ធភាពក្នុងការអនុវត្ត

អលទ្ធភាពក្នុងការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ក៏មិនខុសគ្នាពីអត្ថន័យនៃអលទ្ធភាពនៅក្នុងការមិនអនុវត្តកាតព្វកិច្ចដែរ គឺកូនបំណុលត្រូវចាត់ទុកថាអលទ្ធភាពក្នុងការអនុវត្ត នៅពេលដែលកូនបំណុលមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបាន។[31] ហើយអលទ្ធភាពក្នុងការអនុវត្តអាស្រ័យទៅតាមលក្ខណៈសារជាតុ និងអលទ្ធភាពតាមស្ថានភាពសង្គម ឬសេដ្ឋកិច្ច។[32] ទោះបីជាកាលកំណត់ត្រូវអនុវត្តមិនទាន់មកដល់

[31] មាត្រា ៤០៨ ចំណុច គ នៃក្រមរដ្ឋប្បវេណី។

[32] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ទំព័រទី ១៥៩។

ក៏ដោយ កូនបំណុលនឹងត្រូវបានចាត់ទុកថាបានធ្លាក់ទៅក្នុងស្ថានភាពនៃការមិនអនុវត្តកាតព្វកិច្ច ហើយការទទួលខុសត្រូវដូចជាការសងសំណងនៃការខូចខាត ជាអាទិ៍ នឹងកើតមានឡើងបានដែរ។[33]

អលទ្ធភាពតាមលក្ខណៈរូបធាតុ គឺកើតឡើងនៅពេលដែលកម្មវត្ថុដែលជាតាវកាលិកត្រូវបានខូចខាត ដោយសារតែអំពើ ឬសកម្មភាពណាមួយដែលធ្វើឱ្យវត្ថុនោះបែកបាក់ខ្ទេចខ្ទីមិនជួសជុលដូចសភាពដើមបាន។ ឧទាហរណ៍៖ លោក វឌ្ឍា បានទិញនាឡិកាបុរាណមួយពីកញ្ញា ដាវី។ ប៉ុន្តែ កញ្ញា ដាវី បានធ្វើឱ្យមានកំហុសក្នុងការលើកទុកដាក់នាឡិកាបុរាណដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ហើយបានធ្វើឱ្យនាឡិកានោះបាក់បែកខ្ទេចអស់។

ផ្ទុយទៅវិញប្រសិនបើនាឡិកាបុរាណនោះត្រូវបានចោរលួចទៅបាត់ គេចាត់ទុកថាអាចមានលទ្ធភាពក្នុងការអនុវត្ត ព្រោះតែនាឡិកានោះអាចនឹងត្រូវបានគេរកឃើញ ហើយប្រគល់មកវិញ តែតាមសុភវិនិច្ឆ័យ គឺអលទ្ធភាពនៅក្នុងការអនុវត្តបាត់ទៅហើយ ដែលនេះហៅថា អលទ្ធភាពក្នុងការអនុវត្តតាមលក្ខណៈសង្គម។[34]

ប្រសិនបើករណីនាឡិកាបុរាណនោះត្រូវដឹកជញ្ជូនមកតាមកប៉ាល់។ ហើយកប៉ាល់របស់សហគ្រាសដឹកជញ្ជូនដែលដឹកឥវ៉ាន់របស់កញ្ញា ដាវី នោះ បានលិចទៅជាមួយនឹងឥវ៉ាន់រួមមាននាឡិកាបុរាណលោក វឌ្ឍា ផងនោះ ការជួយស្រោចស្រង់កប៉ាល់នេះមានលទ្ធភាពតាមលក្ខណៈរូបសាស្ត្រ ប៉ុន្តែវាត្រូវការចំណាយប្រាក់យ៉ាងច្រើនលើសលប់។ ហេតុដូច្នេះហើយ គេអាចសន្និដ្ឋានបានថាជាអលទ្ធភាពក្នុងការអនុវត្តតាមទស្សនៈនៃសេដ្ឋកិច្ច។[35]

### ២.១.៤.ការបាត់បង់ទំនុកចិត្តរវាងគ្នា

ការបាត់បង់ទំនុកចិត្តរវាងភាគី កើតឡើងនៅពេលដែលការបំពានកិច្ចសន្យាមានភាពហួសហេតុពេកដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចបាននាពេលអនាគត។[36]

ក៏ប៉ុន្តែការរំលាយកិច្ចសន្យាប្រភេទនេះ គឺពុំមានភាពច្បាស់លាស់ទេ។ ដោយសារតែទំនាក់ទំនងនៃទំនុកចិត្ត នៅក្នុងកិច្ចសន្យានីមួយៗមានភាពខុសគ្នា ដែលយើងមិនអាចវាស់ពីទំហំ ឬកម្រិតនៃជំនឿទុកចិត្តបាន គឺមានតែអាស្រ័យទៅលើស្ថានការណ៍ ឬភាពជាក់ស្តែងទៅលើកិច្ចសន្យានីមួយៗនោះ ហើយការរំលាយកិច្ចសន្យាប្រភេទនេះ គឺច្រើនតែឃើញមានទៅលើភតិសន្យា រវាងភតិកៈ និងភតិបតី។

### ២.១.៥.ការបំពានកិច្ចសន្យាធ្ងន់ធ្ងរផ្សេងទៀត

កូនបំណុលត្រូវចាត់ទុកថាបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផងដែរ ប្រសិនបើការបំពាននោះបានធ្វើឱ្យប៉ះពាល់ទៅលើម្ចាស់បំណុលយ៉ាងធ្ងន់ធ្ងរ បើទោះបីជាការបំពាននោះមិនមានចែងជាក់លាក់នៅក្នុងច្បាប់ក៏ពិតមែន

[33] មាត្រា ៣៩២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។
[34] សេចក្តីពន្យល់ពីក្រមរដ្ឋប្បវេណី, ទំព័រទី១៥៩។
[35] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រា ៣០២, ទំព័រទី ១០៦។
[36] មាត្រា ៤០៨ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី។

តែតុលាការអាចទទួលស្គាល់ថាជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ដោយមើលទៅលើស្ថានភាពជាក់ស្តែង។[37] ចំណុចស្តីពីអំពីការបំពានកិច្ចសន្យាធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានផ្តល់សិទ្ធិឱ្យបកស្រាយតាមយុត្តិសាស្ត្រនាពេលអនាគត។

ឧទាហរណ៍៖ លោក វដ្ឋា បានទិញអង្ករចំនួន ១០ តោន ពីកញ្ញា ដាវី។ ដោយលោក វដ្ឋា បានឱ្យកញ្ញា ដាវី រៀបចំជូនលោកឱ្យបានមុនម៉ោង ៧ព្រឹក នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដើម្បីធ្វើការនាំចេញដាក់កប៉ាល់ទៅក្រៅប្រទេស។ តែដល់កាលបរិច្ឆេទដែលកំណត់ កញ្ញា ដាវី នៅមិនទាន់បានរៀបចំគ្រប់ចំនួននៅឡើយ។ លោក វដ្ឋា ក៏បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ដោយសារតែផុតម៉ោងសម្រាប់ការរៀបចំដាក់កប៉ាល់។

តាមរយៈឧទាហរណ៍ខាងលើ យើងសង្កេតឃើញថា បើទោះបីជាកញ្ញា ដាវី បានរៀបចំមួយភាគធំរួចរាល់ក៏ពិតមែន តែលោក វដ្ឋា ត្រូវការពេលវេលាសម្រាប់រៀបចំដាក់លើកប៉ាល់ទៀត។ ដូច្នេះករណីនេះ អាចចាត់ទុកជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ដែលអាចឱ្យភាគីទទួលការបំពាន មានសិទ្ធិរំលាយកិច្ចសន្យាបានភ្លាមៗ។

## ២.២.ការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិពិសេស

### ២.២.១.កម្មវត្ថុនៃកិច្ចសន្យាលក់ទិញជារបស់អ្នកដទៃ

ប្រសិនបើអ្នកលក់មិនបានដឹងថាសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជារបស់ខ្លួន នៅពេលដែលធ្វើកិច្ចសន្យាទេ ហើយគាត់មិនអាចទទួលយកសិទ្ធិនោះ ដើម្បីផ្ទេរទៅឱ្យអ្នកទិញបាន អ្នកលក់ គឺគាត់អាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងសំណងនៃការខូចខាត។[38] នៅក្នុងករណីនេះ ប្រសិនបើអ្នកលក់ គាត់សុចរិតដោយមិនបានដឹងថាគាត់គ្មានសិទ្ធិទៅលើកម្មវត្ថុនោះ ច្បាប់បានអនុញ្ញាតឱ្យគាត់អាចធ្វើការរំលាយកិច្ចសន្យានោះបាន តែយ៉ាងណាក៏គាត់ត្រូវតែសងសំណងនៃការខូចខាតមកឱ្យអ្នកទិញ (អ្នកទិញសុចរិត)ផងដែរ ព្រោះដើម្បីតែរក្សាស្ថេរភាពនៃសុវត្ថិភាពខាងជំនួញ និងការពារទៅលើអ្នកទិញដែលគាត់គ្មានកំហុសនោះផង។ ផ្ទុយទៅវិញបើអ្នកទិញទុច្ចរិត គឺគាត់បានដឹងហើយថាអ្នកលក់គ្មានសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទេ នោះអ្នកលក់ដែលសុចរិតអាចធ្វើការរំលាយកិច្ចសន្យានោះបាន ដោយមិនជាប់កាតព្វកិច្ចសងសំណងនៃការខូចខាតទៅឱ្យអ្នកទិញនោះឡើយ។[39]

ឧទាហរណ៍៖ អ្នកលក់មានការយល់ច្រឡំថា វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែតាមការពិតវត្ថុនោះ ជារបស់អ្នកដទៃ។

[37] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ, គន្លឹះទី៤, ទំព័រទី១២៥។

[38] មាត្រា ៥៣២ នៃក្រមរដ្ឋប្បវេណី។

[39] មាត្រា ៥៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

## ករណីសិក្សា

លោក ក បានព្រមព្រៀងលក់ដីមួយកន្លែងដែលគាត់បានកាន់កាប់ដោយសុចរិតបានរយៈពេល០៥ឆ្នាំមក ហើយ ដោយគាត់យល់ថា គាត់អាចធ្វើជាកម្មសិទ្ធិករលើដីនោះបានតាមរយៈលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ (ចំពោះជនសុចរិត) ដូចនេះគាត់បានលក់ដីមួយកន្លែងនោះទៅឱ្យ លោក ខ ។ ករណីនេះម្ចាស់កម្មសិទ្ធិពិត ប្រាកដ កញ្ញា ង បានដឹង ព្រមទាំងបានធ្វើការទាមទារតាមផ្លូវតុលាការយកបានដីគាត់មកវិញ។ ដូចនេះលោក ក មិនអាចធ្វើលទ្ធកម្មទៅលើកម្មវត្ថុនោះបានដើម្បីផ្ទេរ ទៅឱ្យលោក ខ ឡើយ។

ក.តើលោក ក អាចធ្វើការរំលាយកិច្ចសន្យានោះបានដែរ ឬទេ?

ខ.តើលោក ខ អាចមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាលក់ទិញនោះបានដែរទេ?

គ.តើលោក ខ អាចធ្វើការទាមទារសំណងនៃការខូចខាតបាន ឬអត់?

## សេចក្តីសន្និដ្ឋាន និងមូលហេតុសំអាង

ក.លោក **ក** អាចធ្វើការរំលាយកិច្ចសន្យាបាន ដោយផ្អែកលើស្មារតីនៃមាត្រា **៥៣២** កថាខណ្ឌទី១។ មូលហេតុដោយសារតែលោក **ក** គាត់យល់ច្រឡំថា ការកាន់កាប់លើអចលនវត្ថុមួយនោះរយៈ០៥ឆ្នាំ អាចឱ្យគាត់មានសិទ្ធិពេញលេញឡើងទៅជាម្ចាស់កម្មសិទ្ធិករ តាមលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ ដែលផ្ទុយទៅវិញតាមក្រមរដ្ឋប្បវេណី មាត្រា **១៦២** កថាខណ្ឌទី២ តម្រូវឱ្យលោក **ក** បើគាត់ជាអ្នកកាន់កាប់ដោយសុចរិតអាចធ្វើលទ្ធកម្មសិទ្ធិលើអចលនវត្ថុបាននៅពេលដែលគាត់បានកាន់កាប់បានរយៈពេល១០ឆ្នាំ។ នៅពេលដែលគាត់កាន់កាប់ដីនោះបាន ០៥ ឆ្នាំ ត្រូវបានម្ចាស់កម្មសិទ្ធិករ កញ្ញា **ង** ទាមទារដីនោះមកវិញ ទើបគាត់ (លោក **ក**) មិនអាចធ្វើការអនុវត្តកាតព្វកិច្ចផ្ទេរសិទ្ធិលើទ្រព្យនោះទៅឱ្យ លោក **ខ**។

ដូច្នេះលោក **ក** ជាជនសុចរិតដែលច្បាប់អនុញ្ញាតឱ្យគាត់អាចធ្វើការរំលាយកិច្ចសន្យាលក់ទិញនោះបានដើម្បីរួចផុតពីករណីយកិច្ចក្នុងការផ្ទេរកម្មសិទ្ធិ។

ខ.យោងតាមមាត្រា ៥៣១ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នាំឱ្យលោក **ខ** ដែលជាអ្នកទិញដីនោះ អាចធ្វើការរំលាយកិច្ចសន្យាបាន ដោយសារតែអ្នកលក់មិនអាចផ្ទេរសិទ្ធិដែលកម្មវត្ថុនៃការលក់ទិញឱ្យគាត់។ ជាមួយគ្នានេះផងដែរ បញ្ញត្តិនេះមិនបានបែងចែកថា លោក **ខ** បានដឹង ឬមិនបានដឹងពីភាពគ្មានសិទ្ធិរបស់លោក **ក** ទៅលើដីមួយកន្លែងនោះទេ ដូច្នេះបើទោះបីជាលោក **ខ** ទុច្ចរិតក៏គាត់នៅតែអាចធ្វើការរំលាយកិច្ចសន្យាបានដែរ។

គ.ផ្អែកលើអង្គហេតុខាងលើនេះ គឺគេមិនបានបញ្ជាក់ច្បាស់ថា លោក **ខ** ជាជនដែលសុចរិត ឬទុច្ចរិតនោះទេ ដូចនេះយើងអាចធ្វើការបែងចែក៖

- ករណីដែលលោក **ខ** ជាជនសុចរិត៖ ប្រសិនបើលោក **ខ** ជាជនសុចរិត ដែលគាត់មិនបានដឹងថាលោក **ក** គ្មានសិទ្ធិកម្មសិទ្ធិទៅលើកម្មវត្ថុ(ដី) ដែលគាត់បានទិញ នៅពេលបង្កើតកិច្ចសន្យានោះទេ គាត់អាចធ្វើការទាមទារសំណងនៃការខូចខាតពីលោក **ក** បាន តាមរយៈមាត្រា ៥៣១ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

- ករណីដែលលោក **ខ** ជាជនទុច្ចរិតៈ ប្រសិនបើលោក **ខ** គាត់បានដឹងមុនហើយថា លោក **ក** ប្រាកដជាគ្មានសិទ្ធិលើដីនោះទេ ដោយសារតែគាត់ដឹងពីលក្ខខណ្ឌដែលអាចលោក **ក** ធ្វើជាកម្មសិទ្ធិករតាមអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិអចលនវត្ថុចំពោះជនសុចរិត ទាល់តែ១០ឆ្នាំ។ ដូចនេះ គាត់អាចនឹងគ្មានសិទ្ធិទាមទារសំណងនៃការខូចខាតបាននោះទេ យោងលើមាត្រា ៥៣១ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

**២.២.២.ករណីដែលសិទ្ធិមួយភាគនៅក្នុងកិច្ចសន្យាលក់ទិញជារបស់អ្នកដទៃ**

នៅពេលដែលសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃ ហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះ ដើម្បីធ្វើការផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចទាមទារឱ្យបន្ថយនូវតម្លៃ តាមសមាមាត្រនៃភាគនោះបាន។[40] ក្នុងករណីនេះ គឺជាការមិនអនុវត្តកាតព្វកិច្ចមួយភាគរបស់អ្នកលក់ ដែលយើងអាចយកបញ្ញត្តិនៃមាត្រា ៥៣១ មកអនុវត្តបាន។ ម្យ៉ាងទៀតករណីនេះមិនមែនជាការមិនអនុវត្តកាតព្វកិច្ចទាំងស្រុងទេ ប្រសិនបើទទួលស្គាល់នូវការរំលាយកិច្ចសន្យាទាំងមូលដោយស្វ័យប្រវត្តិវាអាចប៉ះពាល់ខ្លាំងទៅដល់ភាគីក្នុងកិច្ចសន្យា។ ដូចនេះទើបមាត្រានេះអាចអនុញ្ញាតឱ្យអ្នកទិញអាចទាមទារឱ្យបន្ថយតម្លៃនូវថ្លៃលក់ទិញ រហូតដល់តម្លៃនៃភាគីដែលត្រូវបានផ្ទេរទៅអ្នកទិញនោះមានសុពលភាព(តាមសមាមាត្រ)។

ឧទាហរណ៍៖ លោក **ក** បានលក់ដីមួយកន្លែងដែលជាកម្មសិទ្ធិអវិភាគស្មើគ្នារវាងលោក **ខ** ឱ្យទៅកញ្ញា **ង**។ ហើយលោក **ក** បានប្រាប់ទៅកញ្ញា **ង** ថាគាត់អាចចរចារទិញដីដែលជាកម្មសិទ្ធិរបស់លោក **ខ** បានប្រសិនបើកញ្ញា **ង** ព្រមទិញដីពីគាត់ក្នុងតម្លៃ ១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) សំរាប់ទំហំដីសរុបរវាងដីលោក **ក** និងលោក **ខ** ចំនួន ៥០០០ (ប្រាំពាន់) ម៉ែត្រការ៉េ។ លុះនៅពេលដែលលោក **ក** មិនអាចចរចារទិញដីរបស់លោក **ខ** បានទេ កញ្ញា **ង** អាចទាមទារឱ្យលោក **ក** ធ្វើការបន្ថយថ្លៃដី ដែលនៅសល់តែចំណែករបស់គាត់ (លោក **ក**) គឺនៅសល់តែ ៥០០០$ (ប្រាំពាន់ដុល្លារអាមេរិក) សំរាប់ទំហំដីរបស់លោក **ក** ចំនួន ២៥០០ (ពីរពាន់ប្រាំរយ) ម៉ែត្រការ៉េ។

ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ញត្តិនៃមាត្រា៥៣៣ កថាខណ្ឌទី២ នៅតែបើកសិទ្ធិឱ្យអ្នកទិញអាចធ្វើការរំលាយកិច្ចសន្យាលក់ទិញនោះបាន ប្រសិនបើនៅពេលធ្វើកិច្ចសន្យាអ្នកទិញគាត់មិនបានដឹងថា ភាគខ្វះនោះមិនមែនជារបស់អ្នកលក់ទេ ឯអ្នកលក់ក៏គាត់អាចនឹងទទួលស្គាល់ដែរថាអ្នកទិញនឹងមិនទិញភាគដែលនៅសល់តែប៉ុណ្ណោះទេ (ភាគលក់) ព្រោះគោលបំណងនៃការបង្កើតកិច្ចសន្យាមិនបានសម្រេច។ ភ្ជាប់ជាមួយគ្នានេះដែរ ប្រសិនបើអ្នកទិញសុចរិត ដោយសារគាត់មិនបានដឹងថាសិទ្ធិមួយភាគនោះជារបស់អ្នកលក់ពេលដែលបង្កើតកិច្ចសន្យា គាត់អាចទាមទារសំណងនៃការខូចខាតបាន។[41]

[40] មាត្រា៥៣៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[41] មាត្រា ៥៣៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍៖ ចំពោះឧទាហរណ៍ខាងលើ ប្រសិនបើនៅពេលទិញដីនោះ កញ្ញា **ង** មិនបានដឹងទេថាដីនោះជាកម្មសិទ្ធិអវិភាគរវាងលោក **ក** និងលោក **ខ**។ ហើយគាត់ត្រូវការទិញដីដែលមានទំហំចាប់ពី៥០០០ (ប្រាំពាន់ម៉ែត្រការ៉េ)ឡើងទៀត ដូច្នេះដីជាកម្មសិទ្ធិរបស់លោក **ក** ម្នាក់ឯងមិនអាចសម្រេចតាមគោលបំណងនៃការបង្កើតកិច្ចសន្យា។ កញ្ញា **ង** អាចធ្វើការរំលាយកិច្ចសន្យានេះបាន ព្រមទាំងអាចទាមទារសំណងនៃការខូចខាតជាមួយគ្នាផងដែរ។

+ អំឡុងពេលអនុវត្តសិទ្ធិ

ចំពោះសិទ្ធិរបស់អ្នកទិញក្នុងការសុំបន្ថយថ្លៃលក់ទិញ សិទ្ធិរំលាយកិច្ចសន្យាដោយសារតែសិទ្ធិមួយភាគជារបស់អ្នកដទៃ និងសិទ្ធិទាមទារសំណងនៃការខូចខាតដែលកើតឡើង តាមបញ្ញត្តិមាត្រា ៥៣៣ ត្រូវធ្វើការអនុវត្តសិទ្ធិទាំងនេះក្នុងអំឡុងពេល ០១(មួយ) ឆ្នាំ រាប់ចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ក្នុងករណីដែលនៅពេលធ្វើកិច្ចសន្យាគាត់មិនបានដឹងថាសិទ្ធិមួយភាគមិនមែនជារបស់អ្នកលក់ទេ ឬគិតចាប់ពីពេលធ្វើកិច្ចសន្យានៅពេលដែលអ្នកទិញបានដឹងថាសិទ្ធិមួយភាគនោះមិនមែនជារបស់អ្នកលក់។[42]

### ២.២.៣.ករណីកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមានវិការៈ

#### ក.គោលគំនិតអំពីវិការៈ

ជាគោលការណ៍អ្នកលក់ត្រូវតែប្រគល់វត្ថុដែលគ្មានវិការៈទៅឱ្យអ្នកទិញ។[43] មានន័យថាទោះបីជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនោះជាវត្ថុដែលកំណត់ជាក់លាក់ ឬមិនបានកំណត់ជាក់លាក់ក៏ដោយ ក៏អ្នកលក់ត្រូវមានករណីយកិច្ចក្នុងការប្រគល់នូវវត្ថុដែលគ្មានវិការៈទៅឱ្យអ្នកទិញដែរ។

លើកលែងតែគូភាគីបានកំណត់ផ្សេងក្នុងកិច្ចសន្យា វត្ថុដែលបានប្រគល់ទៅអ្នកទិញអាចចាត់ទុកថាមានវិការៈដូចខាងក្រោម៖[44]

- វត្ថុនោះមានភាពមិនសមស្របនឹងចំនួន គុណភាព និងលក្ខណៈដែលបានកំណត់នៅក្នុងកិច្ចសន្យា
- វត្ថុនោះមានភាពផ្សេងពីគំរូដែលអ្នកលក់បានបង្ហាញឱ្យអ្នកទិញមើលពីចំនួន គុណភាព និងលក្ខណៈ
- វត្ថុនោះមិនស្របនឹងវិធីប្រើដែលអ្នកលក់បានបង្ហាញ ដោយជាក់លាក់ ឬដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា[45]
- វត្ថុនោះមិនស្របនឹងវិធីប្រើធម្មតានៃប្រភេទដូចគ្នា

[42] មាត្រា ៥៣៣ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី។
[43] មាត្រា ៥៣៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។
[44] មាត្រា៥៣៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។
[45] សេចក្តីកំណត់ចំពោះមាត្រានីមួយនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ទំព័រទី ១០៣។

- វត្ថុនោះមិនត្រូវបានខ្ចប់តាមវិធីធម្មតានៃការខ្ចប់វត្ថុប្រភេទដូចគ្នា ឬតាមវិធីសមរម្យដើម្បីការពារវត្ថុនោះ។

ក្នុងករណីខាងលើនេះ អ្នកទិញគាត់ត្រូវទទួលបាននូវការធានាពីអ្នកលក់ចំពោះវត្ថុដែលទិញមានវិការៈ ព្រមទាំងអាចទាមទារនូវសំណងនៃការខូចខាតបានផងដែរ ប្រសិនបើអ្នកលក់មានកំហុសចំពោះការខូចខាតនោះ តាមមាត្រា ៣៩៨ ដែលចែងពីលក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត ដែលមកពីការមិនអនុវត្តកាតព្វកិច្ច។

**ខ.ពេលវេលានៃការកើតឡើងវិការៈ**

នៅពេលហានិភ័យត្រូវបានផ្ទេរទៅអ្នកទិញរួចរាល់ បើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនោះមានវិការៈ ទោះបីជាវិការៈទើបតែបានដឹងច្បាស់នៅក្រោយពេលដែលហានិភ័យត្រូវបានផ្ទេរក៏ដោយ ក៏អ្នកលក់ត្រូវទទួលខុសត្រូវការធានាវិការៈ ឬអាចហៅថាជាសិទ្ធិទាមទារឱ្យអនុវត្តពេញលេញ៖[46]

- ប្រគល់វត្ថុជំនួស (មាត្រា៥៤២ កថាខណ្ឌទី២)
- ជួសជុលវិការៈ (មាត្រា ៥៤២ កថាខណ្ឌទី៣)
- ការរំលាយកិច្ចសន្យា (មាត្រា៥៤៣) ឬ ការបន្ថយនូវតម្លៃ (មាត្រា ៥៤៤)

ប៉ុន្តែទោះបីជាវិការៈកើតឡើងនៅក្រោយពេលដែលបានកំណត់ខាងលើ (ពេលដែលហានិភ័យត្រូវផ្ទេរទៅអ្នកទិញ) ប្រសិនបើវិការៈនោះបានកើតឡើងដោយសារតែអ្នកលក់ធ្វើខុសនឹងករណីយកិច្ចរបស់ខ្លួន ក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈករណីខាងលើដែរ។[47]

ឧទាហរណ៍៖ លោក **ក** បានទិញអង្ករចំនួនមួយតោនពីលោក **ខ** ដោយប្រាប់ថានឹងទៅទទួលយកនៅរយៈពេល២ថ្ងៃក្រោយ។ លុះដល់រយៈពេលកំណត់ត្រូវមកយកអង្ករនោះ លោក **ខ** មិនឃើញលោក **ក** មកទទួល ក៏បានតេទូរស័ព្ទទៅដាស់តឿនឱ្យមកទទួល។ ក្រោយមក២ថ្ងៃទៀត ក៏នៅតែមិនឃើញលោក **ក** មកទទួលដដែល គាប់ជួនមេឃបានភ្លៀងធ្វើឱ្យសើមអង្ករនោះខូចចំនួន ៣០% (សាមសិបភាគរយ)។ ករណីនេះ លោក **ខ** នៅតែជាប់កាតព្វកិច្ចក្នុងការធានាវិការៈលើវត្ថុដដែល ថ្វីត្បិតតែគាត់បានស្នើសុំដាស់តឿនឱ្យលោក **ក** មកយកអង្ករដែលជាការទទួលស្គាល់ថា ការផ្ទេរបន្ទុកហានិភ័យត្រូវបានផ្ទេរទៅលោក **ក** តាមបញ្ញត្តិនៃមាត្រា៤១៦ កថាខណ្ឌទី២ ក៏ដោយ តែវិការៈនេះកើតឡើងដោយលោក **ខ** បានបំពានកាតព្វកិច្ចរបស់អ្នកលក់ក្នុងការថែរក្សាទុកដាក់វត្ថុនោះរហូតដល់ពេលប្រគល់។

[46] មាត្រា ៥៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។
[47] មាត្រា ៥៤០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

### គ.ខ្លឹមសារនៃការទទួលខុសត្រូវ

ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមានវិការៈ ភាគីដែលខាតបង់ប្រយោជន៍ដោយសារវិការៈនៃកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនោះ មានសិទ្ធិដូចជា សិទ្ធិទាមទារឱ្យប្រគល់វត្ថុជំនួស សិទ្ធិទាមទារឱ្យជួសជុល សិទ្ធិទាមទារឱ្យបន្ថយថ្លៃ និងសិទ្ធិទាមទារសំណងនៃការខូចខាត ហើយបញ្ញត្តិនៃក្រមរដ្ឋប្បវេណី មិនបានរារាំងដល់ភាគីដែលទទួលរងការបំពានឱ្យប្រើប្រាស់សិទ្ធិរំលាយកិច្ចសន្យានោះទេ ប្រសិនបើគោលបំណងនៃកិច្ចសន្យាលក់ទិញមិនអាចសម្រេចបាន ដោយសារតែកម្មវត្ថុនៃកិច្ចសន្យាមានវិការៈ។[48]

+ ករណីយកិច្ចប្រគល់វត្ថុជំនួស

ពេលដែលកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមានវិការៈ អ្នកលក់ត្រូវមានករណីយកិច្ចក្នុងការប្រគល់វត្ថុជំនួសដែលគ្មានវិការៈទៅឱ្យអ្នកទិញសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ។ ប៉ុន្តែប្រសិនបើការរៀបចំវត្ថុដែលមានប្រភេទដូចគ្នា នឹងធ្វើឱ្យបង្កើនបន្ទុកមិនសមរម្យហួសហេតុដល់អ្នកលក់ នោះអ្នកលក់នឹងមិនជាប់ករណីយកិច្ចប្រគល់វត្ថុជំនួសឡើយ។ [49]ផ្ទុយទៅវិញអ្នកលក់នឹងជាប់នូវករណីយកិច្ចក្នុងការសងសំណងនៃការខូចខាតដល់អ្នកទិញតាមមាត្រា ៤៤៥។

ឧទាហរណ៍៖ ករណីដែលលោក **ក** បានទិញរថយន្តមួយគ្រឿងពីលោក **ខ** ហើយរថយន្តនោះជាប្រភេទរថយន្តដែលផលិតតែ២គ្រឿងប៉ុណ្ណោះលើពិភពលោក។ ហេតុនេះ ហើយប្រសិនបើឱ្យលោក **ខ** ទៅស្វែងរករថយន្តនេះប្រភេទតែមួយមកជំនួស វានឹងធ្វើឱ្យប៉ះពាល់ទៅលើការចំណាយហួសហេតុរបស់លោក **ខ** ដែលច្បាប់បានកំណត់ឱ្យលោក **ខ** មានករណីយកិច្ចត្រឹមការសងសំណងនៃការខូចខាតប៉ុណ្ណោះ។

+ ករណីយកិច្ចជួសជុល

ជាគោលការណ៍ នៅពេលដែលអ្នកលក់បានធ្វើការប្រគល់វត្ថុដែលមានវិការៈទៅឱ្យអ្នកទិញមុនពេលកំណត់ត្រូវប្រគល់ អ្នកលក់នោះអាចធ្វើការជួសជុលវិការៈរហូតដល់ពេលកំណត់បាន លុះត្រាតែមិនបណ្ដាលឱ្យខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ករណីនេះអ្នកទិញអាចធ្វើការទាមទារសំណងនៃការខូចខាតបាន។[50] ប៉ុន្តែនៅក្រោយពេលកំណត់ត្រូវប្រគល់ អ្នកលក់ក៏នៅតែអាចធ្វើការជួសជុលវិការៈបានដោយចេញចំណាយខ្លួនឯង និងមានបណ្ដាលឱ្យខូចប្រយោជន៍ហួសហេតុដល់អ្នកទិញ ចំណែកករណីអ្នកទិញ គាត់អាចអនុវត្តសិទ្ធិរំលាយ និងទាមទារសំណងនៃការខូចខាតបាន។[51]

+ ករណីយកិច្ចបន្ថយថ្លៃលក់

[48] មាត្រា ៥៤៣ នៃក្រមរដ្ឋប្បវេណី។
[49] មាត្រា ៥៤២ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។
[50] មាត្រា៥៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។
[51] មាត្រា ៥៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

ក្នុងករណីដែលវត្ថុត្រូវប្រគល់មានវិការៈ អ្នកទិញដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរអាចទាមទារឱ្យបន្ថយថ្លៃលក់បានទៅតាមសមាមាត្រនៃភាពខុសគ្នារវាងតម្លៃនៃវត្ថុគ្មានវិការៈ និងតម្លៃនៃវត្ថុដែលត្រូវបានប្រគល់។[52]

ឧទាហរណ៍៖ លោក ក បានទិញអង្ករពីកញ្ញា ង ចំនួន១០គីឡូក្រាម ក្នុងតម្លៃ១០០$ (មួយរយដុល្លារអាមេរិក)។ ប៉ុន្តែក្នុងចំណោមអង្ករទម្ងន់១០គីឡូក្រាមនោះ មានអង្ករចំនួន០៣គីឡូក្រាមបានខូចទៅហើយពេលប្រគល់។ ក្នុងករណីនេះ លោក ក អាចទាមទារឱ្យកញ្ញា ង សងប្រាក់ ៣០$ (សាមសិបដុល្លារអាមេរិក) មកវិញបានប្រសិនបើគាត់បានបង់ប្រាក់រួចហើយ តែបើគាត់មិនទាន់បានបង់ប្រាក់ទេ គាត់អាចទាមទារឱ្យបន្ថយថ្លៃសល់ចំនួន ៧០$ (ចិតសិបដុល្លារអាមេរិក)។ លើកលែងតែកញ្ញា ង បានធ្វើការបានធ្វើការប្រគល់អង្ករជំនួសចំនួន០៣គីឡូក្រាមវិញ តាមមាត្រា ៥៤២ នាំឱ្យថ្លៃលក់នោះមិនត្រូវបន្ថយឡើយ។ ហើយលោក ក ក៏មិនអាចធ្វើការប្រកែកមិនឱ្យអ្នកលក់ប្រគល់វត្ថុជំនួសដោយគ្មានហេតុផលត្រឹមត្រូវ និងមិនអាចទាមទារឱ្យបន្ថយថ្លៃទៀតឡើយ។[53]

+ ករណីយកិច្ចសងសំណងការខូចខាត

នៅពេលដែលវត្ថុបានប្រគល់មានវិការៈ អ្នកលក់ត្រូវមានករណីយកិច្ចសងសំណងការខូចខាត។ អ្នកទិញអាច ទាមទារសំណងនៃការខូចខាត ដោយស្របតាមបញ្ញត្តិមាត្រា ៣៩៨ ដល់មាត្រា ៤០៦ (ដែលនិយាយពីសំណងការខូចខាត) ឬមួយអ្នកទិញអាចទាមទារដោយឯករាជ្យពី ឬជាមួយនឹងការសង្គ្រោះណាមួយ ដែលមានបញ្ញត្តិពីមាត្រា៥៤២ ដល់មាត្រា ៥៤៤។ ចំពោះមាត្រា ៥៤៥ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ) មិនបានបញ្ញត្តិឱ្យច្បាស់ទៅលើអ្នកទិញដែលសុចរិត ឬទុច្ចរិត ឬមានកំហុស ឬគ្មានកំហុសឡើយសំរាប់ការទាមទារសំណងការខូចខាត ប៉ុន្តែទៅលើទិដ្ឋភាពជាក់ស្តែង បើអ្នកទិញគាត់ទុច្ចរិត(បានដឹងមុន) ឬមានកំហុសធ្ងន់ធ្ងរទៅលើវត្ថុដែលមានវិការៈនោះ គេចាត់ទុកថាអ្នកទិញនោះគាត់យល់ព្រមទទួលយកកម្មវត្ថុនោះដែលជាការអនុវត្តកាតព្វកិច្ច និងបំពេញគោលបំណងនៃកិច្ចសន្យា។[54]

ម្យ៉ាងទៀតគូភាគីនៃកិច្ចសន្យាលក់ទិញអាចព្រមព្រៀងគ្នាជាមុនក្នុងការអនុគ្រោះ ឬកម្រិតនូវការទទួលខុសករណីមានវិការៈបាន តែអ្នកលក់នោះនឹងមិនត្រូវរួចផុតពីការទទួលខុសត្រូវការធានាទេ ប្រសិនបើករណីដែលអ្នកលក់បានដឹង តែមិនបានប្រាប់។[55] រីឯចំពោះអ្នកទិញវិញ ករណីដែលគាត់បានដឹង ឬមិនបានដឹង

[52] មាត្រា ៥៤៤ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[53] មាត្រា ៥៤៤ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[54] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ទំព័រទី ១០។

[55] មាត្រា៥៤៨ នៃក្រមរដ្ឋប្បវេណី។

ដោយសារកំហុសធ្ងន់ធ្ងររបស់ខ្លួនពីវិការៈនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលធ្វើកិច្ចសន្យាលក់ទិញ អ្នកលក់មិនចាំបាច់ទទួលខុសត្រូវកាធានាវិការៈនោះទេ។[56]

+ សិទ្ធិទាមទាររំលាយកិច្ចសន្យាលក់ទិញ ករណីកម្មវត្ថុមានវិការៈ

ប្រសិនបើអ្នកទិញគាត់មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ដោយសារតែកម្មវត្ថុត្រូវប្រគល់ជូនគាត់មានវិការៈ នោះគាត់អាចរំលាយកិច្ចសន្យានោះបាន (អ្នកទិញដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ)។[57]

ឧទាហរណ៍៖ ក្នុងករណីការលក់ទិញគ្រឿងចក្រ (ត្រាក់ទ័រ) ប្រសិនបើគ្រឿងចក្រនោះមានកម្លាំងខ្សោយខុសធម្មតាជាងលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យា ហើយអ្នកទិញមិនអាចប្រើប្រាស់តាមបំណងខ្លួនបានទេ នោះអ្នកទិញអាចរំលាយកិច្ចសន្យានេះបាន ដោយមិនចាំបាច់ចំណាយពេលវេលាវែងឆ្ងាយទៅលើការជួសជុលនោះទេ ដោយអាចទៅទិញគ្រឿងចក្រពីអ្នកផ្សេងដែលមានគុណភាពល្អវិញបាន។

សិទ្ធិដែលពាក់ព័ន្ធនឹងការទាមទារការធានាពេលមានវិការៈ ឬសិទ្ធិដែលអ្នកទិញមានក្នុងការទាមទារឱ្យអនុវត្តពេញលេញ (ការទាមទារឱ្យប្រគល់វត្ថុជំនួស និងការជួសជុលវិការៈ សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់) ត្រូវអនុវត្តនៅក្នុងអំឡុងពេល ០១ឆ្នាំ ដោយរាប់ចាប់ពីពេលដែលអ្នកទិញបានដឹង ឬគួរដឹងពីវិការៈ និងការខូចខាត។

### ២.២.៤.ករណីសិទ្ធិរបស់អ្នកលក់ក្នុងការជួសជុល

ជាគោលការណ៍ នៅពេលដែលអ្នកលក់បានធ្វើការប្រគល់វត្ថុដែលមានវិការៈទៅឱ្យអ្នកទិញមុនពេលកំណត់ត្រូវប្រគល់ អ្នកលក់នោះអាចធ្វើការជួសជុលវិការៈរហូតដល់ពេលកំណត់បាន លុះត្រាតែមិនបណ្តាលឱ្យខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ករណីនេះអ្នកទិញអាចធ្វើការទាមទារសំណងនៃការខូចខាតបាន។[58] ប៉ុន្តែនៅក្រោយពេលកំណត់ត្រូវប្រគល់ អ្នកលក់ក៏នៅតែអាចធ្វើការជួសជុលវិការៈបានដដែលដោយចេញចំណាយខ្លួនឯង និងមានបណ្តាលឱ្យខូចប្រយោជន៍ហួសហេតុដល់អ្នកទិញ ចំណែកករណីនេះមិនរារាំងអ្នកទិញ មិនឱ្យអនុវត្តសិទ្ធិរំលាយ និងទាមទារសំណងនៃការខូចខាតបាន។[59]

ឧទាហរណ៍៖ កញ្ញា ង បានធ្វើការកក់ប្រាក់ទិញទូរស័ព្ទដៃមួយគ្រឿងម៉ាក A ក្នុងការធ្វើជាកាដូប្រគល់ជូនជីដូនរបស់គាត់ ជាឳកាសមុនគាត់ត្រឡប់ទៅស្រុកក្រៅវិញ។ ហើយលោក ក ជាអ្នកលក់បានធ្វើការសន្យាថាកន្លះខែទៀត ទូរស័ព្ទនោះនឹងមានចូលស្តុក។ លុះដល់ថ្ងៃកំណត់ គាត់បានទូរស័ព្ទហៅកញ្ញា ង ឱ្យទៅយកទូរស័ព្ទខាងលើ។ ក្រោយពីប្រើបាន០១ថ្ងៃ ទូរស័ព្ទនោះមានបញ្ហាគាំង ទើបកញ្ញា ង ទាមទារឱ្យលោក ក ជួលជុលឱ្យហើយក្នុងរយៈពេល០៣ថ្ងៃទៀត ព្រោះជីដូនគាត់ជិតដល់ថ្ងៃត្រឡប់ទៅស្រុកក្រៅហើយ។ លុះដល់ថ្ងៃកំណត់

---

[56] មាត្រា ៥៤០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី។

[57] មាត្រា ៥៤៣ នៃក្រមរដ្ឋប្បវេណី។

[58] មាត្រា៥៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[59] មាត្រា ៥៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

លោក ក មិនអាចធ្វើការជួសជុលទាន់ពេល កញ្ញា ង អាចអនុវត្តសិទ្ធិរំលាយកិច្ចសន្យាខាងលើ ព្រមទាំងទាមទារនូវសំណងនៃការខូចខាតពីលោក ក បាន។

### ២.២.៥.ករណីអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល

ជាធម្មតាអ្នកទិញត្រូវមានករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ។[60] នៅពេលដែលអ្នកលក់បានប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាមកឱ្យអ្នកទិញ ប៉ុន្តែអ្នកទិញបែរជាបដិសេធក្នុងការទទួលវត្ថុដែលប្រគល់នោះអ្នកទិញក៏ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាងនៅក្នុងការទទួលដែរ។[61] ដូច្នេះប្រសិនបើអ្នកទិញបដិសេធក្នុងការទទួលនូវសំណើផ្តល់ការអនុវត្តកាតព្វកិច្ច ដោយសារកំហុសរបស់អ្នកទិញ ពេលនោះអ្នកលក់អាចទាមទារសំណងនៃការខូចខាត និងអាចរំលាយកិច្ចសន្យានោះបាន ករណីដែលការមិនទទួលយកការអនុវត្តកាតព្វកិច្ចរបស់អ្នកលក់ ត្រូវចាត់ទុកជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។[62]

ប្រសិនបើកម្មវត្ថុដែលជាកម្មវត្ថុត្រូវបានបាត់បង់ ឬខូចខាត ដោយគ្មានកំហុសរបស់អ្នកលក់ អ្នកទិញត្រូវទទួលបន្ទុកហានិភ័យនោះដោយខ្លួនឯង។[63] អ្នកលក់ក៏អាចយកវត្ថុនោះទៅតម្កល់ ឬលក់វត្ថុដែលជាកម្មវត្ថុនោះបាន តាមបញ្ញត្តិនៃមាត្រា ៤៥៧ (ការតម្កល់) និងមាត្រា ៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) ប្រសិនបើនៅពេលដែលគាត់ (អ្នកលក់) បានស្នើផ្តល់នូវការសងរួចហើយ តែអ្នកទិញនៅតែមិនព្រមទទួល។[64]

ឧទាហរណ៍៖ លោក ក បានបញ្ជាទិញអង្ករចំនួន០៣តោន ពីកញ្ញា ង ដោយគាត់បានបង់ប្រាក់គ្រប់ចំនួន តែសុំឱ្យកញ្ញា ង រក្សាទុកនូវអង្កររបស់គាត់រយៈពេល ០១សប្តាហ៍ សិន ព្រោះគាត់ទុកពេលដើម្បីរៀបចំឃ្លាំងសំរាប់យកអង្ករនោះទៅទុក។ លុះដល់ថ្ងៃកំណត់កញ្ញា ង បានស្នើសុំឱ្យលោក ក មកយកអង្ករដែលគាត់បានទិញ យកទៅ ព្រោះតែនាងត្រូវការកន្លែងដាក់អង្ករបន្ថែមចូលឃ្លាំង។ តែលោក ក នៅតែមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយបន្តទុកនៅឃ្លាំងរបស់កញ្ញា ង រហូតដល់០២សប្តាហ៍។ ចូលដល់សប្តាហ៍ទី៣ ឃ្លាំងរបស់កញ្ញា ង ត្រូវបានលិចទឹកដោយសារជំនន់ទឹកភ្លៀងធ្លាក់ជោគជាំ រហូតធ្វើឱ្យអង្ករក្នុងឃ្លាំងទាំងអស់ រួមទាំងអង្ករដែលលោក ក បានទិញ ត្រូវបានខូចខ្ទេចខ្ទី។ ករណីនេះកញ្ញា ង មិនត្រូវជាប់បន្ទុកក្នុងការសងសំណងទៅលើលោក ក ឡើយ។ ព្រោះបន្ទុកហានិភ័យនេះត្រូវបានផ្ទេរទៅគាត់រួចរាល់ហើយ។ ម្យ៉ាងទៀតចំពោះការខូចខាតអង្ករនោះមិនមែនកើតឡើងមកពីការទុកដាក់មិនត្រឹមត្រូវរបស់កញ្ញា ង ទេ (ករណីប្រធានស័ក្តិ)។

[60] មាត្រា ៥៥៤ នៃក្រមរដ្ឋប្បវេណី។

[61] មាត្រា ៥៥៩ នៃក្រមរដ្ឋប្បវេណី។

[62] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ទំព័រទី១២ និង១៣។

[63] មាត្រា ៥៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[64] មាត្រា ៥៥៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

### ២.២.៦.ការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិរំលោះ

កិច្ចសន្យាលក់ទិញពិសេសដោយអនុវត្តសិទ្ធិលោះ បានអនុញ្ញាតឱ្យអ្នកទិញ និងអ្នកលក់ធ្វើការព្រមព្រៀងគ្នាក្នុងការលក់ត្រឡប់នូវវត្ថុណាមួយដែលអ្នកទិញបានទិញ ដោយអនុវត្តក្នុងអំឡុងពេលណាមួយនោះ តែមិនឱ្យលើសពីអំឡុងពេលដែលច្បាប់បានកម្រិត (មាត្រា ៥៦១ អំឡុងពេលនៃការលោះ) អ្នកលក់អាចធ្វើការរំលាយកិច្ចសន្យាលក់ទិញនោះបាន ដោយសងប្រាក់ដែលអ្នកទិញបានបង់ និងសងសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ៥៦៣ (វិធីអនុសិទ្ធិលោះ) មាន៖

- អ្នកលក់ត្រូវបង់ថ្លៃលក់ និងបង់សោហ៊ុយក្នុងការធ្វើកិច្ចសន្យា ក្នុងអំឡុងពេលដែលបានកំណត់ដើម្បីលោះវិញ
- ក្នុងករណីដែលអ្នកទិញ ឬអ្នកទទួលបន្តវត្ថុពីអ្នកទិញបានចេញនូវចំណាយសោហ៊ុយចំពោះវត្ថុដែលជាកម្មវត្ថុ អ្នកលក់ត្រូវសងទៅវិញនូវចំណាយចាំបាច់សម្រាប់គ្រប់គ្រង់ និងថែរក្សាវត្ថុទាំងអស់នោះ ចំណែកចំណាយដែលបង្កើននូវតម្លៃវិញ អ្នកលក់ត្រូវសងនូវសោហ៊ុយដែលអ្នកទិញ ឬអ្នកទទួលវត្ថុពីអ្នកទិញបានចេញ ឬតម្លៃដែលកើតនោះ ទៅតាមការជ្រើសរើសរបស់អ្នកលក់ ក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន។

ឧទាហរណ៍៖ លោក ក បានធ្វើកិច្ចសន្យាលក់ដីស្រែរបស់គាត់ទៅឱ្យលោក ខ ព្រោះតែខ្វះខាតប្រាក់សម្រាប់ឱ្យកូនសិក្សាបន្តនៅមហាវិទ្យាល័យ។ រួចលោក ក បានសន្យាថានៅពេល០២ឆ្នាំទៀតគាត់នឹងខិតខំរកប្រាក់ដើម្បីមករំលោះយកដីរបស់គាត់វិញ ហើយលោក ខ ក៏បានយល់ព្រមក្នុងការទុកដីនោះលក់ទៅឱ្យលោក ក វិញ។ តែកន្លងផុតបាន០៣ខែ លោក ខ បានធ្វើការដាក់ជួលដីនោះទៅឱ្យកញ្ញា ង សម្រាប់រយៈពេល០១ឆ្នាំ។ ក្នុងអំឡុងពេលដែលកញ្ញា ង បានជួលដីពីលោក ខ នាងបានរៀបចំសម្អាតនូវបរិវេណដី ស្មៅ រៀបចំប្រព័ន្ធទឹកលើកប្រឡាយ ដែលមើលទៅដីនោះមានសោភណភាពជាងមុន។ លុះរំលងបានរយៈពេល០១ឆ្នាំក្រោយ ពីការលក់ដីស្រែទៅឱ្យលោក ខ នោះលោក ក បានសន្សំប្រាក់គ្រប់ចំនួនក្នុងការមកទិញលោះដីរបស់គាត់ទៅវិញ ដោយចង់រំលាយកិច្ចសន្យាលក់ទិញមុនចោល។ ដូចនេះលោក ក អាចធ្វើបានដោយចេញនូវសោហ៊ុយសម្រាប់ចំណាយរៀបចំធ្វើកិច្ចសន្យា ព្រមទាំងសងត្រឡប់នូវទឹកប្រាក់ដែលលោក ខ បានទិញពីគាត់។ ម៉្យាងទៀតកញ្ញា ង ដែលជាអ្នកទទួលបន្តវត្ថុពីលោក ខ បានធ្វើការចេញសោហ៊ុយចំណាយទៅលើការរៀបចំដីស្រែរបស់គាត់ឱ្យមានសោភណភាព អាចលក់បានថ្លៃជាងមុននោះ គាត់ត្រូវតែសងត្រឡប់នូវសោហ៊ុយក្នុងការចំណាយដែលធ្វើឱ្យដីគាត់កើនថ្លៃនោះមកវិញផងដែរ។

ចំពោះករណីដែលអ្នកលក់ ជាម្ចាស់កម្មសិទ្ធិអវិភាគចង់ធ្វើការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិលោះ អាចបែងចែកដោយ៖

ចំពោះករណីទី១៖ ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគ បានលក់វត្ថុមដោយមានការសន្យាពិសេសនៃការលោះនោះ ធ្វើឡើងក្នុងកិច្ចសន្យាតែមួយ ហើយមានបុគ្គលម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់បានធ្វើការទាមទារលោះវត្ថុមួយភាគដែលជាកម្មសិទ្ធិរបស់ខ្លួននោះ ឬវត្ថុទាំងមូល ច្បាប់បានអនុញ្ញាតផ្ដល់សិទ្ធិទៅលើអ្នកទិញដោយមិនចាំបាច់ធ្វើការយល់ព្រមបាន។[65] ហេតុនេះនៅពេលគាត់(ម្ចាស់ម្នាក់ក្នុងម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់) ចង់រំលាយកិច្ចសន្យានោះគាត់មិនអាចធ្វើបានទេ។

ចំពោះករណីទី២៖ ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់បានលក់ភាគដែលជាកម្មសិទ្ធិរបស់ខ្លួនម្នាក់ៗទៅឱ្យអ្នកទិញតែម្នាក់ តាមកិច្ចសន្យាដោយឡែកនោះ ដោយមានការសន្យាពិសេសនៃការលោះវិញ ម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗអាចលោះមកវិញ នូវភាគរបស់ខ្លួនបាន។ ហេតុនេះ ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគនៃចំណែកនីមួយៗចង់ធ្វើការរំលាយនូវកិច្ចសន្យាលោះរបស់ខ្លួននោះ គាត់ជាអាចធ្វើការរំលាយកិច្ចសន្យាទៅលើការព្រមព្រៀងដោយឡែករបស់ពួកគាត់បាន ដោយអនុវត្តតាមវិធីអនុវត្តសិទ្ធិលោះតាមមាត្រា ៥៦៣ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍៖ លោក ក លោក ខ និងកញ្ញា ង បានធ្វើការលក់ដីមួយកន្លែងដែលជាកម្មសិទ្ធិអវិភាគរវាងអ្នកទាំងបីទៅឱ្យ លោក រដ្ឋា ហើយភាគីអ្នកលក់បានលើកឡើងពីការសន្យាពិសេសសម្រាប់អនុវត្តសិទ្ធិលោះយកដីនោះមកវិញ ក្នុងរយៈពេល០៣ឆ្នាំ ហើយលោក រដ្ឋា ក៏បានយល់ព្រម ដោយអ្នកទាំងបីនាក់បានធ្វើការសន្យាព្រមព្រៀងក្នុងកិច្ចសន្យារួមមួយ។ លុះរំលងបាន០១ឆ្នាំកន្លះ លោក ខ ចង់ធ្វើការរំលាយកិច្ចសន្យាលក់ទិញដែលធ្វើឡើងរវាងគាត់ លោក ក និងកញ្ញា ង ជាមួយនឹងលោក រដ្ឋា ចោល ដោយចង់លោះដីដែលជាភាគរបស់គាត់មកមុនពេលកំណត់។ ក្នុងករណីនេះ លោក រដ្ឋា មិនចាំបាច់ធ្វើការយល់ព្រមចំពោះសំណើនេះឡើយ ដោយហេតុថាកិច្ចសន្យានោះត្រូវបានធ្វើឡើងក្នុងកិច្ចព្រមព្រៀងតែមួយរវាងអ្នកទាំងបី(អ្នកលក់) តែលោក ខ បែរជាចង់លោះតែចំណែករបស់គាត់មុន។ ម្យ៉ាងទៀតបញ្ញត្តិទូទៅ ដែលបានចែងពីការរំលាយកិច្ចសន្យាករណីមានភាគីច្រើននាក់គឺត្រូវធ្វើឡើងដោយបុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់។[66]

### ២.២.៧.ករណីពិសេសអនុវត្តចំពោះកម្មវត្ថុនៃកិច្ចសន្យាជាអចលនវត្ថុ

#### ក.ករណីកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាប់មានសិទ្ធិប្រត្យក្សជាផលុបភោគជាអាទិ៍

នៅពេលដែលកម្មវត្ថុកិច្ចសន្យាលក់ទិញភ្ជាប់ជាមួយសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬសិទ្ធិលើការបញ្ចាំសម្រាប់តតិយជន ដែលអ្នកទិញគាត់មិនអាចប្រើប្រាស់ ឬទទួលផលពីកម្មវត្ថុទាំងមូល ឬមួយផ្នែកដោយសារតែអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិន

[65] មាត្រា ៥៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[66] មាត្រា ៤១០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

បានដឹងពីអត្ថិភាពនៃសិទ្ធិនោះ នៅពេលធ្វើកិច្ចសន្យា អាចធ្វើការទាមទារសំណងនៃការខូចខាតបាន។[67] វាមើលទៅគឺមានទំនាក់ទំនងស្រដៀងគ្នាទៅនឹងករណីដែលសិទ្ធិមួយភាគជារបស់អ្នកដទៃ ហេតុនេះទើបអ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាប្រហាក់ប្រហែលគ្នានឹងករណីមាត្រា ៥៣៣ ដែរ។

ឧទាហរណ៍៖ នៅក្នុងករណីដែលលោក ខ បានធ្វើការទិញដីពីលោក ក ប៉ុន្តែ ក បានជួលដីនោះទៅឱ្យកញ្ញា ង រួចមុនទៅហើយ ដោយកញ្ញា ង ក៏បានបង្កើតនូវលក្ខខណ្ឌតតាំងរួចផងដែរ ដូច្នេះ ខ មិនអាចទាមទារនូវការប្រើប្រាស់ដីនោះ ចំពោះ កញ្ញា ង បានឡើយ។

ដូចគ្នានេះដែរ ចំពោះករណីដែលសេវភាពត្រូវមានសម្រាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ បែរជាគ្មានទៅវិញនោះ ករណីនេះត្រូវយកអនុវត្តដូចគ្នានឹងករណីដែលមានបន្ទុកនៃសិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល ត្រង់ចំណុចថា ការប្រើប្រាស់ និងអាស្រ័យផលដែលអ្នកទិញសង្ឃឹមលើការប្រើប្រាស់ចំពោះវត្ថុដែលជាកម្មវត្ថុ ផ្ទុយទៅវិញត្រូវបានរារាំង ហេតុដូច្នេះ ត្រូវអនុលោមតាមបញ្ញត្តិដូចគ្នា ដោយយោងតាមបញ្ញត្តិមាត្រា៥៣៤ កថាខណ្ឌទី៣។

ករណីដែលអ្នកទិញប្រើប្រាស់សិទ្ធិក្នុងការទាមទារសំណងនៃការខូចខាត ឬការរំលាយកិច្ចសន្យាដោយសារតែកម្មវត្ថុនៃការបង្កើតកិច្ចសន្យាមិនបានសម្រេច ត្រូវប្រើប្រាស់សិទ្ធិទាំងពីរនេះ ក្នុងរយៈពេល០១ (មួយ)ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត។[68]

**ខ.ករណីកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាប់សិទ្ធិប្រាតិភោគប្រត្យក្ស**

ប្រសិនបើមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំដែលកំណត់ថា ម្ចាស់បំណុលមិនប្រើប្រាស់ និងអាស្រ័យផល ឬមានហ៊ីប៉ូតែកដែលបានដាក់លើអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ នៅពេលដែលអ្នកទិញបានបាត់បង់កម្មសិទ្ធិលើអចលនវត្ថុនោះ ដោយសារតែសិទ្ធិប្រាតិភោគប្រត្យក្សនោះត្រូវបានគេអនុវត្ត អ្នកទិញអាចរំលាយកិច្ចសន្យាបាន។[69] ថ្វីត្បិតតែអ្នកលក់បានផ្ទេរកម្មសិទ្ធិលើវត្ថុនោះមកឱ្យអ្នកទិញក៏ពិតមែន ដែលយើងអាចមើលដឹងថាការផ្ទេរបន្ទុកហានិភ័យត្រូវបានប្រគល់មកឱ្យអ្នកទិញបាត់ទៅហើយ ដោយសារតែការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ប៉ុន្តែបើច្បាប់មិនអនុញ្ញាតឱ្យគាត់រំលាយកិច្ចសន្យា គឺវាហាក់ដូចជាអយុត្តិធម៌ចំពោះគាត់ពេក ព្រោះតែសិទ្ធិប្រាតិភោគប្រត្យក្សដែលបានបានបង្កើតលើដីដោយអ្នកលក់ ហើយដីនោះវាជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញត្រូវបានគេយកទៅអនុវត្ត ជាហេតុធ្វើឱ្យគាត់ (អ្នកទិញ) បានបាត់បង់ដី នោះបញ្ញត្តិនេះមិនរារាំងការរំលាយកិច្ចសន្យាទេ បើទោះបីជាអ្នកទិញបានដឹងពីអត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សនេះជាមុនក៏ដោយ ព្រោះគាត់អាចជឿជាក់ថាអ្នកលក់នឹងអនុវត្តកាតព្វកិច្ចក្នុងការសងបំណុលនោះ។

[67] សេចក្តីកំណត់ចំពោះមាត្រានីមួយ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ទំព័រទី ១០៣, កថាខណ្ឌទី១។

[68] មាត្រា ៥៣៤ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី។

[69] មាត្រា ៥៣៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

ករណីដែលអ្នកទិញបានធ្វើការចំណាយដើម្បីរក្សាទុកនូវកម្មសិទ្ធិ អ្នកទិញនោះអាចទាមទារឱ្យអ្នកលក់សងថ្លៃចំណាយនោះមកវិញបាន។[70] មានន័យថានៅពេលដែលអ្នកទិញបានចេញថ្លៃសងទៅលើបំណុលដែលមានលើដីនោះ ដើម្បីតែការពារការអនុវត្តនូវសិទ្ធិប្រាតិភោគប្រត្យក្ស គាត់អាចទាមទារថ្លៃចំណាយប្រាក់នោះពីអ្នកលក់វិញបាន។

ឧទាហរណ៍៖ លោក ខ បានទិញដីមួយកន្លែងពីលោក ក ហើយដីនោះជាកម្មវត្ថុហ៊ីប៉ូតែក ដែលលោក ក បានដាក់ធានាលើបំណុលរបស់កញ្ញា ង ចំនួន ១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក)។ ក្រោយមក កញ្ញា ង បានស្នើសុំឱ្យលោក ខ ធ្វើការបង់ប្រាក់ចំនួន ១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ដើម្បីរំលត់ការអនុវត្តហ៊ីប៉ូតែក បើមិនដូច្នោះទេ កញ្ញា ង នឹងយកដីនេះទៅអនុវត្ត។ ដូចនេះប្រសិនបើលោក ខ បានចេញថ្លៃសងបំណុលចំនួន ១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ក្នុងការចំណាយរក្សាវត្ថុដែលជាដីរបស់គាត់។ គាត់អាចទាមទារប្រាក់ចំនួន ១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ពីលោក ក វិញបាន។

ទោះបីជាករណីអ្នកទិញមានសិទ្ធិដូចបានកំណត់ក្នុងការរំលាយកិច្ចសន្យា តាមកថាខណ្ឌទី១ នៃមាត្រា ៥៣៥ ឬទាមទារឱ្យអ្នកលក់សងថ្លៃចំណាយក៏ដោយ ប្រសិនបើគាត់បានទទួលការខូចខាត គាត់អាចទាមទារសំណងថ្លៃខូចខាតបានផងដែរ[71]។

ឧទាហរណ៍៖ សម្រាប់ឧទាហរ៍ខាងលើ ប្រសិនបើលោក **ខ** បានចំណាយសម្រាប់រក្សាការពារដីរបស់គាត់ពីការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សរបស់កញ្ញា **ង** ចំនួន១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) នោះ គាត់ក៏អាចទាមទារជាមួយគ្នានូវថ្លៃសំណងនៃការខូចខាតផងដែរ។

ប៉ុន្តែប្រសិនបើអ្នកទិញដែលបានទិញអចលនវត្ថុ ដែលភ្ជាប់ជាមួយសិទ្ធិប្រាតិភោគប្រត្យក្សដូចដែលបានកំណត់ក្នុងមាត្រា ៥៣៥ កថាខណ្ឌទី១ នោះ ក្នុងតម្លៃដែលគាត់បានដកចេញនូវប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះរួចរាល់ គាត់មិនអាចអនុវត្តសិទ្ធិក្នុងការរំលាយកិច្ចសន្យា ឬសងថ្លៃចំណាយប្រាក់ និងទាមទារសំណងនៃការខូចខាតពីអ្នកលក់បានឡើយ។[72]

ឧទាហរណ៍៖ នៅក្នុងករណីខាងលើនេះ ប្រសិនបើតម្លៃដើមនៃដីត្រូវលក់គឺ ៥០០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ហើយលោក **ក** និងលោក **ខ** បានព្រមព្រៀងគ្នាបង់ថ្លៃលក់ទិញគឺ៣៨០០០$ (បីម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ដោយដកតម្លៃនៃអត្ថិភាពហ៊ីប៉ូតែករួចហើយ នោះ លោក **ខ** មិនអាចធ្វើការទាមទារប្រាក់ចំនួន១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារ) ឬសូម្បីតែថ្លៃសំណងនៃការខូចខាត ទោះបីជាគាត់បានចេញថ្លៃចំណាយសំរាប់ការរក្សាការពារទ្រព្យគាត់ក៏ដោយ។

---

[70] មាត្រា ៥៣៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[71] មាត្រា ៥៣៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

[72] មាត្រា ៥៣៥ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី។

**គ.ករណីខ្វះ ឬលើសទំហំដី**

នៅក្នុងមាត្រា ៥៤៦ បានចែងពីបញ្ញត្តិពិសេសនៃការទទួលខុសត្រូវក្នុងការធានាវិការៈ នៅក្នុងករណីដែលដីមានទំហំលើស ឬក៏ខ្វះ។ ករណីដែលគូភាគីបានបញ្ជាក់ទំហំដីសរុប និងកំណត់តម្លៃតាមខ្នាតដីច្បាស់លាស់ វាមានលក្ខណៈងាយស្រួលក្នុងការគណនាគម្លាតតម្លៃរវាងទំហំដីពិតប្រាកដ និងទំហំដីដែលបានបញ្ជាក់។[73] ដូចនេះករណីនេះ ប្រសិនបើទំហំដីពិតប្រាកដតិចជាងទំហំដីដែលបានបញ្ជាក់ នោះអ្នកទិញអាចទាមទារឱ្យផ្ដល់តាវកាលិកនូវផ្នែកខ្វះ ឬបន្ថយនូវតម្លៃដី ឬរំលាយកិច្ចសន្យាបាន (ប្រសិនបើគោលបំណងនៃកិច្ចសន្យាមិនបានសម្រេច) និងអាចទាមទារសំណងនៃការខូចខាតផងដែរ។[74] ផ្ទុយទៅវិញប្រសិនបើទំហំដីពិតប្រាកដលើសពីទំហំដីដែលបានបញ្ជាក់ នោះអ្នកលក់ដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារឱ្យបន្ថែមតម្លៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងគ្នាផ្សេង។[75]

ករណីមួយផ្សេងទៀតប្រសិនបើភាគីបានបញ្ជាក់ទំហំដីសរុប និងកំណត់ដីទាំងមូលរួចរាល់ នោះវាមានភាពលំបាកក្នុងការគណនាគម្លាតតម្លៃរវាងទំហំដីពិតប្រាកដ និងទំហំដីដែលបានបញ្ជាក់។ ដូច្នេះក្រមរដ្ឋប្បវេណីបានបញ្ញត្តថាអ្នកទិញមិនអាចទាមទារផ្ដល់តាវកាលិកនូវផ្នែកខ្វះ ឬបន្ថយតម្លៃ ឬរំលាយកិច្ចសន្យា ឬទាមទារសំណងនៃការខូចខាតបានឡើយ ទោះបីជាទំហំដីពិតប្រាកដ តិចជាងទំហំដីដែលបានបញ្ជាក់ក៏ដោយ។[76] ករណីលើកលែងដែលអ្នកទិញអាចទាមការសង្គ្រោះខាងក្រោមនេះបាន ប្រសិនបើ៖

- អ្នកលក់បានដឹងពីការខ្វះនៃទំហំដីនោះ ឬ
- អ្នកលក់បានធានានូវទំហំដីនោះ ឬ
- ទំហំខ្វះនោះមានច្រើនជាង ១ភាគ២០ (ស្មើនឹងប្រាំភាគរយ) នៃទំហំដីដែលបានបញ្ជាក់[77]

ហើយនៅពេលដែលទំហំដីពិតប្រាកដ មានលើសពីទំហំដែលបានបញ្ជាក់ នោះអ្នកលក់មិនអាចទាមទារបន្ថែមតម្លៃដីបានឡើយ។[78] តែអ្នកលក់ដែលសុចរិត និងគ្មានកំហុសអាចធ្វើការទាមទារឱ្យបន្ថែមតម្លៃដីបាន ប្រសិនបើទំហំដីពិតប្រាកដ លើសពីទំហំដីដែលបានបញ្ជាក់ ចំនួន១ភាគ២០ (ស្មើនឹងប្រាំភាគរយ)។[79]

ឧទាហរណ៍៖ ករណីដែលលោក ក បានទិញដីទំហំ ១០០០ (មួយពាន់) ម៉ែត្រការ៉េ ក្នុងតម្លៃ ១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) ពីលោក ខ ប៉ុន្តែទំហំដីពិតប្រាកដមានតែចំនួន ៩១០ (ប្រាំបួនរយដប់) ម៉ែត្រការ៉េ។

---

[73] សេចក្ដីពន្យល់នៃក្រមរដ្ឋប្បវេណី ភាគ២, ទំព័រទី ១០។

[74] មាត្រា ៥៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[75] មាត្រា៥៤៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[76] មាត្រ ៥៤៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

[77] មាត្រា ៥៤៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[78] មាត្រា ៥៤៦ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី។

[79] មាត្រា ៥៤៦ កថាខណ្ឌទី៤ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

ប្រសិនបើគូភាគីបានព្រមព្រៀងគ្នាថា តម្លៃនៃដីនោះ គឺ ១០$ (ដប់ដុល្លារអាមេរិក) ក្នុងមួយម៉ែត្រការ៉េ នោះលោក ក អាចធ្វើការទាមទារឱ្យផ្តល់នូវតារាកាលិកដែលជាផ្នែកខ្វះ ឬបន្ថយតម្លៃដីចំនួនមកត្រឹមចំនួន៩៧០០$ (ប្រាំបួនពាន់ប្រាំពីររយដុល្លារអាមេរិក) ឬក៏រំលាយកិច្ចសន្យាមួយនេះបានប្រសិនបើលោក ក មិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យា ព្រមទាំងអាចទាមទារនូវសំណងនៃការខូចខាត (ករណីនេះទាល់តែលោក ក ជាជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ)។ តែបើគូភាគីមិនបានសម្រេចពីតម្លៃតាមខ្នាតដីច្បាស់លាស់ទេ នោះលោក ក អាចទាមទារនូវការសង្គ្រោះបាន ចំពោះករណីដែលលោក ខ បានដឹងពីទំហំខ្វះ និងបានធានានូវទំហំរបស់ខ្លួន។ ជាក់ស្តែងនៅក្នុងករណីនេះទោះបីជាលោក ខ មិនបានធានា ឬមិនបានដឹងថាទំហំដីរបស់ខ្លួននឹងខ្វះខាតបែបនេះក៏ដោយ តែលោក ក នៅតែមានសិទ្ធិទាមទារការសង្គ្រោះបានដដែល ព្រោះតែទំហំដែលខ្វះមានចំនួនលើសពី១ភាគ២០នៃទំហំដីដែលបានបញ្ជាក់ គឺៈ

ដូចនេះយើងឃើញថាចំនួន ៥% នៃទំហំដីសរុបគឺ ៥០ម៉ែត្រការ៉េ។ ហេតុនេះករណីខាងលើលោក **ក** អាចទាមទារការសង្គ្រោះទៅលើលោក **ខ** បាន ព្រោះទំហំដីពិតប្រាកដមានចំនួន ៩១០ម៉ែត្រការ៉េ ដែលតិចជាងទំហំដីបញ្ជាក់។ ម្យ៉ាងទៀតច្បាប់បានអនុញ្ញាតឱ្យមានការសង្គ្រោះកាលណាតិចជាង៥% ដោយ ១០០០ម៉ែត្រការ៉េ ដក៥០ម៉ែត្រការ៉េ ស្មើនឹង៩៥០ម៉ែត្រការ៉េ នាំឱ្យដីពិតប្រាកដមានទំហំ ៩១០ ម៉ែត្រការ៉េ តូចជាងដីដែលបានបញ្ជាក់ដែលមានទំហំ ១០០០ ម៉ែត្រការ៉េ។

សំរាប់អំឡុងពេលក្នុងការអនុវត្តសិទ្ធិដែលទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានាវិការៈ ត្រូវអនុវត្តក្នុងអំឡុងពេល ០១ឆ្នាំ ដោយគិតចាប់ពីៈ

- សម្រាប់អ្នកទិញ ពេលដែលបានដឹង ឬគូភាគីបានដឹងពីវិការៈ និងការខូចខាត
- សម្រាប់អ្នកលក់ពេលដែលធ្វើកិច្ចសន្យា (មាត្រា ៥៤៧ កថាខណ្ឌទី២)

ចំពោះសិទ្ធិទាមទារសំណងនៃការខូចខាតលើករណីក្នុងមាត្រា៥៤៦ កថាខណ្ឌទី១ និងមាត្រា៥៤៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ ត្រូវរលត់ទៅតាមមាត្រា ៤៨២ (អំឡុពេលនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលទូទៅ) គឺមានរយៈពេល០៥ឆ្នាំ ហើយរាប់គិតចាប់ពីពេលដែលអ្នកលក់អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន តាមបញ្ញត្តិនៃមាត្រា ៤៨១ និងមាត្រា ៤៨២។[80]

### ២.៣.ការរំលាយកិច្ចសន្យាលក់ទិញដោយការព្រមព្រៀងរបស់ភាគី

ជាការពិតណាស់ កិច្ចសន្យាកើតចេញពីការព្រមព្រៀងរវាងភាគីដោយបានកំណត់អត្ថន័យ និងខ្លឹមសារនៃកិច្ចសន្យា ម្យ៉ាងវិញទៀតច្បាប់បានអនុញ្ញាតឱ្យភាគីមានសិទ្ធិក្នុងការកំណត់សិទ្ធិ និងករណីយកិច្ចដែលត្រូវអនុវត្តក្នុងកិច្ចសន្យារបស់ខ្លួនផងដែរ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណី បានចែងថា គូភាគីនៃកិច្ចសន្យាអាចសន្យាឱ្យភាគីម្ខាង

[80] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ទំព័រទី ១២។

ឬសងខាងមានសិទ្ធិរំលាយកិច្ចសន្យា នៅក្នុងកិច្ចសន្យានោះបាន។[81] អត្ថន័យនៃចំណុចនេះ ចង់បញ្ជាក់ថាការរំលាយកិច្ចសន្យាដែលកំណត់ដោយការព្រមព្រៀង គឺជាការរំលាយដែលផ្អែកលើឆន្ទៈព្រមព្រៀងរបស់ភាគីដោយមានកំណត់ជាមុន ឬក្រោយពេលនៃការបង្កើតកិច្ចសន្យា។

ជាធម្មតា អំឡុងពេលនៃការបង្កើតកិច្ចសន្យាភាគីអាចកំណត់សិទ្ធិ និងករណីយកិច្ច ឬការបំពានដែលជាលក្ខខណ្ឌនៃការរំលាយកិច្ចសន្យាបាន។ ប្រសិនបើលក្ខខណ្ឌនៃការរំលាយកិច្ចសន្យាបានកំណត់ជាមុននៅក្នុងកិច្ចសន្យានោះ វិវាទនឹងពុំកើតមានទេក្នុងករណីដែលការបំពានកិច្ចសន្យាត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា ហើយត្រូវបានព្រមព្រៀងដោយភាគីទាំងសងខាង។

ឧទាហរណ៍៖ A បានបញ្ជាឱ្យ B ដែលជាជាងកាត់សំលៀកបំពាក់រៀបចំឈុតមង្គលការសម្រាប់ថ្ងៃរៀបអាពាហ៍ពិពាហ៍របស់ខ្លួននៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ ហើយភាគីទាំងសងខាងបានព្រងព្រៀងគ្នាដោយបានចងនៅក្នុងកិច្ចសន្យាថា "ភាគីទាំងសងខាងមានសិទ្ធិរំលាយកិច្ចសន្យារបស់ខ្លួន នៅពេលណាក៏បាន មុនពេលការអនុវត្តកិច្ចសន្យាបានមកដល់ និងដោយមានការជូនដំណឹងជាមុនទៅភាគីម្ខាងទៀត។" នៅក្នុងថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ B (ជាងកាត់សំលៀកបំពាក់) បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យារបស់ខ្លួន។

ការរំលាយកិច្ចសន្យានេះ នឹងមានអានុភាពភ្លាមៗ ទោះបីជាការរំលាយកិច្ចសន្យានេះបានធ្វើឱ្យប៉ះពាល់ ឬគោលបំណងរបស់ A (អ្នកបញ្ជាទិញ) មិនបានសម្រេចក៏ពិតមែន។ ដោយហេតុថាភាគីទាំងសងខាងបានព្រមព្រៀងគ្នា ដោយកំណត់និងអនុញ្ញាតឱ្យភាគីទាំងសងខាងមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាពេលណាក៏បានមុនពេលការអនុវត្តកិច្ចសន្យាមកដល់ និងដោយមានការជូនដំណឹងជាមុន។ ហេតុដូច្នេះ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាគឺស្របតាមគោលបំណង និងឆន្ទៈរបស់ភាគីទាំងសងខាង។

ទោះបីជាគ្មានការកំណត់សិទ្ធិរំលាយកិច្ចសន្យាក៏ដោយ ប៉ុន្តែគូភាគីអាចរំលាយកិច្ចសន្យាដោយការព្រមព្រៀងគ្នាបានដែរ។[82] ក្រោយពេលដែលកិច្ចសន្យាបានកើតមានឡើង ហើយបើភាគីម្ខាងណាបានយល់ឃើញថាខ្លួនចង់រំលាយកិច្ចសន្យានោះដោយមូលហេតុនៃការរំលាយកិច្ចសន្យាតែពុំបានកំណត់ជាមុនក្នុងកិច្ចសន្យា ឬមិនមែនជាមូលហេតុនៃការបំពានកិច្ចសន្យាធ្ងន់ធ្ងរតាមមាត្រា ៤០៨ ភាគីម្ខាងនោះអាចដាក់សំណើក្នុងការរំលាយកិច្ចសន្យាទៅកាន់ភាគីម្ខាងទៀតបាន។ ប្រសិនបើភាគីម្ខាងទៀតផ្តល់ស្វីការចំពោះសំណើនោះ សិទ្ធិរំលាយកិច្ចសន្យានឹងកើតមានឡើង។ ប៉ុន្តែការរំលាយកិច្ចសន្យានេះ មិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានឡើយ។[83]

[81] មាត្រា ៤១៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។

[82] មាត្រា ៤១៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។

[83] មាត្រា ៤១៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍៖ A បានដាក់ផ្ទះលក់ និងបានពឹងពាក់ B (ភ្នាក់ងារអចលនទ្រព្យ) ឱ្យរកអ្នកទិញផ្ទះរបស់ខ្លួន ដោយផ្តល់ប្រាក់កម្រៃ ១០% (ដប់ភាគរយ) នៃតម្លៃផ្ទះ។ បន្ទាប់មក B បានណែនាំ C (អ្នកទិញ) ដើម្បីទិញផ្ទះពី A ក្នុងតម្លៃ ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដោយ B ទទួលបានកម្រៃ ១,០០០ (មួយពាន់) ដុល្លារអាមេរិកពីការលក់នោះ។ A បានសន្យាថាប្រគល់ផ្ទះឱ្យ C នៅ ១០ (ដប់) ថ្ងៃក្រោយពីការចុះកិច្ចសន្យា។ លុះដល់ថ្ងៃទី ០៩ ក្រោយពីការចុះកិច្ចសន្យា A បានស្នើសុំ C ដើម្បីរំលាយកិច្ចសន្យានោះ ដោយព្រមផ្តល់សំណងនៃការខូចខាតទៅកាន់ C។

ក្នុងករណីនេះ ការរំលាយកិច្ចសន្យាមិនអាចបង្កើតឡើងទេ ដោយហេតុថាការរំលាយកិច្ចសន្យានេះបានប៉ះពាល់ ឬធ្វើឱ្យខូចប្រយោជន៍របស់តតិយជននោះ។ ជាក់ស្តែងក្នុងកិច្ចសន្យានេះ ត្បិតតែមាន A (ជាអ្នកលក់) និង B (ជាអ្នកទិញ) ក៏ពិតមែន ប៉ុន្តែចំណងគតិយុត្តិនិងទំនាក់ទំនងផលប្រយោជន៍ពុំបានកើតឡើងសម្រាប់តែភាគី A និងC ទេ។ ផ្ទុយទៅវិញ B (ភ្នាក់ងារអចលនទ្រព្យ) បានទទួលប្រយោជន៍ពីកិច្ចសន្យាលក់ទិញខាងលើនេះផងដែរ។ ហេតុដូច្នេះ ដើម្បីការពារផលប្រយោជន៍របស់តតិយជនក្នុងកិច្ចសន្យាពីការបំពាន ឬខូចខាតដោយមិនត្រឹមត្រូវ បញ្ញត្តិនៃមាត្រា ៤១៤ បានការពារ និងមិនអនុញ្ញាតឱ្យភាគីព្រមព្រៀងគ្នារំលាយកិច្ចតាមមូលហេតុដែលមិនបានកំណត់ក្នុងកិច្ចសន្យាឡើយ លើកលែងតែមានការព្រមព្រៀងពីតតិយជន។

ការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចក្នុងបញ្ញត្តិទូទៅ និងការរំលាយកិច្ចសន្យាក្នុងបញ្ញត្តិពិសេស មានលក្ខណៈគតិយុត្តិដូចគ្នា ពោលគឺជាការរំលាយកិច្ចសន្យាកើតចេញពីការបង្ហាញឆន្ទៈរបស់ភាគីម្ខាង(សកម្មភាពឯកតោភាគី) នៅពេលដែលលក្ខខណ្ឌនៃការរំលាយត្រូវបានបំពេញ។ ចំណែកឯការរំលាយកិច្ចសន្យាដោយការព្រមព្រៀង គឺជាការរំលាយដែលកើតចេញពីឆន្ទៈព្រមព្រៀងរបស់ភាគីទាំងសងខាងដោយមិនមែនជាសកម្មភាពឯកតោភាគីនោះទេ។[84]

[84] សាស្ត្រាចារ្យសេង នាង និងលោកស្រីមេធាវី ទេព បូផល, ការរំលាយកិច្ចសន្យា, ឆ្នាំ ២០១៩, ទំព័រទី ២០។

## ជំពូកទី ២ ៖ នីតិវិធីនៃការរំលាយកិច្ចសន្យាលក់ទិញ

នៅក្នុងស្មារតី និងគោលបំណងនៃបញ្ញត្តិទូទៅ និងបញ្ញត្តិពិសេសស្តីពីកិច្ចសន្យាលក់ទិញក្នុងក្រមរដ្ឋប្បវេណី បានកំណត់យ៉ាងច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីក្នុងការអនុវត្តកិច្ចសន្យាលក់ទិញឱ្យមានភាពងាយស្រួល ឆាប់រហ័ស និងល្អប្រសើរ។ ការកំណត់បែបនេះ ដើម្បីឱ្យភាគីនៃកិច្ចសន្យាបានអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គល សុចរិតភាពនិងភាពស្មោះត្រង់ និងប្រើប្រាស់សិទ្ធិដែលខ្លួនមានដោយមិនបំពានចំពោះសិទ្ធិរបស់អ្នកដទៃ។ ម្យ៉ាងវិញទៀតបទបញ្ញត្តិទូទៅ និងបញ្ញត្តិពិសេសក៏បានកំណត់យកវិធានរំលាយកិច្ចសន្យាជាវិធានសង្គ្រោះ ដែលអនុញ្ញាតឱ្យភាគីដែលមានសិទ្ធិអាចអនុវត្តសិទ្ធិនេះក្នុងគោលបំណងដើម្បីការពារប្រយោជន៍ស្របច្បាប់របស់ខ្លួនដែលកើតឡើងក្រោមអានុភាពនៃកិច្ចសន្យា ក្នុងករណីដែលកិច្ចសន្យាត្រូវបានបំពានយ៉ាងធ្ងន់ធ្ងរ។

ត្បិតតែក្នុងបញ្ញត្តិពិសេសស្តីពីកិច្ចសន្យាលក់ទិញក្នុងក្រមរដ្ឋប្បវេណី មិនបានកំណត់ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាលក់ទិញយ៉ាងច្បាស់លាស់ជាក់លាក់ក៏ពិតមែន ប៉ុន្តែបើតាមគោលការណ៍ជាមូលដ្ឋាននៃក្រមរដ្ឋប្បវេណី ភាគីម្ខាងនៃកិច្ចសន្យាដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈជាសកម្មភាពរបស់ភាគីឯកជនតែម្ខាង ដើម្បីបំពេញសេចក្តីត្រូវការនិងបំណងរបស់ខ្លួន ដែលអាចអនុញ្ញាតឱ្យភាគីដែលមានសិទ្ធិធ្វើការបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យសម្បត្តិតែម្ខាង និងមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតនៃកិច្ចសន្យាឡើយ។

ដូច្នេះចំពោះការរំលាយកិច្ចសន្យាគ្រប់ទម្រង់ រួមបញ្ចូលទាំងកិច្ចសន្យាលក់ទិញផងដែរ ភាគីដែលមានសិទ្ធិរំលាយអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ដោយការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតជាការគ្រប់គ្រាន់។[85] ការបង្ហាញឆន្ទៈដើម្បីរំលាយកិច្ចសន្យាលក់ទិញ អាចធ្វើឡើងដោយការជូនដំណឹងតាមគ្រប់មធ្យោបាយដែលអាចផ្តល់ព័ត៌មានទៅដល់ភាគីម្ខាងទៀតនៃកិច្ចសន្យាបាន ហើយអានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញនឹងកើតមានឡើង នៅពេលដែលការជូនដំណឹងអំពីការរំលាយបានទៅដល់ភាគីម្ខាងទៀតនៃកិច្ចសន្យាលក់ទិញ។ ថ្វីត្បិតតែភាគីដែលមានសិទ្ធិរំលាយបានអនុវត្តសិទ្ធិរបស់ខ្លួន និងបានជូនដំណឹងដើម្បីបង្កើតអានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញទៅកាន់ភាគីម្ខាងទៀតយ៉ាងណាក្តី វានឹងមិនមែនជាបញ្ហា ឬវិវាទឡើយ ប្រសិនបើភាគីម្ខាងទៀតដែលទទួលនូវដំណឹងអំពីការរំលាយកិច្ចសន្យាលក់ទិញ បានអនុវត្តនូវករណីយកិច្ចបដិទាននូវសិទ្ធិ ឬតាវកាលិកនៃកិច្ចសន្យាលក់ទិញត្រលប់ទៅវិញនោះ។ ប៉ុន្តែវាជាបញ្ហា ក្នុងករណីដែលភាគីដែលទទួលដំណឹងអំពីការរំលាយកិច្ចសន្យាលក់ទិញ មិនទទួលស្គាល់សិទ្ធិរំលាយ និងមិនព្រមអនុវត្តករណីយកិច្ចបដិទាននូវសិទ្ធិ

[85] លោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ ,ឆ្នាំ២០១៨ ដល់២០១៩ ,សញ្ញាណទូទៅនៃកិច្ចសន្យា ,ទំព័រ ២១។

ឬតាវលិកនៃកិច្ចសន្យាលក់ទិញត្រឡប់ទៅវិញ។ ចំពោះចំណុចនេះ បទបញ្ញត្តិមូលដ្ឋាន ឬបញ្ញត្តិពិសេសនៃក្រម រដ្ឋប្បវេណី មិនបានហាមភាគីដែលមានសិទ្ធិរំលាយ អនុវត្តសិទ្ធិរបស់ខ្លួនតាមនីតិវិធីបណ្តឹងនោះទេ។

ដូច្នេះនៅក្នុងជំពូកទី២នេះ យើងនឹងធ្វើការពិភាក្សា ពិនិត្យ និងដោះស្រាយនូវចំណោទគតិយុត្តិចំនួន ០២ សំណួរៈ តើនីតិវិធីនៃការរំលាយកិច្ចសន្យាលក់ទិញអាចត្រូវធ្វើឡើងដូចម្តេច? ហើយក្នុងករណីដែលភាគីមិន បានអនុវត្តសិទ្ធិរំលាយ តើនឹងមានអានុភាពយ៉ាងណាខ្លះ?

នីតិវិធីដែលភាគីអាចជ្រើសរើសដើម្បីអនុវត្តសិទ្ធិរំលាយកិច្ចសន្យាលក់ទិញ ដែលធ្វើឱ្យកិច្ចសន្យាបាត់បង់ អានុភាព ហើយមូលហេតុចម្បងដែលញ៉ាំងឱ្យភាគីបាត់បង់នូវសិទ្ធិរំលាយកិច្ចសន្យាលក់ទិញ ដែលបង្កើតឱ្យ មានអានុភាពនៃការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញរបស់ខ្លួន នឹងត្រូវលើកយកមកបកស្រាយសម្រាប់ ចំណុចនេះ។

## ១.នីតិវិធីនៃការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាលក់ទិញ

នៅក្នុងនីតិវិធីនៃការរំលាយកិច្ចសន្យាលក់ទិញ ភាគីអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាលក់ទិញតាម ប្រព័ន្ធតុលាការ ក្នុងករណីដែលមានវិវាទទាក់ទងនឹងការទទួលស្គាល់សិទ្ធិរំលាយកិច្ចសន្យា ឬភាគីម្ខាងទៀតមិន ព្រមអនុវត្តករណីយកិច្ចបដិទាន ដោយឡែកប្រសិនបើភាគីបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាក្រៅប្រព័ន្ធ តុលាការ ហើយភាគីម្ខាងទៀតបានទទួលស្គាល់នូវសិទ្ធិរំលាយ និងព្រមអនុវត្តករណីយកិច្ចធ្វើបដិទាននោះ មិន តម្រូវឱ្យការអន្តរាគមន៍ពីតុលាការឡើយ។

### ១.១.ការរំលាយកិច្ចសន្យាលក់ទិញតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវបណ្តឹង ឬការទាមទារតាមផ្លូវតុលាការ គឺជាការអះអាងស្តីពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិតាមផ្លូវច្បាប់នីតិឯកជន ដែលបានកំណត់តាមរយៈបណ្តឹងរបស់ដើមចោទចំពោះចុងចម្លើយ។ ប៉ុន្តែការទាមទារតាមផ្លូវបណ្តឹងក្នុងករណីរំលាយកិច្ចសន្យា ពុំមានន័យថាត្រូវធ្វើការរំលាយកិច្ចសន្យាតាមរយៈ សេចក្តីសម្រេចរបស់តុលាការទេ ពីព្រោះការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា កើតឡើងដោយការបង្ហាញឆន្ទៈរបស់ ភាគីម្ខាងចំពោះភាគីម្ខាងទៀត ហេតុនេះការអនុវត្តសិទ្ធិរំលាយគឺផ្អែកសំខាន់លើឆន្ទៈរបស់ភាគីតែប៉ុណ្ណោះ។[86]

ផ្អែកតាមមាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី វិធីនៃការរំលាយកិច្ចសន្យាគឺជាការបង្ហាញឆន្ទៈរបស់ភាគីម្ខាង ទៀត ដែលបានន័យថាការរំលាយកិច្ចសន្យាមិនចាំបាច់មានការអន្តរាគមន៍ពីតុលាការឡើយ។ ប៉ុន្តែទោះបីជាភាគី ដែលមានសិទ្ធិរំលាយបានសុំឱ្យតុលាការចេញសាលក្រមរំលាយកិច្ចសន្យាជាអាទិ៍ តាមខ្លឹមសារនៃការទាមទារនេះ ត្រូវបានចាត់ទុកថាគ្មានផលប្រយោជន៍នៃបណ្តឹង ដែលជាមូលហេតុនៃការចេញដីកាសម្រេចលើកចោលបណ្តឹង

[86] លោក សេង នាង និងលោកស្រីទេព បូផល, ការរំលាយកិច្ចសន្យាលក់ទិញ, ឆ្នាំ២០១៩, ទំព័រ ៦៣។

ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។[87] ប្រសិនបើភាគីបានបង្ហាញឆន្ទៈក្រៅប្រព័ន្ធតុលាការរួចហើយ ដោយមានមូលហេតុតាមផ្លូវច្បាប់ក្នុងការរំលាយកិច្ចសន្យាជាអាទិ៍ ការអន្តរាគមន៍របស់តុលាការមានភាពចាំបាច់ ដើម្បីសម្រេចគោលបំណងរបស់ម្ចាស់បំណុលឱ្យមានលក្ខណៈជាសត្យានុម័ត។

ដូច្នេះការអនុវត្តសិទ្ធិទាមទារតាមផ្លូវតុលាការ ភាគីដែលមានសិទ្ធិរំលាយអាចអនុវត្តសិទ្ធិរបស់ខ្លួនតាមផ្លូវបណ្តឹង ក្រោមរូបភាពនៃការទាមទារដោយផ្អែកលើសិទ្ធិទាមទារឱ្យបដិទាន និងការទាមទារបញ្ជាក់នត្ថិភាពនៃកិច្ចសន្យា ក្រោយពេលដែលខ្លួនបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាចំពោះភាគីម្ខាងទៀត។

ឧទាហរណ៍៖ ក្នុងករណីអ្នកទិញ ដែលកំពុងកាន់កាប់រថយន្ត និងមិនព្រមប្រគល់រថយន្តមកកាន់អ្នកលក់វិញទេ អ្នកលក់មិនអាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់ដោយផ្អែកលើសិទ្ធិទាមទារដោយខ្លួនឯងដូចជា ការដកហូតរថយន្តត្រឡប់មកវិញ ឬការបញ្ឈប់ការប្រើប្រាស់ជាដើម ព្រោះអ្នកទិញមានមូលហេតុគតិយុត្តិក្នុងការកាន់កាប់តាមរយៈការកាន់កាប់ដោយជាក់ស្តែង។ ដូច្នេះអ្នកលក់ ត្រូវអនុវត្តសិទ្ធិទាមទារឱ្យប្រគល់តាមរយៈសេចក្តីសម្រេចរបស់តុលាការ។

ប្រសិនបើភាគីម្ខាងទៀត ត្រូវបានភាគីមានសិទ្ធិរំលាយជូនដំណឹងអំពីការរំលាយកិច្ចសន្យារួចហើយ ប៉ុន្តែភាគីម្ខាងទៀតនៅតែបន្តទាមទារឱ្យភាគីមានសិទ្ធិរំលាយ អនុវត្តកាតព្វកិច្ច ឬមិនទទួលស្គាល់ការបង្ហាញឆន្ទៈរំលាយ ដែលជាហេតុធ្វើឱ្យភាគីម្ខាងទៀតមិនព្រមប្រគល់តាវកាលិកនៃកិច្ចសន្យាលក់ទិញមកវិញទេ ភាគីដែលមានសិទ្ធិរំលាយ អាចធ្វើបណ្តឹងទាមទារឱ្យតុលាការបញ្ជាក់អំពីនត្ថិភាពនៃកិច្ចសន្យាលក់ទិញបាន។

តាមគោលការណ៍ច្បាប់ សេចក្តីសម្រេចរបស់តុលាការទោះបីជាសាលក្រមចុងក្រោយ ឬសាលក្រមរបៀបភាគីនៃសេចក្តីសម្រេចចាំបាច់ត្រូវអនុវត្តតាមការសម្រេច ឬកំណត់នៅក្នុងសេចក្តីសម្រេចនោះ ក្នុងករណីដែលសិទ្ធិប្តឹងឧបាស្រ័យ ឬប្តឹងទាស់ត្រូវបានរលត់។ ប្រសិនបើតុលាការបានចេញសេចក្តីសម្រេចរួចហើយ ទោះភាគីម្ខាងទៀតនូវប្រកែកមិនព្រមទទួលស្គាល់ក៏ដោយ ភាគីម្ខាងទៀតក៏ត្រូវតែបង្ខំចិត្តអនុវត្តតាមការសម្រេចរបស់តុលាការផងដែរ។

ប៉ុន្តែមុននឹងតុលាការចេញសាលក្រមបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច ឬបង្គាប់ឱ្យភាគីម្ខាងទៀតធ្វើបដិទាននូវតាវកាលិកនៃកិច្ចសន្យា តុលាការត្រូវពិនិត្យអំពីលក្ខខណ្ឌបណ្តឹងជាមុនសិន ហើយក្នុងករណីដែលពាក្យបណ្តឹងមិនត្រូវបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវ ឬខុសច្បាប់នោះ តុលាការអាចលើកចោលបណ្តឹងដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀម ឬការទាញហេតុផលនោះទេ។ ជាក់ស្តែង ដូចបានបញ្ជាក់ខាងលើ ចំពោះករណីដែលខ្លឹមសារនៃបណ្តឹងទាមទារឱ្យតុលាការសម្រេចអំពីការរំលាយកិច្ចសន្យា បណ្តឹងនេះ ជាបណ្តឹងខុស

[87] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ច្បាប់ ដោយហេតុថាច្បាប់មិនបានអនុញ្ញាតឱ្យភាគីរំលាយកិច្ចសន្យា តាមសេចក្តីសម្រេចរបស់តុលាការឡើយ។ ហេតុដូច្នេះតុលាការអាចលើកបណ្តឹងនេះចោល តាមដីកាសម្រេចបាន។

នីតិវិធីបណ្តឹងរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធតុលាការ ត្រូវបានចាប់ផ្តើមនៅពេលដែលមានការដាក់ពាក្យបណ្តឹង។ ពាក្យបណ្តឹងត្រូវបានចាត់ទុកថាបានដាក់ នៅពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងនោះទៅតុលាការ ហើយត្រូវបានបុគ្គលិករដ្ឋបាលផ្នែកទទួលពាក្យបណ្តឹងរដ្ឋប្បវេណី បោះត្រា និងចុះលេខចូលថាបានទទួល។[88] តាមក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងករណីដែលមានការបញ្ញត្តិផ្សេង ដូចជា បណ្តឹងនៃរឿងក្តីដែលមានចំនួនទឹកប្រាក់តិច។

នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចមួយចំនួនដូចជា៖ ក-ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ខ-ខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។ គ-នៅ ក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅខាងលើ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវ អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវ អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង។[89]

ក្រោយពីតុលាការ បានទទួលពាក្យបណ្តឹងដែលមានស្របតាមលក្ខខណ្ឌខាងលើ តុលាការត្រូវពិនិត្យ សារជាថ្មីអំពីចំណុចទាំងនោះ ហើយក្នុងករណីដែលតុលាការបានរកឃើញថាពាក្យបណ្តឹងនោះបានផ្ទុយនឹង ចំណុចខាងលើ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ។ ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះទេ តុលាការត្រូវលើកពាក្យបណ្តឹងចោល ដោយដីកាសម្រេច។[90]

តាមមាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅពេលតុលាការបានទទួលពាក្យបណ្តឹង និងក្រោយពីមានការ ពិនិត្យលើទម្រង់នៃពាក្យបណ្តឹង ឬចំណុចផ្សេងៗទៀតឃើញថាមានលក្ខណៈពេញលេញរួចហើយ តុលាការត្រូវ កំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងធ្វើការកោះហៅគូភាគីដែលអំឡុងពេលនោះ ត្រូវកំណត់ ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង លើកលែងតែមានករណីពិសេសដូចជាចៅក្រមទទួលបន្ទុកមាន

---

[88] លោកមេធាវី ប៉ោ ហ៊ុយ, នីតិវិធីជម្រះក្តីលើកទី១, ទំព័រទី ១។

[89] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[90] មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ធុរៈ ហើយមិនអាចរកចៅក្រមមកជំនួសបានសម្រាប់អំឡុងពេលនោះ ឬក៏មានហេតុការណ៍ដូចជាគ្រោះធម្មជាតិ ដែលតុលាការមិនអាចបំពេញភារកិច្ចបានជាដើម។[91]

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូរភាគីមកចូលរួម។ ជាគោលការណ៍ ដើម្បីចេញសាលក្រមទៅលើបណ្ដឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។[92]

បើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យលើភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ។[93]

**ករណីសិក្សាការរំលាយកិច្ចសន្យាលក់ទិញចលនវត្ថុ តាមផ្លូវតុលាការ**

អង្គហេតុ៖ លោក សុខ សំបូរ បានលក់រថយន្តម៉ាក Lexus 770 ឱ្យលោក មហា សំណាង ក្នុង តម្លៃ USD ៨០០,០០០ (ប្រាំបីសែនដុល្លារអាមេរិក) នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ហើយកិច្ចសន្យាលក់ទិញនេះ បានកំណត់ការបង់ប្រាក់ជាបីដំណាក់កាល ដែលមានដំណាក់កាលទី១ ធ្វើឡើងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដោយអ្នកទិញត្រូវបង់ប្រាក់ចំនួន USD ២០០,០០០ (ពីរសែនដុល្លារអាមេរិក)។ ដំណាក់កាលទី២ ធ្វើឡើងនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ ដោយអ្នកទិញត្រូវបង់ប្រាក់ចំនួន USD ៤៥០,០០០ (បួនសែនប្រាំម៉ឺនដុល្លារអាមេរិក) ហើយដំណាក់កាលទី៣ អ្នកទិញត្រូវបង់ប្រាក់ចំនួន USD ១៥០,០០០ (មួយសែនប្រាំម៉ឺនដុល្លារអាមេរិក)។[94]

ប៉ុន្តែលុះដល់ថ្ងៃដែលត្រូវបង់ដំណាក់កាលទី២ លោក មហា សំណាង មិនបានបង់ប្រាក់តាមការកំណត់នោះទេ ទោះបីជាលោក សុខ សំបូរ បានប្រើសិទ្ធិដាស់តឿនឱ្យលោក មហា សំណាង បង់ប្រាក់ក៏ដោយ ហើយលោក មហា សំណាង ថែមទាំងព្យាយាមគេចវេស និងពន្យារការបង់ប្រាក់ជានិច្ច។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ លោក សុខ សំបូរ បានធ្វើលិខិតដាស់តឿនឱ្យបង់ប្រាក់ និងជូនទៅកាន់លោក មហា សំណាង ប៉ុន្តែមិនមានការឆ្លើយតប ឬអនុវត្តករណីយកិច្ចបង់ប្រាក់ឡើយ។[95]

រហូតដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ លោក សុខ សំបូរ បានជូនដំណឹងទៅកាន់លោក មហា សំណាង អំពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា តាមរយៈលិខិតជូនដំណឹងចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០។ ប៉ុន្តែនៅថ្ងៃទី

[91] លោកមេធាវី ប៉ោ ហ៊ុយ ,នីតិវិធីជម្រះក្ដីលើកទី១ ,ទំព័រទី ៥១។

[92] មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[93] មាត្រា ១៨០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[94]សូមពិនិត្យនៅឧបសម្ព័ន្ធទី ១៖ គំរូកិច្ចសន្យាលក់ទិញចលនវត្ថុ

[95] សូមពិនិត្យនៅឧបសម្ព័ន្ធទី ២៖ គំរូលិខិតជូនដំណឹងអំពីការបង់ប្រាក់។

៣០ ខែមេសា ឆ្នាំ២០២០ លោក មហា សំណាង មិនបានទទួលស្គាល់ការបង្ហាញឆន្ទៈរំលាយរបស់លោក សុខ សំបូរ ឡើយ និងនៅតែបន្តពន្យារពេលសម្រាប់ការបង់ប្រាក់ដំណាក់កាលទី២ ទៀត។[96]

ហេតុដូច្នេះ តើលោក សុខ សំបូរ អាចធ្វើយ៉ាងណាទើបទទួលបានរថយន្តរបស់ខ្លួនត្រលប់មកវិញ តាមផ្លូវតុលាការ ?

## **ដំណោះស្រាយ**

ដូចបានបញ្ជាក់ខាងលើ និងសេចក្តីដែលមានកំណត់នៅក្នុងមាត្រា ៤០៩ ការរំលាយកិច្ចសន្យាអាចមានអានុភាព ក្រោយពេលភាគីដែលមានសិទ្ធិរំលាយ បានជូនដំណឹងអំពីការរំលាយទៅភាគីម្ខាងទៀតជាការរួចរាល់។ ប៉ុន្តែសម្រាប់ករណីរបស់ លោក សុខ សំបូរ ដែលកូនបំណុលមិនបានទទួលស្គាល់សិទ្ធិរំលាយរបស់ម្ចាស់បំណុល និងមិនព្រមអនុវត្តករណីយកិច្ចបដិទាន ហើយកូនបំណុលព្យាយាមបង្ខំឱ្យម្ចាស់បំណុលបន្តអនុវត្តករណីយកិច្ច។ ជាដំណោះស្រាយ លោក សំបូរ អាចប្រើប្រាស់នីតិវិធីបណ្តឹង តាមរយៈការដាក់ពាក្យបណ្តឹងដែលមានខ្លឹមសារនៃការទាមទារច្បាស់លាស់ អង្គហេតុចាំបាច់បញ្ជាក់ការទាមទារ និងអង្គហេតុជាមូលហេតុនៃការទាមទារត្រឹមត្រូវដូចខាងក្រោម៖

១.ខ្លឹមសារនៃការទាមទារ[97]

ខ្លឹមសារនៃការទាមទារក្នុងបណ្តឹង លោក សំបូរ ត្រូវសរសេរការទាមទារដូចខាងក្រោម៖

- ទាមទារឱ្យតុលាការចេញសេចក្តីសម្រេចដើម្បីបញ្ជាក់អំពីនត្ថិភាពនៃកិច្ចសន្យាលក់ទិញ
- ទាមទារឱ្យចុងចម្លើយ ប្រគល់រថយន្តម៉ាកLEXUS 770
- បង្គាប់ឱ្យចុងចម្លើយសងសំណងនៃការខូចខាតចំនួន ១០.០០០ (មួយម៉ឺនដុល្លារអាមេរិក)។
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

២.អង្គហេតុចាំបាច់បញ្ជាក់នូវការទាមទារ

ក.ការបង្កើតកិច្ចសន្យាលក់ទិញ

ខ.ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

គ.ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា

៣.ភស្តុតាងបញ្ជាក់ការទាមទារ

ក.កិច្ចសន្យាលក់ទិញចលនវត្ថុ

ខ.លិខិតជូនដំណឹងអំពីការបង់ប្រាក់

[96] សូមពិនិត្យនៅឧបសម្ព័ន្ធទី ៣៖ គំរូលិខិតជូនដំណឹងអំពីការរំលាយកិច្ចសន្យា។

[97] សូមពិនិត្យនៅឧបសម្ព័ន្ធទី ៤៖ គំរូពាក្យបណ្តឹង។

គ.លិខិតជូនដំណឹងអំពីការរំលាយកិច្ចសន្យា

ចំណាំ៖ ការទាមទាររបស់លោក សុខ សំបូរ ដែលសរសេរនៅក្នុងពាក្យបណ្តឹង មិនអាចទាមទារឱ្យតុលាការធ្វើការរំលាយកិច្ចសន្យាលក់ទិញបាន។ ប្រសិនបើលោក សុខ សំបូរ បានធ្វើការទាមទារឱ្យតុលាការធ្វើការរំលាយកិច្ចសន្យា បណ្តឹងរបស់លោក សុខ សំបូរ គឺជាបណ្តឹងខុសច្បាប់ ដោយហេតុថាការរំលាយកិច្ចសន្យាអាចមានអានុភាពក្រោយពេលភាគីបានអនុវត្តសិទ្ធិរំលាយតាមការជូនដំណឹងទៅភាគីម្ខាងទៀត។ ហេតុនេះ ក្នុងករណីដែលលោក សុខ សំបូរ បានធ្វើបណ្តឹងខុសច្បាប់ តុលាការអាចចេញដីកាសម្រេចលើកចោលបណ្តឹងនេះបាន។ ក្រោយពីលោក សុខ សំបូរ បានដាក់ពាក្យបណ្តឹងចូលតុលាការរួចហើយ នីតិវិធីនៃការពិនិត្យពាក្យបណ្តឹងនឹងត្រូវយកអនុវត្តដូចមានបង្ហាញនៅក្នុងចំណុចខាងលើ។

### **១.២.ការរំលាយកិច្ចសន្យាលក់ទិញក្រៅប្រព័ន្ធតុលាការ**

វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា ត្រូវបានបញ្ញត្តិនៅក្នុងមាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថាភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន។ ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ។ ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់លក្ខខណ្ឌបង្អង់បាន។

ផ្អែកតាមមាត្រានេះ សិទ្ធិរំលាយកិច្ចសន្យាត្រូវកើតឡើងក្នុងករណីលក្ខខណ្ឌដើម្បីរំលាយកិច្ចសន្យាត្រូវបានបំពេញ។ ចំពោះវិធីអនុវត្តសិទ្ធិរំលាយ គឺជាការបង្ហាញឆន្ទៈរបស់ភាគីម្ខាងទៀត ហើយអានុភាពនៃការរំលាយកិច្ចសន្យានឹងកើតឡើង នៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ក៏ប៉ុន្តែដូចដែលបានរៀបរាប់ខាងលើអញ្ចឹងថាបើសិនជាភាគីមិនទទួលស្គាល់អំពីសិទ្ធិរំលាយនោះទេ គឺមានតែចៅក្រមទេដែលជាអ្នកមានសិទ្ធិសម្រេចអំពីនត្ថិភាពនៃកិច្ចសន្យានោះ។ យើងសង្កេតឃើញថា ករណីដែលភាគីទទួលស្គាល់នូវសិទ្ធិរំលាយកិច្ចសន្យារបស់ភាគីទៀតទេ ទើបកិច្ចសន្យាអាចត្រូវបានរំលាយនៅក្រៅតុលាការបាន។ ការរំលាយកិច្ចសន្យាលក់ទិញក្រៅប្រព័ន្ធតុលាការនេះ គឺដើម្បីជួយសម្រួលដល់ភាគីនៃកិច្ចសន្យា ជួយសន្សំសំចៃប្រាក់កាស និងថែមទាំងកុំឱ្យមានការកកស្ទះសំណុំរឿងនៅក្នុងតុលាការទៀតផង។

ផ្អែកតាមមាត្រានេះ ការបង្ហាញឆន្ទៈរបស់ភាគី ចំពោះភាគីម្ខាងទៀតកើតមានក្រោមការជូនដំណឹង។ ជាទូទៅការជូនដំណឹងអំពីការរំលាយកិច្ចសន្យាលក់ទិញ អាចជ្រើសរើសមធ្យោបាយណាមួយក៏បាន ដែលភាគីមានសិទ្ធិរំលាយយល់ថា សមរម្យ និងងាយស្រួល ហើយអាចបន្សល់ទុកជាភស្តុតាងក្នុងការអះអាងតាមផ្លូវច្បាប់បាន ដូចជាលិខិតជូនដំណឹងអំពីការរំលាយកិច្ចសន្យាតាមលិខិតលាយលក្ខណ៍អក្សរ ឬសារអេឡិចត្រូនិច។ យោងតាមឧបសម្ព័ន្ធទី ៣ អ្នកលក់ជ្រើសរើសយកការជូនដំណឹងតាមលិខិតជាលាយលក្ខណ៍អក្សរដើម្បីរំលាយកិច្ចសន្យា ដោយនៅក្នុងលិខិតនោះត្រូវកំណត់អំពីអត្តសញ្ញាណរបស់ភាគីម្ខាងទៀត មូលហេតុនៃការរំលាយកិច្ច

សន្យា និងករណីយកិច្ចដែលភាគីម្ខាងទៀតត្រូវបំពេញឱ្យបានច្បាស់លាស់។ ក្នុងករណីដែលមានការបង្ហាញឆន្ទៈតាមមធ្យោបាយនៃការផ្ញើលិខិតជូនដំណឹងដូចក្នុងឧបសម្ព័ន្ធទី ៣ ប្រសិនបើភាគីម្ខាងទៀតមិនព្រមទទួលស្គាល់ ឬអនុវត្តករណីយកិច្ចដែលកើតមានក្រោយពេលរំលាយកិច្ចសន្យាទេ ភាគីដែលមានសិទ្ធិអាចដាក់ពាក្យបណ្ដឹងទៅតុលាការ ដោយយកលិខិតជូនដំណឹងអំពីការរំលាយ និងចាត់ទុកជាភស្តុតាងសម្រាប់សំអាងនៅក្នុងតុលាការបាន។

ផ្អែកតាមមាត្រានេះ ការរំលាយកិច្ចសន្យាអាចធ្វើឡើងក្រៅតុលាការ និងអាចបកស្រាយថា មានករណីដែលអាចធ្វើនៅក្នុងតុលាការ ប៉ុន្តែពុំមានន័យថាចាំបាច់ត្រូវការឱ្យតុលាការចេញសេចក្តីសម្រេច អំពីការរំលាយកិច្ចសន្យានេះទេ។ ហេតុនេះ ការអនុវត្តសិទ្ធិរំលាយមិនចាំបាច់មានការអន្តរាគមន៍ពីតុលាការឡើយ។

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាលក់ទិញ មិនអាចដកវិញបានទេ បើទោះបីជាបានរំលាយក្រៅប្រព័ន្ធតុលាការក៏ដោយ។ ប្រសិនបើភាគីមានសិទ្ធិបានអនុវត្តសិទ្ធិរំលាយ ហើយបដិសេធនិងដកការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាត្រលប់មកវិញ វានឹងនាំឱ្យមានភាពច្របូកច្របល់ដល់សកម្មភាពជំនួញរបស់ភាគីម្ខាងទៀត ហើយកិច្ចសន្យាដែលត្រូវបានរំលាយបែរជាមានអានុភាពវិញ។ បញ្ហាចោទឡើងថា ប្រសិនបើមានការព្រមព្រៀងគ្នាក្រៅតុលាការថាមិនរំលាយកិច្ចសន្យាវិញ តើអាចទទួលស្គាល់អានុភាពវិញយ៉ាងដូចម្ដេច?

តាមការជាក់ស្ដែង ពាក្យថា "មិនអាចដកវិញបានទេ" គឺសំដៅដល់ការមិនអាចដកវិញដោយឯកតោភាគីបានទេ ដែលបានន័យថា ប្រសិនបើភាគីដែលមានសិទ្ធិបានបង្ហាញឆន្ទៈរំលាយ ក្រៅប្រព័ន្ធតុលាការទៅភាគីម្ខាងទៀត ហើយភាគីដែលមានសិទ្ធិមិនអាចដកការបង្ហាញឆន្ទៈរំលាយដោយឯកឯងនោះទេ។ ប៉ុន្តែប្រសិនបើភាគីទាំងសងខាងបានព្រមព្រៀងគ្នា ឬផ្សះផ្សាគ្នា មិនរំលាយកិច្ចសន្យាវិញ មានន័យថាពួកគេបានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក។ ហើយយើងមិនអាចបកស្រាយបានថា "ទោះបីជាភាគីបានព្រមព្រៀងគ្នាមិនរំលាយកិច្ចសន្យាវិញក៏ដោយ ក៏មិនអាចដកការបង្ហាញឆន្ទៈរំលាយវិញបានទេ" ការបកស្រាយបែបនេះហាក់បីដូចជាចង្អៀត និងម៉ឺងម៉ាត់ពេក។ សរុបមកការបង្ហាញឆន្ទៈមិនអាចដកវិញបាន សំដៅទៅដល់ការមិនអាចដកវិញដោយឯកតោភាគីព្រោះគាត់បង្ហាញឆន្ទៈរំលាយតែម្ខាង ហើយមិនអាចដកវិញតែម្ខាងបានទេ។

ប៉ុន្តែគោលការណ៍ទូទៅនៃការបង្ហាញឆន្ទៈត្រូវយកមកអនុវត្ត ចំពោះការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ហេតុដូច្នេះ ការរំលាយកិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ឬការរំលាយកិច្ចសន្យាដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជាការភាន់ច្រឡំ ឬការគម្រាមកំហែង ជាអាទិ៍ អាចត្រូវបានលុបចោលនៅពេលក្រោយ។[98]

[98] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, គន្ថីទី៤, ទំព័រទី ១២៦, ឆ្នាំ២០១០។

ការបង្ហាញឆន្ទៈរំលាយ អាចដាក់លក្ខខណ្ឌបង្អង់បាន ដោយសារវានឹងផ្ដល់លក្ខណៈងាយស្រួលសម្រាប់ភាគីនៃកិច្ចសន្យា។ ឧទាហរណ៍៖ ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង ហើយភាគីម្ខាងទៀតដាស់តឿនឱ្យអនុវត្តកាតព្វកិច្ចដោយកំណត់ពេលជាក់លាក់ដើម្បីអនុវត្ត ប្រសិនបើមិនអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលកំណត់នោះ ភាគីម្ខាងទៀតនឹងអនុវត្តសិទ្ធិរំលាយកិច្ចសន្យា។ ឧទាហរណ៍នេះ គឺជាករណីដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ចំពោះការបង្កើតអានុភាពនៃការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា។

## ២.ការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញ

គូភាគីនៃកិច្ចសន្យា មានសិទ្ធិរំលាយកិច្ចសន្យានៅពេលលក្ខខណ្ឌដែលជាមូលហេតុខាងលើនៃការរំលាយត្រូវបានបំពេញ។ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយភាគីម្ខាងទៀតនៃកិច្ចសន្យាមានករណីយកិច្ចធ្វើបដិទាននូវតារាវកាលិកនៃកិច្ចសន្យាទៅឱ្យភាគីដែលមានសិទ្ធិរំលាយ។ ប៉ុន្តែសិទ្ធិរំលាយមិនមែនចេះតែបន្តមានអត្ថិភាពរហូតសូម្បីតែក្នុងស្ថានភាពមិនត្រឹមត្រូវ ឬមិនសមហេតុផលក្នុងការទទួលស្គាល់នោះទេ ហើយបញ្ហាចោទត្រង់ថា ប្រសិនបើវត្ថុដែលត្រូវធ្វើបដិទាននោះ ត្រូវបានបាត់បង់ ឬទទួលការខូចខាត តើសិទ្ធិរំលាយកិច្ចសន្យានៅមានអានុភាពទៀតដែរឬទេ ?

### ២.១.មូលហេតុដែលនាំឱ្យរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញ

តាមបញ្ញត្តិជាមូលដ្ឋាននៃក្រមរដ្ឋប្បវេណី សិទ្ធិរំលាយកិច្ចសន្យាលក់ទិញរបស់ភាគីត្រូវបានរលត់ក្រោមមូលហេតុចំនួនពីរ គឺការរលត់សិទ្ធិដោយសារសកម្មភាពរបស់ភាគី និងការរលត់សិទ្ធិដោយអាជ្ញាយុកាល។

#### ២.១.១.ការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញដោយសារសកម្មភាពរបស់ភាគី

ពេលដែលកិច្ចសន្យាត្រូវបានរំលាយ ភាគីមានករណីយកិច្ចធ្វើបដិទាននូវកម្មវត្ថុនៃកិច្ចសន្យាទៅឱ្យម្ចាស់ដើមវិញ។ ប៉ុន្តែប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាត្រូវបានបាត់បង់ ឬខូចខាត តើអានុភាពនៃការរំលាយកិច្ចសន្យានឹងអាចកើតមានដែរឬទេ ?

ត្បិតតែភាគីដែលមានសិទ្ធិរំលាយអាចប្រើប្រាស់សិទ្ធិរបស់ខ្លួននៅពេលណាក៏បាន ប៉ុន្តែស្មារតីនៃច្បាប់បានកំណត់លក្ខខណ្ឌមួយចំនួន ដើម្បីហាមឃាត់មិនឱ្យភាគីដែលមានសិទ្ធិអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយបំពានបានដែរ ហើយលក្ខខណ្ឌទាំងនោះកើតចេញពីចេតនា និងកំហុសរបស់អ្នកមានសិទ្ធិរំលាយជាចម្បង។ សិទ្ធិរំលាយត្រូវរលត់ ក្នុងករណីភាគីដែលមានសិទ្ធិរំលាយបានធ្វើឱ្យមានការខូចខាត ឬការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះវិញបានដោយចេតនា ឬធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬការផ្លាស់ទម្រង់ដោយចេតនា។[99]

[99] មាត្រា ៤១២ ចំណុចទី ១ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍៖ លោក ក បានលក់រថយន្តឱ្យលោក ខ។ នៅពេលដែលលោក ខ កំពុងប្រើប្រាស់ រថយន្តមានបញ្ហាបច្ចេកទេសកើតឡើង បណ្ដាលឱ្យលោក ខ ជួបគ្រោះថ្នាក់ ហើយរថយន្តត្រូវទទួលរងការខូចខាតខ្ទេចអស់ មិនអាចជួសជុលវិញបានឡើយ។ តើសិទ្ធិរំលាយកិច្ចសន្យារបស់លោក ខ ត្រូវរលត់ដែរឬទេ?

យោងទៅតាមមាត្រា ៤១២ ចំណុចទី១ យើងអាចសិក្សា និងសង្កេតមើលអង្គហេតុខាងលើ ជាពីរករណីចាំបាច់។ ករណីទី១៖ ប្រសិនរថយន្តដែលទទួលរងការខូចខាតក្រោមមូលហេតុនៃវិការៈកំបាំងរបស់កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ទោះវត្ថុនោះត្រូវបានខ្ទេចខូចខាតមិនអាចជួសជុលអំឡុងពេលដែលភាគីដែលមានសិទ្ធិរំលាយកំពុងប្រើប្រាស់ នោះសិទ្ធិរំលាយមិនត្រូវបានរលត់ឡើយ។ ប្រសិនបើរថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញខាងលើ មិនអាចបើកបរក្នុងល្បឿន ៥០គីឡូម៉ែត្រក្នុងមួយម៉ោងបានទេ ដោយបញ្ហាបច្ចេកទេស ហើយអ្នកលក់បានដឹងអំពីវិការៈកំបាំងនេះ ប៉ុន្តែមិនបានប្រាប់ និងបញ្ជាក់ទៅឱ្យអ្នកទិញបានដឹង។ លុះដល់ពេលអ្នកទិញបានប្រើប្រាស់ និងបើកបរក្នុងល្បឿន ៥១គីឡូម៉ែត្រក្នុងមួយម៉ោង បានធ្វើឱ្យរថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ផ្ទុះម៉ាស៊ីនឆេះគ្មានសល់។ ក្នុងករណីនេះ សិទ្ធិរំលាយរបស់អ្នកទិញមិនត្រូវបានរលត់ឡើយ ដោយហេតុថាការខូចខាត ឬការបាត់បង់កម្មវត្ថុនៃកិច្ចសន្យាពុំបានកើតចេញពីចេតនារបស់អ្នកទិញ។ ហេតុដូច្នេះ អ្នកទិញមានសិទ្ធិទាមទាររំលាយកិច្ចសន្យា និងទាមទារឱ្យអ្នកលក់ផ្តល់ប្រាក់ថ្លៃទិញ ហើយមិនហាមឃាត់ឱ្យអ្នកទិញទាមទារសំណងនៃការខូចខាតឡើយ។

ប៉ុន្តែក្នុងករណីទី២៖ ប្រសិនបើរថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ បានខូចខាត និងបាត់បង់ដោយសកម្មភាពជាចេតនារបស់អ្នកមានសិទ្ធិរំលាយវិញ នោះសិទ្ធិរំលាយនឹងត្រូវរលត់។ ឧទាហរណ៍៖ រថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញខាងលើ ត្រូវបានយកទៅកែកុន និងតំឡើងគ្រឿងថ្មីបន្ថែមដោយអ្នកទិញដែលខុសនឹងបច្ចេកទេសដើមនៃស្តង់ដាររបស់រថយន្ត ហើយអំឡុងពេលប្រើប្រាស់នោះ ដោយហេតុមកពីបញ្ហានៃបច្ចេកទេសនៃគ្រឿងតម្លើងថ្មី បានធ្វើឱ្យផ្ទុះឆេះរថយន្ត។ ក្នុងករណីនេះ សិទ្ធិរំលាយរបស់អ្នកទិញត្រូវបានរលត់ ដោយហេតុថាការខូចខាតនេះមិនមែនជាកំហុសរបស់អ្នកលក់ឡើយ ហើយដោយតាមមាត្រា ៤១២ ចំណុចទី១ ប្រសិនបើការខូចខាតកើតចេញពីកំហុសរបស់អ្នកមានសិទ្ធិរំលាយ ពេលនោះសិទ្ធិរំលាយនឹងត្រូវរលត់។

### ២.១.២.ការរលត់សិទ្ធិរំលាយកិច្ចសន្យាលក់ទិញដោយអាជ្ញាយុកាល

អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទាន មានអំឡុងពេល ០៥ ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។[100] តាមបញ្ញត្តិច្បាប់ ភាគីត្រូវអនុវត្តកាតព្វកិច្ចនៅពេលដែលកាលកំណត់សម្រាប់អនុវត្តបានមកដល់ ប្រសិនបើភាគីមិនបានអនុវត្តទាន់ពេលកំណត់ទេ ត្រូវចាត់ទុកថាភាគីយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដែលជាមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច។

[100] មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណី។

ដូច្នេះអាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា ត្រូវចាប់ផ្តើមគិតចាប់ពីពេលដែលមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច។

ប៉ុន្តែការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចមិនត្រូវបានកើតមានទេ ប្រសិនបើម្ចាស់បំណុលមិនបានដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច។ ប្រសិនបើម្ចាស់បំណុលបានដាស់តឿនអំពីការអនុវត្តកាតព្វកិច្ចរួចហើយ សិទ្ធិរំលាយអាចត្រូវបានកើតឡើងនៅពេលណាក៏បានដែរ។

ឧទាហរណ៍៖ លោក ក បានលក់រថយន្តឱ្យលោក ខ ដោយកំណត់យកថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ជាថ្ងៃអនុវត្តកាតព្វកិច្ចទាំងសងខាង។ លុះដល់ថ្ងៃកំណត់អ្នកលក់ បានអនុវត្តករណីយកិច្ចផ្តល់រថយន្ត ប៉ុន្តែអ្នកទិញបានសុំពន្យាពេល ២ខែ សម្រាប់ការអនុវត្តករណីយកិច្ចផ្តល់ថ្លៃទិញរបស់ខ្លួន។ ពីរខែកន្លងផុតទៅ អ្នកលក់បានដាស់តឿនអំពីការដល់ពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចទៅកាន់អ្នកទិញ អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយនឹងចាប់គិតពីពេលដែលមានការដាស់តឿននេះ។

ដូច្នេះអ្នកលក់មានរយៈពេល ៥ឆ្នាំ ក្រោយពីការដាស់តឿនដើម្បីអនុវត្តសិទ្ធិរំលាយរបស់ខ្លួន ប្រសិនបើអ្នកលក់មិនបានអនុវត្តសិទ្ធិក្នុងអំឡុងពេលនេះទេ សិទ្ធិរំលាយរបស់អ្នកលក់នឹងត្រូវបានរលត់។ ហេតុដូច្នេះទោះបីមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរពីភាគីម្ខាងទៀតក៏ដោយ តែបើផុតអាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយហើយ អ្នកលក់ក៏គ្មានសិទ្ធិដើម្បីរំលាយកិច្ចសន្យាក្រោមមូលហេតុខាងលើដែរ។ ប៉ុន្តែប្រសិនបើមានមូលហេតុនៃការរំលាយកិច្ចសន្យាថ្មីកើតមាន ច្បាប់មិនហាមឃាត់មិនឱ្យមានសិទ្ធិរំលាយថ្មីឡើយ។

### ២.២.អានុភាពនៃការរលត់សិទ្ធិរំលាយ

ក្នុងករណីដែលមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ភាគីមានសិទ្ធិរំលាយកិច្ចសន្យាក៏ពិតមែន ប៉ុន្តែសិទ្ធិនេះមិនមែនមានបិតបេរជានិរន្តឡើយ។ សិទ្ធិនេះត្រូវតែអនុវត្តក្នុងរយៈពេល ០៥ឆ្នាំ ក្រោយពីមានការមិនអនុវត្តកាតព្វកិច្ច។ ម្យ៉ាងវិញទៀតសិទ្ធិរំលាយ នឹងត្រូវរលត់ក្នុងករណីដែលអ្នកមានសិទ្ធិរំលាយបានធ្វើឱ្យបាត់បង់ ឬខូចខាតកម្មវត្ថុនៃកិច្ចសន្យា ឬបានកែប្រែរូបរាងនៃកម្មវត្ថុចម្បង ឬមិនអាចផ្តល់កម្មវត្ថុនៃកិច្ចសន្យាលក់ទិញត្រលប់មកវិញដោយចេតនា នោះសិទ្ធិរំលាយត្រូវរលត់។ ហេតុដូច្នេះក្នុងករណីដែលភាគីមានសិទ្ធិរំលាយបានអនុវត្តសិទ្ធិក្នុងអំឡុងពេលច្បាប់បានកំណត់ នោះនឹងនាំឱ្យមានអានុភាពនៃការរំលាយកិច្ចសន្យាដែលចងឱ្យមានការរលត់ករណីយកិច្ចដែលកំណត់ក្នុងកិច្ចសន្យា ករណីយកិច្ចបដិទាន និងការទាមទារសំណងនៃការខូចខាត។ ប៉ុន្តែប្រសិនបើភាគីមានសិទ្ធរំលាយ មិនបានអនុវត្តសិទ្ធិរំលាយរបស់ខ្លួនទាន់ពេលវេលាដែលច្បាប់បានកំណត់នោះទេ សិទ្ធិរំលាយនោះនឹងត្រូវរលត់ដោយអាជ្ញាយុកាល។ តើពេលដែលសិទ្ធិរំលាយត្រូវបានរលត់ មានអានុភាពបែបណាដែរ?

ជាក់ស្តែង អានុភាពនៃកិច្ចសន្យាត្រូវបានរលត់ ដែលបានន័យថាករណីយកិច្ចនៃកិច្ចសន្យាត្រូវបានរលត់ដូចគ្នា ហើយបង្កើតឱ្យមានករណីយកិច្ចបដិទាន និងសិទ្ធិទាមទារសំណងពីអ្នកដែលបំពាន។ ប៉ុន្តែក្នុងករណីដែលសិទ្ធិរំលាយត្រូវបានរលត់នោះ ភាគីដែលមានសិទ្ធិរំលាយមិនអាចអនុវត្តសិទ្ធិនេះបានទេ ដែលនាំអ្នកដែលមានសិទ្ធិរំលាយត្រូវបានរលត់សិទ្ធិរំលាយរបស់ខ្លួន និងមិនអាចទាមទារឱ្យភាគីម្ខាងទៀតធ្វើបដិទាននូវកម្មវត្ថុនៃកិច្ចសន្យានោះទេ។

សិទ្ធិទាមទារបដិទាន ដែលធ្វើឡើងក្រោមមូលហេតុនៃការរំលាយកិច្ចសន្យា មិនអាចធ្វើដោយឯកឯង ឬឯករាជ្យដោយគ្មានការអនុវត្តសិទ្ធិរំលាយបានឡើយ ដែលបានន័យថាក្នុងករណីដែលសិទ្ធិរំលាយត្រូវបានរលត់ក្រោមមូលហេតុនៃការផុតអាជ្ញាយុកាល ភាគីមិនអាចទាមទារបដិទានបានឡើយ។ ដូច្នេះ ភាគីត្រូវអនុវត្តសិទ្ធិទាមទារបដិទានរបស់ខ្លួន នៅមុនពេលដែលអាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយត្រូវផុត។ ដូចបញ្ជាក់ក្នុងឧទាហរណ៍ខាងលើ ក្រោយពីបានដាស់តឿនអ្នកទិញឱ្យអនុវត្តករណីយកិច្ចប្រគល់ប្រាក់ហើយ អ្នកលក់ត្រូវត្រៀមលក្ខណៈដើម្បីទាមទារឱ្យអ្នកទិញប្រគល់រថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រលប់មកវិញដូចគ្នា បើអាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយ ត្រូវបានបំពេញអ្នកលក់ក៏មិនអាចអនុវត្តសិទ្ធិទាមទារក្រោមរូបភាពនៃការរំលាយកិច្ចសន្យាផងដែរ។

ក្នុងន័យម៉្យាងទៀត ក្នុងករណីដែលសិទ្ធិរំលាយកិច្ចសន្យាត្រូវបានរលត់នោះ កិច្ចសន្យានឹងនៅតែបន្តមានអានុភាពជារៀងរហូត លើកលែងតែមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរក្រោមមូលហេតុផ្សេងថ្មីទៀត។

ឧទាហរណ៍៖ លោក ក បានទិញកៅអីសាឡុងចំនួន ០៥ ឈុត នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ពីលោក ខ ជាអ្នកលក់ និងបានប្រគល់ប្រាក់កក់ពាក់កណ្តាលនៃតម្លៃសរុបដោយសន្យាថានឹងប្រគល់ប្រាក់ឱ្យគ្រប់នៅពេល លោក ខ ប្រគល់កៅអីសាឡុងគ្រប់ដែរត្រឹមថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៤។ ប៉ុន្តែអ្នកលក់មិនបានប្រគល់កៅអីសាឡុងតាមពេលកំណត់ឡើយ។ លោក ក ក្រោយពីបានដឹងរឿងនេះក៏មិនខ្វាយខ្វល់ដែរ ដោយបានបណ្តោតបណ្តោយរហូតដល់ឆ្នាំ២០១៩ ទើបមានការចង់ប្តឹងលោក ខ ឱ្យប្រគល់ប្រាក់កក់ស្មើនឹងពាក់កណ្តាលត្រលប់មកវិញ និងទាមទាររំលាយកិច្ចសន្យា។ ប៉ុន្តែសិទ្ធិរំលាយរបស់លោក ក ត្រូវបានរលត់ដោយសារអាជ្ញាយុកាលបាត់ទៅហើយ ម៉្យាងទៀតសិទ្ធិទាមទារឱ្យធ្វើបដិទានក៏ត្រូវបានរលត់ទៅតាមសិទ្ធិរំលាយកិច្ចសន្យាដែរ។

# ជំពូកទី៣៖ អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញ

## ១.ទ្រឹស្តីអានុភាពនៃការរំលាយកិច្ចសន្យា

ជាគោលការណ៍នៅក្នុងបទប្បញ្ញត្តិទូទៅ អានុភាពនៃការរំលាយកិច្ចសន្យា មាត្រា៤១១ បានចែងមានអត្ថន័យដូចខាងក្រោម៖[101]

- ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត
- គូភាគីមានកាតព្វកិច្ចក្នុងការធ្វើបដិទានឡើងវិញទៅស្ថានភាពដើមរបស់ខ្លួន
- ភាគីត្រូវសងប្រាក់ដែលភ្ជាប់មកជាមួយនឹងការប្រាក់ ឬបង្វិលវត្ថុជាមួយនឹងផលប្រយោជន៍ដែលបានទទួលពីវត្ថុនោះផង។

បើទោះបីជាមាត្រា ៤១១ បានកំណត់ពីអានុភាពទាំងនេះនឹងកើតឡើង ក្រោយពីមានការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាពីភាគីក៏ដោយ ក៏ប៉ុន្តែយើងមិនឃើញមានបញ្ញត្តិណាមួយដែលច្បាប់បានចែងពីមូលហេតុដែលនាំឱ្យកើតមាននូវអានុភាពទាំងនេះឡើយ។ ជាក់ស្តែងអានុភាពនៃកិច្ចសន្យាត្រូវបានគេរកឃើញនូវគំនិត ០២ (ពីរ) ផ្សេងគ្នា ដែលគំនិតទី០១ និយាយពីការទទួលស្គាល់នូវអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា និងគំនិតទី០២ និយាយអំពីការមិនទទួលស្គាល់នូវអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា។ ហើយមូលហេតុដែលបង្កើតនូវគំនិតទាំង០២ (ពីរ) នេះ គឺមានភាពប្រទាក់ក្រឡាគ្នាក្នុងការអនុវត្តទៅតាមប្រភេទនៃកិច្ចសន្យា (កិច្ចសន្យាអនុវត្តម្តង និងកិច្ចសន្យាអនុវត្តបន្តបន្ទាប់) និងមានគោលដៅក្នុងការការពារទៅលើតតិយជនផងដែរ។

ប៉ុន្តែចំណុចនេះមូលហេតុនៃការការពារតតិយជន នឹងមិនត្រូវយកមកធ្វើការបកស្រាយឡើយ ដោយសារតែយើងនៅមានចំណុចបន្ទាប់ដែលពាក់ព័ន្ធនឹងអានុភាពចំពោះតតិយជន។

ចំពោះកិច្ចសន្យាអនុវត្តម្តងចប់ តម្រូវឱ្យមានអានុភាពប្រតិសកម្មនៅពេលដែលមានការរំលាយកិច្ចសន្យា (មាត្រា ៤១១ កថាខណ្ឌទី១) រីឯកិច្ចសន្យាដែលអនុវត្តជាបន្តបន្ទាប់ គឺមិនមានអនុភាពប្រតិសកម្មជាចាំបាច់នោះទេ។ ឧទាហរណ៍៖ កិច្ចសន្យាភតិសន្យា នៅពេលដែលមានការរំលាយកិច្ចសន្យាកើតឡើង គឺមិនមានអានុភាពប្រតិសកម្មទេ មានតែអានុភាពឆ្ពោះទៅអនាគតប៉ុណ្ណោះ។ ជាក់ស្តែងតាមបញ្ញត្តិមាត្រា ៦១៧ នៃក្រមរដ្ឋប្បវេណី ប្រសិនបើភតិបតី និងភតិកៈ បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាដោយមានរយៈពេលជួល៣ឆ្នាំ តែនៅពេលដែលភតិកៈបានអនុវត្តកាតព្វកិច្ចបាន២ឆ្នាំ ក៏ជួបវិបត្តិផ្នែកសេដ្ឋកិច្ច ហើយមានការខកខានក្នុងការបំពេញកាតព្វកិច្ចបង់ថ្លៃជួលរបស់ខ្លួន ជារឿយៗ។ ទើបភតិបតីសម្រេចចិត្តរំលាយកិច្ចសន្យានេះចោល។ ដូចនេះប្រសិនបើកិច្ចសន្យានេះមានអានុភាពប្រតិសកម្ម យើងឃើញថាភតិបតីត្រូវតែសងត្រឡប់មកវិញនូវថ្លៃឈ្នួលខ្លួនទទួលបានពី

[101] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគទី១, ទំព័រ ១៨៤។

ភតិកៈរយៈពេល០២ឆ្នាំនោះ ព្រោះក្រោយការរំលាយកិច្ចសន្យា គឺគេចាត់ទុកថាកិច្ចសន្យានឹងមិនមានតាំងពីដំបូង ឯភតិបតីវិញមានសិទ្ធិក្នុងការទាមទារឱ្យភតិកៈបដិទានផ្ទះឱ្យដូចដើមវិញ ព្រមទាំងអាចមានសំណងនៃការខូចខាតដោយសារការបំពាន។

### ១.១.គោលការណ៍ប្រតិសកម្ម

តាមរយៈគោលការណ៍មួយនេះ នៅពេលដែលកិច្ចសន្យាត្រូវបានរំលាយ វាត្រូវបានគេចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង។ ដូច្នេះប្រសិនបើភាគីបានទទួលតាវកាលិកនៅមុនពេលរំលាយ គាត់ត្រូវតែធ្វើបដិទានឡើងវិញ ត្រឡប់មកទៅស្ថានភាពដើមរបស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ។[102]

ឧទាហរណ៍៖ ក្នុងកិច្ចសន្យាលក់ទិញម៉ូតូ ដែល ក បានទិញម៉ូតូមួយគ្រឿងពី ខ ហើយបានព្រមព្រៀងគ្នាថា អ្នកទាំងពីរ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅពេលព្រមគ្នា (ក ប្រគល់ប្រាក់ ឯ ខ ត្រូវប្រគល់ម៉ូតូ)។ លុះដល់កាលបរិច្ឆេទអនុវត្ត ស្រាប់តែភាគី ក បានអនុវត្តកាតព្វកិច្ចខ្លួនក្នុងការប្រគល់ប្រាក់ទៅឱ្យ ខ តែ ភាគី ខ បានស្នើសុំប្រគល់ម៉ូតូនោះក្នុងរយៈពេលមួយខែក្រោយ ដោយសារតែមានបញ្ហាក្នុងការដឹកជញ្ជូន។ ក្រោយមកដល់ថ្ងៃកំណត់ដែល ខ ត្រូវអនុវត្តកាតព្វកិច្ច ស្រាប់តែ ខ មិនអាចអនុវត្តបានដោយសារតែម៉ូតូនោះមិនទាន់មកដល់ពេលនោះ ក បានសម្រេចចិត្តក្នុងការរំលាយកិច្ចសន្យា។ ដូចនេះតាមរយៈគំនិតនៃការទទួលស្គាល់នូវអានុភាពប្រតិសកម្ម នាំឱ្យ ក អាចទាមទារប្រាក់ដែលគាត់បានប្រគល់ជូន ខ នោះមកវិញតាមដោយផ្អែកតាមសេចក្តីចម្រើនដោយឥតហេតុ។

ឧទាហរណ៍៖ ករណី ខ បានទិញស្រូវ១០០គីឡូក្រាម ពី ក ក្នុងតម្លៃ១០០$ (មួយរយដុល្លារអាមេរិក)។ ក្រោយមកនៅពេលដែល ខ បានយកស្រូវនោះទៅប្រើប្រាស់អស់ចំនួន៣០គីឡូក្រាម ក បានរំលាយកិច្ចសន្យាដោយសារតែ ខ បានមិនបានអនុវត្តកាតព្វកិច្ចក្នុងការប្រគល់ប្រាក់ថ្លៃទិញទៅឱ្យ ក ។ ដូចនេះតាមគំនិតទី១នេះ ខ ត្រូវសងស្រូវនោះមកវិញ ដោយកម្រិតត្រឹមតែ៧០គីឡូក្រាម (តាមមាត្រា ៧៣៦ កថាខណ្ឌទី១)។ ក៏ប៉ុន្តែ នៅក្នុងមាត្រា ៤១១ កថាខណ្ឌទី២ បានតម្រូវឱ្យភាគីធ្វើការបដិទានត្រឡប់ទៅស្ថានភាពដើមវិញ ដូចនេះ ខ ត្រូវសងស្រូវដែលបានប្រើប្រាស់ចំនួន៣០គីឡូក្រាមនោះមកវិញ ដែលមានគុណភាពដូចដើម ឬសងប្រាក់ដែលស្មើនឹងតម្រូវនៃស្រូវ៣០គីឡូក្រាមនោះ។

ដូច្នេះតាមគំនិតនៃការទទួលស្គាល់អានុភាពប្រតិសកម្ម ទំហំកាតព្វកិច្ចដែលត្រូវធ្វើបដិទាន ត្រូវបានពន្លាតចាប់ពី "ផលប្រយោជន៍ ទៅត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន" (មាត្រា ៧៣៦ កថាខណ្ឌទី១) ទៅដល់ "ការធ្វើបដិទានទៅស្ថានភាពដើមរបស់ភាគី" (មាត្រា ៤១១ កថាខណ្ឌទី២)។[103]

---

[102] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, ទំព័រទី ១៨១។
[103] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, ទំព័រទី ១៨៥។

ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធិ៖ តាមគោលការណ៍ប្រតិសកម្ម ការផ្ទេរកម្មសិទ្ធិនឹងត្រូវបានរលត់ដោយប្រតិសកម្ម ព្រោះការរំលាយមានអានុភាពប្រតិសកម្ម។[104] ឧទាហរណ៍៖ ក បានធ្វើកិច្ចសន្យាលក់ម៉ូតូទៅឱ្យ ខ ហើយ ក ព្រមទាំងបានប្រគល់ម៉ូតូទៅឱ្យ ក ជាមុនទៀត ដោយសារតែយល់ថាជាអ្នកស្គាល់គ្នា ហើយអ្នកទាំងពីរបានព្រមព្រៀងគ្នា ដោយឱ្យ ខ ប្រគល់ប្រាក់មកឱ្យវិញនៅរយៈពេល០២ខែទៀត។ លុះក្រោយមក ខ មិនបានអនុវត្តកាតព្វកិច្ច តាមកាលកំណត់ឡើយ ទោះបីជា ក បានដាស់តឿនយ៉ាងណាក្តី ទើប ក បានរំលាយកិច្ចសន្យាខាងលើ។ ដូច្នេះពេលដែលការរំលាយមានអានុភាពប្រតិសកម្ម នោះ គេចាត់ទុកថា ខ មិនមែនជាម្ចាស់កម្មសិទ្ធិតាំងពីដំបូង មានន័យថា កម្មសិទ្ធិលើម៉ូតូនោះគឺមិនត្រូវបានផ្ទេរពី ក ទៅ ខ នោះទេ គឺ ក នៅតែជាកម្មសិទ្ធិករពីដំបូង ដែលអាចប្រើសិទ្ធិលើកម្មសិទ្ធិក្នុងការទាមទារឱ្យ ខ ប្រគល់ម៉ូតូមួយគ្រឿងនោះមកវិញ។

### ១.២.គោលការណ៍មិនប្រតិសកម្ម

ចំពោះគោលការណ៍នេះ ការរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថា គ្មានអានុភាពប្រតិសកម្ម។ ដូច្នេះសិទ្ធិលើបំណុល និងកាតព្វកិច្ចដើមត្រូវបានប្តូរទៅជាសិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់គូភាគីវិញ។[105]

ឧទាហរណ៍៖ ប្រសិនបើ ក ជាអ្នកលក់ម៉ូតូ បានរំលាយកិច្ចសន្យាលក់ទិញម៉ូតូរវាងខ្លួន និង ខ។ ដោយសារ ខ មិនអនុវត្តកាតព្វកិច្ចប្រគល់ប្រាក់តាមកាលកំណត់មកឱ្យខ្លួន ក្រោយពេលដែលខ្លួនបានប្រគល់ម៉ូតូឱ្យទៅប្រើប្រាស់បាន០១(មួយ)ខែ ទៅ០២ (ពីរ)ខែ ហើយនោះ។ តាមគោលការណ៍មិនប្រតិសកម្ម ខ នឹងមិនត្រូវបានគេចាត់ទុកថាជាគ្មានទទួលបានកម្មសិទ្ធិតាំងពីដំបូងឡើយ ផ្ទុយទៅវិញ ខ ត្រូវមានកាតព្វកិច្ចថ្មីក្នុងការប្រគល់ម៉ូតូទៅឱ្យ ក វិញ ដោយផ្អែកលើការរំលាយកិច្ចសន្យា។

តាមរយៈគោលការណ៍នេះ គឺចង់បង្ហាញថា កាតព្វកិច្ចដែលបានអនុវត្តរួចហើយ គឺមានសុពលភាព ដែលមិនអាចក្លាយទៅជាសេចក្តីចម្រើនឥតហេតុឡើយ។ ហើយគេយកវាមកអនុវត្តតែចំពោះកាតព្វកិច្ចណាដែលមិនទាន់បានអនុវត្ត ដោយវានឹងគ្មានអត្ថិភាពទៀតទេនាពេលអនាគត។

ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធ៖ ចំពោះគោលការណ៍នេះ គឺកម្មសិទ្ធិត្រូវបានធ្វើបដិទានពី ខ ទៅ ក ជាស្វ័យប្រវត្តិដោយសារតែការរំលាយកិច្ចសន្យា។ ឧទាហរណ៍៖ ខ ត្រូវមានកាតព្វកិច្ចក្នុងការប្រគល់ត្រឡប់មកវិញ ប្រសិនបើគាត់បានទទួលវត្ថុចរាល់ (ម៉ូតូ) ដោយសារពេលបង្កើតកិច្ចសន្យា កម្មសិទ្ធិត្រូវបានផ្ទេរទៅអ្នកទិញ (ខ) ហើយនៅពេលមានការរំលាយកិច្ចសន្យានោះ ខ ត្រូវមានករណីយកិច្ចថ្មីក្នុងការបដិទានទៅឱ្យអ្នកលក់ (ក) វិញដោយស្វ័យប្រវត្តិ ដែលនេះជាអានុភាពនៃការរំលាយកិច្ចសន្យា។

104 សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, ទំព័រទី ១៨៥។

105 សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, ទំព័រទី ១៨៥។

ជារួមមកលក្ខណៈនៃអានុភាពទាំងពីរចំពោះការរំលាយកិច្ចសន្យានេះ គឺសុទ្ធតែតម្រូវឱ្យភាគីដែលទទួលបាននូវវត្ថុចរាល់ហើយ ត្រូវតែធ្វើបដិទានត្រឡប់ឱ្យទៅម្ចាស់ដើមវិញ (ទៅតាមស្ថានភាពដើម) គ្រាន់តែគោលការណ៍ដែលទទួលស្គាល់អានុភាពប្រតិសកម្ម បានកំណត់ថាកម្មសិទ្ធិនឹងមិនត្រូវបានផ្ទេរពីម្ចាស់ដើមឡើយ ហើយគាត់អាចទាមទារមកវិញ ដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ ទៅតាមបញ្ញត្តិនៃសេចក្តីចម្រើនឥតហេតុ។ រីឯគោលការណ៍ដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម គេកំណត់ឱ្យភាគីដែលទទួលបានវត្ថុនោះ មាននូវកាតព្វកិច្ចថ្មីត្រូវតែប្រគល់ត្រឡប់មកវិញ (បដិទាន) នូវវត្ថុនោះ ដោយម្ចាស់ដើមមាននូវសិទ្ធិទាមទារ។ ម្យ៉ាងទៀតគោលការណ៍ទាំងពីរនេះមិនត្រូវបានកំណត់ច្បាស់ទៅលើការរំលាយកិច្ចសន្យា ដូចករណីអានុភាពទៅលើការលុបចោលឡើយ (ការលុបចោលមានអានុភាពប្រតិសកម្ម មាត្រា ៣៥៨ កថាខណ្ឌទី២) ព្រោះតែកិច្ចសន្យា គឺមានវិការៈតាំងពីដំបូងម្ល៉េះ ផ្ទុយពីការរំលាយកិច្ចសន្យា គឺមានសុពលភាពពេញលេញ តែត្រូវបានរំលាយដោយសារតែមានអត្ថិភាពនៃមូលហេតុបំពានកិច្ចសន្យាដែលប៉ះពាល់ទៅដល់ភាគីម្ខាងទៀតតែប៉ុណ្ណោះ។

## ២.អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញចំពោះភាគី

ដោយឡែកនៅក្នុងកិច្ចសន្យាពិសេសដូចជាកិច្ចសន្យាលក់ទិញជាដើម ពេលដែលមានការរំលាយកិច្ចសន្យាកើតឡើង វាបង្កើតបាននូវអានុភាពទៅលើភាគី មិនខុសគ្នាពីគោលការណ៍ទូទៅប៉ុន្មានដែរ ក្នុងនោះមាន ២.១.ការរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា និង២.២.ករណីយកិច្ចធ្វើបដិទាន។

### ២.១.ការរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា

ការរំលាយកិច្ចសន្យាមានអានុភាពនាំឱ្យភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងសំណងនៃការខូចខាត។[106] មានន័យថាប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយ ចំណងនៃកិច្ចសន្យានោះនឹងត្រូវរលត់នូវរាល់កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតមាននៅក្នុងកិច្ចសន្យា ជាហេតុនាំឱ្យភាគីរួចផុតពីករណីយកិច្ចទាំងនោះ ប៉ុន្តែនៅក្នុងករណីរំលាយកិច្ចសន្យា ដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច ការសងសំណងខូចខាតរបស់កូនបំណុលនៅតែមានអានុភាព ព្រោះតែសកម្មភាពរបស់កូនបំណុលបានធ្វើឱ្យប៉ះពាល់ទៅដល់ភាគីម្ខាងទៀតនៃកិច្ចសន្យា។

### ២.២.ករណីយកិច្ចក្នុងការធ្វើបដិទាន

បន្ទាប់ពីចំណងករណីយកិច្ចរវាងភាគីត្រូវបានរលត់នោះ មានន័យថាកិច្ចសន្យានោះបានបញ្ចប់ ដូចនេះភាគីគ្មានកាតព្វកិច្ចឱ្យគ្នាតទៅទៀតទេ។ តែប្រសិនបើភាគីបានទទួលតាវកាលិកមួយភាគ ឬទាំងអស់រួចរាល់ហើយ ភាគីនោះមានករណីយកិច្ចសងនូវតាវកាលិកនោះទៅឱ្យភាគីដែលជាម្ចាស់ដើមវិញ ដើម្បីឱ្យភាគីដែលជា

[106] មាត្រា ៤១១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

ម្ចាស់កម្មសិទ្ធិករដើមទទួលបដិទានឡើងវិញ ដោយសារការរំលាយកិច្ចសន្យា។[107] ជាគោលការណ៍ ភាគីត្រូវមានករណីយកិច្ចក្នុងការស្តារត្រឡប់ទៅរកស្ថានភាពដើមមុនពេលដែលមានកិច្ចសន្យា ដែលជាហេតុថាប្រសិនបើភាគីណាម្ខាងបានទទួលតាវកាលិកតែមួយផ្នែក ឬទាំងមូលរួចហើយនោះ វាចាំបាច់ណាស់ដែលគាត់ត្រូវតែប្រគល់តាវកាលិកនោះទៅឱ្យភាគីម្ខាងទៀតវិញ ដោយសារតែមានការរំលាយកិច្ចសន្យាកើតឡើង។ ឧ.បើអ្នកលក់បានទទួលប្រាក់កក់ពីអ្នកទិញ ក្រោយមកគាត់បានរំលាយកិច្ចសន្យា នោះគាត់ត្រូវតែមានកាតព្វកិច្ចក្នុងការសងប្រាក់កក់នោះទៅវិញ។

នៅពេលដែលសិក្សាមកដល់ចំណុចនេះ យើងឃើញថាបញ្ញត្តិដែលចែងពីករណីយកិច្ចធ្វើបដិទានមិនត្រឹមតែឱ្យភាគីសងត្រឡប់តែតាវកាលិកវិញគ្រប់គ្រាន់នោះទេ ហេតុនេះហើយក្រមរដ្ឋប្បវេណីបានកំណត់ពីលក្ខខណ្ឌមួយចំនួនសំរាប់តម្រូវឱ្យភាគីអនុវត្តពេលដែលភាគីត្រូវធ្វើបដិទានដោយសារការរំលាយកិច្ចសន្យា ដែលលក្ខខណ្ឌនោះមាន៖ ២.២.១.ការអនុវត្តព្រមគ្នានូវករណីយកិច្ចធ្វើបដិទាន, ២.២.២.ទំហំនៃករណីយកិច្ចធ្វើបដិទាន និង២.២.៣.ករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬខាតបង់។

### ២.២.១.ការអនុវត្តព្រមគ្នានូវករណីយកិច្ចធ្វើបដិទាន

ករណីដែលភាគីនៅក្នុងកិច្ចបានសន្យាបានធ្វើការប្រគល់នូវតាវកាលិកមួយភាគ ឬទាំងអស់ទៅឱ្យគ្នារួចហើយនោះ ប្រសិនបើមានការរំលាយកិច្ចសន្យាកើតឡើង នោះភាគីទាំងសងខាងត្រូវមានករណីយកិច្ចទៅវិញទៅមកក្នុងការធ្វើបដិទាន (ប្រគល់ត្រឡប់នូវតាវកាលិកទៅឱ្យម្ចាស់ដើមវិញ) ដោយធ្វើការអនុវត្តនៅពេលជាមួយគ្នា។[108]

ឧទាហរណ៍៖ ប្រសិនបើអ្នកលក់បានប្រគល់រថយន្តទៅឱ្យអ្នកទិញ ហើយអ្នកទិញបានប្រគល់ប្រាក់ខ្លះហើយនោះ នៅពេលមានការរំលាយកិច្ចសន្យាកើតឡើង អ្នកលក់ត្រូវធ្វើការប្រគល់ប្រាក់ដែលអ្នកលក់បានទទួលប្រគល់ជូនមកឱ្យអ្នកទិញវិញ ឯអ្នកទិញត្រូវធ្វើការប្រគល់រថយន្តទៅឱ្យអ្នកលក់វិញ ដោយអនុវត្តនៅពេលព្រមគ្នា។

### ២.២.២.ទំហំនៃករណីយកិច្ចធ្វើបដិទាន

ករណីដែលភាគីគាត់ធ្វើការសងត្រឡប់មកវិញនូវតាវកាលិក គាត់មិនត្រូវសងតែតាវកាលិកដែលគាត់ទទួលបានពីកិច្ចសន្យាប៉ុណ្ណោះទេ ព្រោះក្រមរដ្ឋប្បវេណីបានពន្លាតទៅដល់ទំហំមួយដែលក្នុងករណីយកិច្ចសងជាប្រាក់ គឺគាត់ត្រូវសងមកវិញដោយភ្ជាប់ជាមួយនឹងការប្រាក់ដែលគិតចាប់ពីថ្ងៃដែលគាត់បានទទួលប្រាក់ដើមនោះ រីឯករណីយកិច្ចបង្វិលវត្ថុ ឬជាតាវកាលិកផ្សេងទៀតដែលខ្លួនបានទទួល នៅពេលមានការរំលាយកិច្ចសន្យា

[107] មាត្រា ៤១១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។
[108] មាត្រា ៤១១ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

គាត់ត្រូវសងទាំងផលដែលបានទទួលពីវត្ថុនោះ ឬតាវកាលិកនោះផងដែរ។[109] តាមន័យនេះ យើងឃើញថាការធ្វើបដិទានមិនត្រឹមតែស្តារត្រឡប់ទៅរកនូវស្ថានភាពដើមរបស់ភាគីទេ តែក្រមរដ្ឋប្បវេណីបានពង្រីកទៅដល់ស្ថានភាពដែលអាចកើតមានថា ករណីប្រសិនបើភាគីមិនបានបង្កើតកិច្ចសន្យានោះ តើនឹងមានអ្វីកើតឡើងនៅចន្លោះពេលដែលបង្កើត រហូតដល់ពេលរំលាយកិច្ចសន្យានោះ។ ម្យ៉ាងទៀតប្រសិនបើតម្លៃនៃកម្មវត្ថុ មានការផ្លាស់ប្តូរខ្លាំងរវាងពេលបង្កើត និងពេលរំលាយកិច្ចសន្យា គេអាចយកបញ្ញត្តិដែលពាក់ព័ន្ធនឹងការសងតាមរយៈការទាមទារសំណងនៃការខូចខាតមកប្រើប្រាស់បានផងដែរ។

**ករណីសិក្សា**

ឧទាហរណ៍៖ លោក ក បានធ្វើការកក់ប្រាក់ចំនួន១០០០០$(មួយម៉ឺនដុល្លារអាមេរិក) ជាថ្លៃក្នុងការទិញរថយន្តមួយគ្រឿង ដែលរថយន្តនោះមានតម្លៃ៥០០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ពី ខ។ ដោយ ខ បានសន្យាថា រយៈពេល០២ខែក្រោយរថយន្តនឹងមកដល់ឃ្លាំង។ លុះដល់ថ្ងៃកំណត់ដែល ខ ត្រូវមកទទួលរថយន្តពីឃ្លាំង ខ ស្រាប់តែ ខ មិនមានរថយន្តប្រគល់ជូនទៅ ក ដោយសារតែកម្មវត្ថុដែលជារថយន្ត ក ធ្វើការកម្ម៉ង់ទិញ គឺខ មិនអាចធ្វើការដេញថ្លៃទិញបាន។ ដូចនេះ ក ក៏សម្រេចធ្វើការរំលាយកិច្ចសន្យាខាងលើ។

ក.តើបន្ទាប់ពី ក បានរំលាយកិច្ចសន្យា តើ ខ មានករណីយកិច្ចធ្វើអ្វី ?

ខ.ប្រសិនបើ ខ ធ្វើការសងប្រាក់ទៅ ក វិញ តើ ខ គ្រាន់តែសងប្រាក់ថ្លៃកក់នោះគ្រប់គ្រាន់ដែរ ឬទេ ?

**ដំណោះស្រាយ**

ក.យើងបានសិក្សារួចមកហើយថា នៅពេលដែលមានការរំលាយកិច្ចសន្យា ភាគីត្រូវមានករណីយកិច្ចក្នុងការប្រគល់ត្រឡប់ទៅតាវកាលិកមកវិញ ដើម្បីឱ្យភាគីម្ខាងទៀតធ្វើបដិទានឡើងវិញ។ ហេតុនេះ ពេលដែល ក ធ្វើការរំលាយកិច្ចសន្យា ខ ត្រូវមានករណីយកិច្ចចាំបាច់សម្រាប់ធ្វើការសងប្រាក់កក់ដែល ក បានបង់ជូនគាត់ចំនួន ១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) នោះទៅវិញ។

ខ.ករណីនេះ ការប្រគល់ជូនត្រឹមតែប្រាក់កក់ចំនួន១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) ទៅឱ្យ ក វិញ គឺមិនទាន់ត្រូវបានចាត់ទុកថា ខ បានអនុវត្តករណីយកិច្ចក្នុងការធ្វើបដិទានរួចរាល់ហើយនោះទេ។ ដោយសារតែក្រមរដ្ឋប្បវេណីបានពន្លាតឱ្យ ខ ត្រូវធ្វើការសងដោយភ្ជាប់មកជាមួយនឹងការប្រាក់ ឬផលប្រយោជន៍ដែលកើតមានមកពីតាវកាលិកនោះ គិតចាប់ពីថ្ងៃដែលបានទទួលផងដែរ។ ដូចនេះ ខ ត្រូវសងមកជាមួយនឹងការប្រាក់ក្នុងអំឡុងពេល០២ខែ(ចាប់ពីថ្ងៃដែល ក និង ខ បានព្រមព្រៀងបង្កើតកិច្ចសន្យា) មកឱ្យ ក វិញ ដោយអាចគណនាតាមមាត្រា ៣១៨ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់)។

[109] មាត្រា ៤១១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។

## ២.២.៣.ករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់

ជាគោលការណ៍នៅពេលដែលមានការរំលាយកិច្ចសន្យាកើតឡើង ភាគីទាំងសងខាងមានករណីយកិច្ចក្នុងការធ្វើបដិទានទៅវិញទៅមក ប៉ុន្តែបញ្ហាអាចចោទមានឡើងថា សិទ្ធិរំលាយកិច្ចសន្យាអាចអនុវត្តបានដែរ ឬទេនៅពេល ដែលភាគីមិនអាចប្រគល់នូវកម្មវត្ថុនោះវិញបាន ដោយសារតែកម្មវត្ថុនោះត្រូវបានខូចខាត ឬបាត់បង់។ ដោយឡែកនៅក្នុងមាត្រា ៤១២ បានកំណត់ពីដំណោះស្រាយក្នុងបញ្ហានេះដោយៈ

\+ នៅពេលដែលកម្មវត្ថុនោះខូចខាត ឬបាត់បង់ដោយសារចេតនារបស់អ្នកមានសិទ្ធិរំលាយ ហើយមិនអាចសងវិញបាននោះ អ្នកមានសិទ្ធិរំលាយមិនអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាបានទេ (សិទ្ធិរំលាយត្រូវបានរលត់)។[110]

ឧទាហរណ៍៖ ករណីដែលអ្នកទិញរថយន្តរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុរថយន្តនោះមានវិការៈ។ ប្រសិនបើអ្នកទិញនោះបានធ្វើឱ្យខូចខាតដោយចេតនាដល់រថយន្តដែលខ្លួនត្រូវប្រគល់វិញ បើខ្លួនមានរំលាយកិច្ចសន្យា នោះនឹងត្រូវបាត់បង់សិទ្ធិរំលាយតែករណីដែលរថយន្តនោះខូចខាតមកពីកំហុស) បណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ គាត់នៅតែមានសិទ្ធិរំលាយដដែល ព្រោះតែគ្រោះថ្នាក់ចរាចរណ៍មិនមែនកើតមកពីចេតនារបស់អ្នកទិញឡើយ។(

\+ នៅពេលដែលកម្មវត្ថុនោះខូចខាត ឬបាត់បង់ដោយសារកំហុសរបស់អ្នកមានសិទ្ធិរំលាយ ហើយមិនអាចសងវិញបាន អ្នកមានសិទ្ធិរំលាយអាចរំលាយកិច្ចសន្យាបាន។ តែត្រូវសងប្រាក់ដែលជាតម្លៃនៃកម្មវត្ថុ ត្រឹមកម្រិតនៃថ្លៃលក់ទិញ(ជាថ្លៃកំណត់ក្នុងកិច្ចសន្យា)។[111]

ឧទាហរណ៍៖ ដូចគ្នានឹងឧទាហរណ៍ខាងលើដែរ តែអ្នកទិញបានធ្វើឱ្យខូចខាតដល់រថយន្តមកពីកំហុសក្នុងពេលបើកបរ នោះគាត់នៅតែអាចមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាបាន ប៉ុន្តែត្រូវសងជាទឹកប្រាក់ចំពោះតម្លៃដែលត្រូវបានបន្ថយដោយសារការខូចខាតរថយន្តនោះ។

\+ នៅពេលដែលកម្មវត្ថុមិនអាចសងវិញបាន ដោយសារកំហុស ឬមូលហេតុរបស់ភាគីម្ខាងទៀត អ្នកមានសិទ្ធិរំលាយអាចរំលាយបាន។ តែគាត់មិនជាប់នូវករណីយកិច្ចក្នុងការសងប្រាក់ដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើទេ។[112]

ឧទាហរណ៍៖ អ្នកទិញរំលាយកិច្ចសន្យាដោយសារតែរថយន្តនោះមានវិការៈ។ ហើយរថយន្តនោះត្រូវបានខូចខាតមកពីក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ ដោយមូលហេតុជិះបុកជញ្ជាំផ្ទះគេ។ ដូចនេះអ្នកទិញពុំចាំបាច់ត្រូវទទួលខុសត្រូវលើការខូចខាតនៃរថយន្តនោះឡើយ ដោយសារតែអ្នកលក់ត្រូវបានចាត់ទុកថាបានបង្កើតមូល

---

110 មាត្រា៤១២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

111 មាត្រា ៤១២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

112 មាត្រា១៤២ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ហេតុនាំឱ្យមានការខូចខាតនោះ ហេតុដូច្នេះអ្នកទិញមិនចាំបាច់សងជាប្រាក់ចំពោះផ្នែកដែលបានបាក់បែករបស់រថយន្តទេ។

## ៣.អានុភាពនៃការរំលាយកិច្ចសន្យាលក់ទិញចំពោះតតិយជន

ថ្វីត្បិតតែការរំលាយកិច្ចសន្យាមានអានុភាពនាំឱ្យភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា (លើកលែងករណីយកិច្ចសងសំណងនៃការខូចខាត) ក៏ដោយ តែការរំលាយកិច្ចសន្យានោះនឹងមិនត្រូវបានធ្វើឡើងដែលនាំឱ្យខូចប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។[113] ពាក្យតតិយជន គឺសំដៅលើជនទីបី ឬជនដែលមិនមែនជាភាគីក្នុងទំនាក់ទំនងគតិយុត្ត។[114] ក្នុងន័យនេះ គឺក្រមរដ្ឋប្បវេណីបានការពារទៅលើតតិយជនតែចំពោះជនដែលមានផលប្រយោជន៍ត្រឹមត្រូវ ដើម្បីរក្សានូវស្ថេរភាពនៃប្រតិបត្តិការជំនួញផងដែរ ព្រោះជននោះហាក់បីដូចជាស្ថិតនៅក្នុងស្ថានភាពមួយដែលអាចប៉ះពាល់ ដោយសារតែភាគីក្នុងកិច្ចសន្យាណាមួយបង្ហាញឆន្ទៈរំលាយកិច្ចសន្យានោះចោលក្នុងពេលណាក៏បាន (ពេលមានការបំពាន ឬការព្រមព្រៀងគ្នារវាងភាគី)។

ហេតុនេះហើយក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវស្ថានការណ៍ពីរផ្សេងគ្នា ដែលត្រូវការពារទៅលើតតិយជនដូចទៅនឹងការលុបចោលដែរ គឺ ៖[115]

- តតិយជនមុនរំលាយកិច្ចសន្យា
- តតិយជនក្រោយរំលាយកិច្ចសន្យា

ឧទាហរណ៍៖ លោក ក បានធ្វើកិច្ចសន្យាលក់ទិញម៉ូតូចំនួន០១(មួយ)គ្រឿង ជាមួយនឹងលោក ខ។ ក្រោយមកលោក ខ បានលក់បន្តទៅឱ្យកញ្ញា គ។ ប្រសិនបើលោក ខ បានលក់ម៉ូតូចំនួន ០១ (មួយ) គ្រឿងនោះទៅឱ្យ កញ្ញា គ មុនពេលដែលលោក ក បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យានោះ។ កញ្ញា គ ត្រូវបានចាត់ទុកថាជាតតិយជនដែលមានវត្តមាននៅមុនពេលរំលាយកិច្ចសន្យា។ ប៉ុន្តែប្រសិនបើលោក ខ បានលក់ម៉ូតូចំនួន ០១ (មួយ) គ្រឿងនោះទៅឱ្យ កញ្ញា ខ ក្រោយពីដែលលោក ក បានបង្ហាញឆន្ទៈទៅកាន់លោក ខ ថាគាត់នឹងរំលាយកិច្ចសន្យានោះ។ កញ្ញា គ នឹងត្រូវចាត់ទុកថាជាតតិយជនដែលមានវត្តមាននៅក្រោយពេលរំលាយកិច្ចសន្យា។ យើងឃើញថាការរំលាយកិច្ចសន្យារវាងលោក ក និងលោក ខ នឹងអាចនាំឱ្យកញ្ញា គ ត្រូវទទួលរងការប៉ះពាល់។

តាមស្មារតីនៃមាត្រា ៤១១ កថាខណ្ឌទី៤ មិនបានចែងពីភាពច្បាស់លាស់ថាតើវត្តមានរបស់តតិយជនដែលមានមុនពេលរំលាយកិច្ចសន្យា ឬក្រោយពេលរំលាយកិច្ចសន្យា ដែលនឹងត្រូវបានការពារដោយច្បាប់នោះទេ។ តែចំណុចនេះ ក៏មិនខុសគ្នាពីការលុបចោលករណីមានតតិយជនពាក់ព័ន្ធដែរ គឺយើងអាចវិភាគ និងសិក្សា

---

113 មាត្រា ៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី។

114 សន្ទានុក្រមរដ្ឋប្បវេណី, ទំព័រទី ៧។

115 លោក គង់ សុភ័ក្រ្ត, មេរៀនការសង្គ្រោះកិច្ចសន្យា,ទំព័រទី២២។

ដោយឈរលើគោលគំនិត ០២(ពីរ) ៣.១.គោលការណ៍ប្រតិសកម្មនៃការរំលាយកិច្ចសន្យា និង៣.២.គោលការណ៍មិនប្រតិសកម្មនៃការរំលាយកិច្ចសន្យា។

### ៣.១.គោលការណ៍ប្រតិសកម្មនៃការរំលាយកិច្ចសន្យា

គំនិតទី១ ជាគំនិតដែលទទួលស្គាល់នូវអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា។ ប្រតិសកម្មមានន័យថា ជាការដែលមានអានុភាពបកទៅអតីតកាលវិញ។[116] ដូចនេះតាមទស្សនៈនេះ កិច្ចសន្យានោះត្រូវចាត់ទុកថាមិនមានអានុភាពតាំងពីដំបូង ដោយសារតែការរំលាយកិច្ចសន្យា។ ប្រសិនបើនៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់បានប្រគល់វត្ថុរួចរាល់ នៅពេលដែលកិច្ចសន្យាត្រូវរំលាយ អ្នកលក់អាចទាមទារឱ្យអ្នកទិញប្រគល់វត្ថុនោះត្រឡប់មកវិញបាន ដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ (អានុភាពប្រតិសកម្មៈ សិទ្ធិនៃកម្មសិទ្ធិលើវត្ថុនោះមិនត្រូវបានផ្ទេរតាំងពីដំបូងម្ល៉េះ គឺត្រឡប់ទៅរកសភាពដើមមុនពេលមានកិច្ចសន្យា)។

ហេតុនេះករណីខាងលើគឺ គ ត្រូវបានចាត់ទុកថាទទួលគ្រប់គ្រងបន្តលើកម្មសិទ្ធិពី ខ ដែលមិនមានកម្មសិទ្ធិលើម៉ូតូនោះ (ព្រោះតែកម្មសិទ្ធិរបស់ ក មិនបានផ្ទេរទៅ ខ ទេ) ដូចនេះ គ គឺមិនអាចទទួលបានការផ្ទេរកម្មសិទ្ធិឡើយ។ យើងឃើញថាថ្វីត្បិតតែទស្សនៈនេះទទួលស្គាល់នូវអានុភាពប្រតិសកម្មក៏ពិតមែន ប៉ុន្តែនៅក្នុងបញ្ញត្តិមាត្រា ៤១១ កថាខណ្ឌទី៤ គឺតម្រូវឱ្យមានការការពារករណីមានការរំលាយកិច្ចសន្យាទៅលើតតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវស្របតាមច្បាប់។ មានន័យថាអានុភាពនៃកិច្ចសន្យានោះ នឹងមិនអាចយកមកធ្វើការអះអាងចំពោះតតិយជនបានឡើយ ប្រសិនបើតតិយជននោះជាជនដែលសុចរិត និងគ្មានកំហុស(ធ្ងន់ធ្ងរ)។

នៅក្នុងគំនិតនេះ តតិយជនត្រូវតែមានទំនាក់ទំនងនៅក្នុងកិច្ចសន្យាមុនពេលកិច្ចសន្យានោះត្រូវបានរំលាយ ទើបអាចអះអាងពីផលប្រយោជន៍របស់ខ្លួនបាន។ ឯលក្ខខណ្ឌតតាំងវិញ គឺមិនតម្រូវចាំបាច់ទាល់តែមានការកាន់កាប់ (ចំពោះចលនវត្ថុ) ឬការចុះបញ្ជី (ចំពោះអចលនវត្ថុ) ដើម្បីទទួលការការពារឡើយ ដោយសារតែមាត្រា ៤១១ កថាខណ្ឌទី៤ មិនតម្រូវឱ្យមានលក្ខខណ្ឌតតាំងចំពោះតតិយជនឡើយ។ តែបើតតិយជននោះអាចមានលក្ខខណ្ឌតតាំង ដើម្បីអះអាងពីសិទ្ធិរបស់ខ្លួនបាន នោះវារឹតតែប្រសើរឡើង ដោយសារតតិយជនបានបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការការពារសិទ្ធិរបស់ខ្លួន។

ចំពោះតតិយជនដែលមានវត្ថុមាននៅក្រោយការរំលាយកិច្ចសន្យា មិនអាចទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី៤ទេ ព្រោះអានុភាពប្រតិសកម្មបានកើតឡើងរួចរាល់ហើយ ដូចនេះតតិយជនមានវត្ថុមានក្រោយការរំលាយកិច្ចសន្យា ត្រូវបានចាត់ទុកថាបានទទួលបានការគ្រប់គ្រងបន្តពីជនដែលមិនមានកម្មសិទ្ធិ ដែលមិនអាចធ្វើលទ្ធកម្មបាន។ យ៉ាងណាមិញសំរាប់កម្មវត្ថុដែលជាចលនវត្ថុនោះ តតិយជននោះនៅតែអាចធ្វើលទ្ធកម្មកម្មសិទ្ធិបាន បើបំពេញតាមលក្ខខណ្ឌមានចែងក្នុងមាត្រា ១៩៣ "អ្នកដែលបានទទួលការផ្ទេរការ

[116] វចនានុក្រមច្បាប់ខ្មែរ តាមបទដ្ឋានគតិយុត្តិ, ទំព័រទី ២៤៥។

កាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះ”។ បញ្ហានៅត្រង់ថាកម្មវត្ថុដែលជាអចលនវត្ថុ ប្រសិនបើតតិយជននោះមិនអាចទទួលបានកម្មសិទ្ធិ តាមរយៈលទ្ធកម្មដោយសុចរិតនោះ តើតតិយជននោះត្រូវទទួលរងនូវផលប៉ះពាល់ដែលបានមកពីការរំលាយកិច្ចសន្យា ឬយ៉ាងណា? ជាក់ស្តែងមានគំនិតមួយទៀត ដែលអាចជួយការពារដល់តតិយជននោះបាន (ជនមានវត្តមានក្រោយការរំលាយកិច្ចសន្យា តែជាជនសុចរិត និងគ្មានកំហុស) គឺតាមរយៈការអនុវត្តដែលមានភាពស្រដៀងគ្នាទៅនឹងមាត្រា ៣៥៣ កថាខណ្ឌទី២ (ការបង្ហាញឆន្ទៈមិនពិត) ដោយគិតទៅលើការបន្សល់ទុកការចុះបញ្ជីពី ក ទៅ ខ ទើបអាចឱ្យ គ (ជាតតិយជន) នោះមានការជឿជាក់ថា ខ គឺជាម្ចាស់កម្មសិទ្ធិពិតប្រាកដ។ ជាធម្មតាការអនុវត្តមាត្រា ៣៥៣ កថាខណ្ឌទី២ (ការបង្ហាញឆន្ទៈមិនពិត) ក្នុងការមោឃៈទៅលើកិច្ចសន្យា នៅពេលដែលមានការឃុបឃិតគ្នារវាងគូភាគីដើម្បីឱ្យខ្លួនរួចផុតពីការអនុវត្តកាតព្វកិច្ចណាមួយ។

ឧទាហរណ៍៖ កូនបំណុល ខ ដើម្បីធ្វើឱ្យខ្លួនរួចផុតពីការការរឹបអូសយកយកដីរបស់ខ្លួនទៅអនុវត្តដោយបង្ខំសងប្រាក់ ទៅ ក ។ ពេលនោះ ខ បានប្រាប់ទៅមិត្តរបស់ខ្លួន គ នូវបញ្ហានេះ ក្នុងការរកវិធីសាស្ត្រឃុបឃិតគ្នាដោយ ខ បានធ្វើលក់ដីនោះទៅឱ្យ គ ក្លែងក្លាយ ដោយបានចុះបញ្ជីផ្ទេរសិទ្ធិកម្មសិទ្ធិរួចរាល់។ ក្នុងករណីនេះកិច្ចសន្យាលក់ទិញរវាង ខ និងគ ត្រូវបានចាត់ទុកជាមោឃៈ ដោយផ្អែកលើមាត្រា ៣៥៣ កថាខណ្ឌទី១។ ជាងនេះទៅទៀត ខ មិនមានឆន្ទៈក្នុងការផ្ទេរកម្មសិទ្ធិរបស់ខ្លួនទៅឱ្យ គ ហើយ គ ក៏មិនមានឆន្ទៈក្នុងការធ្វើលទ្ធកម្មកម្មសិទ្ធិដែរ។ ដូច្នេះ ខ នៅតែមានកម្មសិទ្ធិលើដីនោះ។ តែ គ បានបំពានទៅលើទំនុកចិត្តរបស់ ខ ដោយបានយកដីនោះទៅលក់បន្តទៅ ឃ (តតិយជន) និងបានធ្វើការផ្ទេរនូវកម្មសិទ្ធិចុះបញ្ជីរួចរាល់ ដោយ ឃ បានជឿជាក់ថា គ គឺជាម្ចាស់កម្មសិទ្ធិពិតប្រាកដ ដោយសារតែ គ មានការចុះបញ្ជីនូវប័ណ្ណកម្មសិទ្ធិ។ ចំណុចនេះ តាមមាត្រា៣៥៣ កថាខណ្ឌទី២ គឺ ខ មិនអាចអះអាងនូវសិទ្ធិរបស់ខ្លួនចំពោះ ឃ បានឡើយ គឺដើម្បីការពារសុវត្ថិភាពជំនួយរបស់ ឃ។ ដូចនេះដើម្បីទទួលបានការពារចំពោះតតិយជនដែលមានវត្តមានក្រោយការរំលាយកិច្ចសន្យា តាមមាត្រា ៣៥៣ កថាខណ្ឌទី២ គឺចាំបាច់ជននោះត្រូវតែសុចរិត គ្មានកំហុស(ធ្ងន់ធ្ងរ) ព្រោះតែជនដែលបានបង្កើតនូវទិដ្ឋភាពមិនពិតដូចជា ខ មិនមានសិទ្ធិក្នុងការអះអាងពីមោឃភាពកិច្ចសន្យាចំពោះតតិយជនដែលជឿជាក់ទៅលើទិដ្ឋភាពមិនពិតនោះបានឡើយ។

បង្វែរចូលទៅក្នុងការរំលាយកិច្ចសន្យាវិញ គឺមិនមានការឃុបឃិតនៃឆន្ទៈដែលបង្ហាញឱ្យឃើញច្បាស់រវាង ក និង ខ (ករណីឧទាហរណ៍លក់ទិញម៉ូតូខាងលើ) ទៅក្នុងករណីនេះទេ។ ដូច្នេះយើងក៏មិនអាចអនុវត្តមាត្រា ៣៥៣ កថាខណ្ឌទី២ ដោយផ្ទាល់ទៅលើករណីនេះដែរ តែវាមានលក្ខណ្ឌស្រដៀងគ្នាទៅនឹងស្ថានភាពនៃ

ការបង្ហាញឆន្ទៈមិនពិតដែរ ដោយសារតែភាគីនៃកិច្ចសន្យានៅតែបន្សល់ទុកនូវលក្ខខណ្ឌតតាំង (ដូចជាការចុះបញ្ជីចំពោះអចលនវត្ថុ ឬការកាន់កាប់ចំពោះចលនវត្ថុ) ដដែល ដោយមិនមានការផ្លាស់ប្តូរក្រោយមានរំលាយកិច្ចសន្យាក៏ដោយ (មិនខិតខំរុះរាន់ធ្វើការផ្ទេរចុះបញ្ជី ឬការកាន់កាប់វិញ) ដែលនេះបញ្ជាក់ថាបានបង្ហាញទិដ្ឋភាពមួយ ដែលមើលទៅ ខ ជាម្ចាស់កម្មសិទ្ធិចំពោះម៉ូតូនោះ។ ហើយបើ គ បានជឿជាក់ថា ខ ជាម្ចាស់កម្មសិទ្ធិពិតប្រាកដ ដោយសុចរិត និងគ្មានកំហុស(ធ្ងន់ធ្ងរ)នោះ គឺ គ (តតិយជន) នោះនៅតែទទួលបានការការពារតាមការអនុវត្តស្រដៀងគ្នានៃមាត្រា ៣៥៣ កថាខណ្ឌទី២ បាន។

### ៣.២.គោលការណ៍មិនប្រតិសកម្មនៃការរំលាយកិច្ចសន្យា

គំនិតទី២ ជាគំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម នៃការរំលាយកិច្ចសន្យា។ នៅក្នុងគំនិត បើទោះបីជាមានការរំលាយកិច្ចសន្យាក៏ដោយ ក៏គេមិនចាត់ទុកថា ក (អ្នកលក់ម៉ូតូ) ជាកម្មសិទ្ធិករតាំងពីដំបូងទៀតនោះទេ ព្រោះតែមិនមានអានុភាពប្រតិសកម្ម។ តែពេលមានការរំលាយកិច្ចសន្យា ម្ចាស់កម្មសិទ្ធិអាចទារឱ្យធ្វើការផ្ទេរកម្មវត្ថុត្រឡប់មកវិញបាន បើទោះបីជាវត្ថុនោះត្រូវបានផ្ទេរទៅតតិយជនរួចរាល់ក៏ដោយ។

ឧទាហរណ៍៖ ប្រសិនបើ ក (អ្នកលក់ម៉ូតូ) បានរំលាយកិច្ចសន្យា នោះ ខ (អ្នកទិញម៉ូតូ) ត្រូវមានកាតព្វកិច្ចថ្មីក្នុងការប្រគល់ត្រឡប់នូវអ្វីដែលគាត់បានទទួល ដោយសារតែមានការរំលាយកិច្ចសន្យា។

ដូចនេះសម្រាប់តតិយជនដែលមានវត្តមានមុនពេលរំលាយកិច្ចសន្យា ត្រូវបានគេចាត់ទុកថាជាជនដែលទទួលបានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ ព្រោះតែ ខ (អ្នកទិញម៉ូតូ) ចាត់ទុកជាកម្មសិទ្ធិករតាំងពីមុនរំលាយកិច្ចសន្យា (ដោយសារអានុភាពមិនប្រតិសកម្ម)។[117] ហេតុនេះហើយតតិយជននេះត្រូវបានការពារតាមមាត្រា ៤១១ កថាខណ្ឌទី៤។

ប៉ុន្តែក្នុងករណីដែល គ (តតិយជន) បានទិញម៉ូតូនោះបន្ទាប់ពីមានការរំលាយកិច្ចសន្យានោះ មានន័យថាកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យ ក (អ្នកលក់ម៉ូតូ) វិញ ហើយក្រោយមក ខ បានលក់ទៅម៉ូតូទៅលក់ឱ្យ គ (តតិយជន) ទៀត បែបនេះគឺ ខ នឹងត្រូវធ្វើការផ្ទេរកម្មសិទ្ធិ០២(ពីរ)ដងជាន់គ្នា។ ដូច្នេះបុគ្គលណាដែលទទួលបានលក្ខខណ្ឌតតាំងមុន នោះបុគ្គលនោះអាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន ទោះបីជាមានបញ្ញត្តិនៃមាត្រា ៤១១ កថាខណ្ឌទី៤ ក៏ដោយ (ការការពារចំពោះតតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់) ក៏នៅតែមានលទ្ធផលផ្ទេរពីរដងជាន់គ្នាដដែល ទើបបញ្ញត្តិនេះ មិនបានការពារតតិយជនដែលស្របច្បាប់ពេញលេញនោះ (បញ្ញត្តិពិសេស) ទេ គ្រាន់តែជាបញ្ញត្តិបញ្ជាក់បន្ថែមប៉ុណ្ណោះ។ ដូចនេះបញ្ហានឹងចោទមានឡើងថា តើមានបញ្ញត្តិអ្វីដើម្បីយកមក

[117] ក្រុមការងារគណៈមេធាវី នៃកិច្ចប្រជុំក្រុមការងារចម្រុះលើកទី៣, បទបង្ហាញអំពីកិច្ចការពារតតិយជនពាក់ព័ន្ធនឹងការលុបចោល ការរំលាយកិច្ចសន្យា, ទំព័រទី ៦។

ការពារចំពោះតតិយជននោះ ឬក៏ទាល់តែមានលក្ខខណ្ឌតតាំង? តើតតិយជននោះត្រូវតែជាជនដែលសុចរិត និងគ្មានកំហុស (ធ្ងន់ធ្ងរ) ដែរ ឬយ៉ាងណា?

បើក្រឡេកទៅមើលមាត្រា ៤១១ កថាខណ្ឌទី៤ គឺមិនបានចែងពីភាពច្បាស់លាស់ថា តតិយជននោះត្រូវតែធ្វើសកម្មភាពដោយសុចរិត និងគ្មានកំហុសទេ។ តាមរយៈការបកស្រាយខាងលើ ទំនាក់ទំនងរវាង ក និង គ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្ទេរពីរដងជាន់គ្នា។ ដូច្នេះ គ ត្រូវតែទទួលបាននូវការកាន់កាប់មុន (លក្ខខណ្ឌតតាំងចំពោះចលនវត្ថុ) ក ដើម្បីទទួលបានការការពារ។ យ៉ាងណាមិញចំពោះលក្ខខណ្ឌតតាំងដែលមាននៅមាត្រា ១៣៤ និងមាត្រា ១៣៥ ប៉ុណ្ណោះ ក៏មិនទាន់អាចការពារតតិយជននោះពេញលេញដែរ។ ឧទាហរណ៍៖ ប្រសិន គ (តតិយជន) បានធ្វើការរុះរាន់ដើម្បីទទួលបានលក្ខខណ្ឌតតាំងដើម្បីអះអាងពីសិទ្ធិរបស់ខ្លួន នោះគាត់នឹងមានអាទិភាពជាង ក(អ្នកលក់) តាមបញ្ញត្តិនៃមាត្រា ១៣៤ ។ ក៏ប៉ុន្តែប្រសិនបើ គ បានដឹងហើយថា កិច្ចសន្យាលក់ទិញម៉ូតូរវាង ក និង ខ ត្រូវបានបានរំលាយ នោះ គ ប្រាកដជាដឹងច្បាស់ថា ខ មិនមានសិទ្ធិតទៅទៀតទេលើម៉ូតូនោះ។ ហេតុនេះភាពចាំបាច់ដើម្បី ការពារ គ គឺមិនមានខ្ពស់នោះទេ។

ដូច្នេះចំពោះតតិយជនដែលមានវត្តមាននៅក្រោយការរំលាយកិច្ចសន្យា គឺចាំបាច់សម្រាប់គាត់ក្នុងការធ្វើសកម្មភាពនោះដោយសុចរិត និងគ្មានកំហុស(ធ្ងន់ធ្ងរ) ព្រមទាំងបំពេញតាមលក្ខខណ្ឌតតាំង ទើបជាការប្រសើរក្នុងការពារធានានូវសិទ្ធិរបស់ខ្លួន។

ជារួមមក តាមគោលគំនិតទាំងពីរខាងលើ មិនថាគោលគំនិតអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា និងគោលគំនិតមិនប្រតិសកម្មនៃការរំលាយកិច្ចសន្យា សុធតែការពារតតិយជននៃកិច្ចសន្យាលក់ទិញទាំងអស់ដោយស្របតាមស្មារតីនៃមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី លើកលែងតែតតិយជនដែលមានកំហុស និងចេតនាទុច្ចរិតប៉ុណ្ណោះ ដែលមិនត្រូវទទួលបានការការពារពីច្បាប់។ ជាក់ស្តែងតតិយជននៃកិច្ចសន្យាលក់ទិញដែលមានវត្តមានក្រោយការបង្ហាញឆន្ទៈដើម្បីរំលាយកិច្ចសន្យា ដែលទោះបីជាបានដឹងថាកិច្ចសន្យាត្រូវបានរំលាយក៏ពិតមែន ប៉ុន្តែតតិយជននេះព្យាយាមចង់បាន និងទទួលបានកម្មសិទ្ធិចំពោះកម្មវត្ថុនៃកិច្ចសន្យាលក់ទិញដើមដែលត្រូវបានរំលាយ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយទៅលើប្រធានបទខាងលើ យើងសង្កេតឃើញថា ប្រព័ន្ធនៃការរំលាយកិច្ចសន្យាលក់ទិញ ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី ក្នុងគន្ថីទី៤ ស្តីពីកាតព្វកិច្ច និងគន្ថីទី៥ ស្តីពីកិច្ចសន្យាពិសេសផ្សេងៗទៀត បានបញ្ជាក់ឱ្យយើងដឹងលក្ខណៈគោលដើម្បីអនុវត្តវិធានសង្គ្រោះកិច្ចសន្យាលក់ទិញបានដោយរលូន។ ជាក់ស្តែងនៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់មូលហេតុនៃការរំលាយកិច្ចសន្យា ដោយអាចធ្វើឡើងក្រោម ០៣ (បី) រូបភាព ដែលមានការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិទូទៅ ការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិពិសេស និងការរំលាយកិច្ចសន្យាលក់ទិញដោយការព្រមព្រៀងរបស់ភាគី។ ប្រសិនបើភាគីនៃកិច្ចសន្យាលក់ទិញណាម្ខាង បានបំពានកិច្ចសន្យាក្រោមមូលហេតុនៃការរំលាយកិច្ចសន្យាលក់ទិញដោយបញ្ញត្តិទូទៅ ឬបញ្ញត្តិពិសេសនោះ ក្រមរដ្ឋប្បវេណីបានប្រគល់សិទ្ធិទៅឱ្យភាគីដែលទទួលរងការបំពានដើម្បីរំលាយកិច្ចសន្យាលក់ទិញនោះបាន។ ម៉្យាងវិញទៀត ប្រសិនបើភាគីនៃកិច្ចសន្យាលក់ទិញ មិនបានកំណត់អំពីមូលហេតុពិសេសដើម្បីរំលាយកិច្ចសន្យាក្នុងលិខិតកិច្ចសន្យានោះទេ ហើយពេលក្រោយមានភាគីណាម្ខាងចង់រំលាយកិច្ចសន្យា ភាគីនោះអាចបង្ហាញឆន្ទៈរំលាយបានផងដែរ។

ប្រសិនបើភាគីបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យារួចហើយ អានុភាពនៃការរំលាយកិច្ចសន្យានឹងកើតមានឡើង។ គួរបញ្ជាក់ផងថា ប្រព័ន្ធនៃការរំលាយកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយក្រមរដ្ឋប្បវេណី អាចមានអានុភាពតាមរយៈការជូនដំណឹងអំពីការរំលាយទៅដល់ភាគីម្ខាងទៀតតែប៉ុណ្ណោះ។ ការជូនដំណឹងអាចធ្វើបានគ្រប់មធ្យោបាយ ប៉ុន្តែការជូនដំណឹងតាមលិខិតជាលាយលក្ខណ៍អក្សរ នឹងមានអត្ថប្រយោជន៍នាពេលអនាគត ជាពិសេសក្នុងករណីដែលមានទំនាស់ ពីព្រោះថាការជូនដំណឹងតាមលិខិតជាលាយលក្ខណ៍អក្សរអំពីការរំលាយកិច្ចសន្យានេះ ជាក្លាយភស្តុតាងក្នុងប្រព័ន្ធតុលាការបាន។ ក្រៅពីការបង្ហាញឆន្ទៈដើម្បីរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ប្រសិនបើភាគីម្ខាងទៀតបដិសេធមិនទទួលស្គាល់អំពីការរំលាយនេះទេ ភាគីដែលមានសិទ្ធិអាចប្តឹងទាមទារការអន្តរាគមន៍ពីស្ថាប័នតុលាការផងដែរ។ ប៉ុន្តែគួរចំណាំ ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់ថាការរំលាយកិច្ចសន្យាអាចមានអានុភាពបាន ដោយការបង្ហាញឆន្ទៈរំលាយរបស់ភាគីតែប៉ុណ្ណោះដែលមិនបានអនុញ្ញាតឱ្យតុលាការសម្រេចអំពីការរំលាយកិច្ចសន្យាឡើយ។ ក្នុងន័យនៃកម្មវត្ថុនៃការទាមទាររបស់អ្នកមានសិទ្ធិរំលាយ មិនអាចប្តឹងសុំទាមទារឱ្យតុលាការសម្រេចអំពីការរំលាយកិច្ចសន្យាបានទេ ប៉ុន្តែភាគីដែលមានសិទ្ធិរំលាយ អាចប្តឹងសុំឱ្យតុលាការសម្រេចអំពីនត្ថិភាពនៃកិច្ចសន្យា និងទាមទារឱ្យផ្តល់តាវលិកបាន។

បន្ទាប់ពីភាគីណាមួយនៃកិច្ចសន្យាលក់ទិញបានបង្ហាញឆន្ទៈរំលាយដោយយកមូលដ្ឋានណាមួយ ដូចជាបញ្ញត្តិច្បាប់ ឬករណីដែលបានចែងនៅក្នុងកិច្ចសន្យា ដើម្បីរំលាយកិច្ចសន្យាលក់ទិញ ច្បាប់បានទទួលស្គាល់ថាការរំលាយកិច្ចសន្យានោះនឹងមានអានុភាព ដែលចងឱ្យភាគីម្ខាងទៀតត្រូវមានករណីយកិច្ចមួយចំនួនដូចមាន

រៀបរាប់នៅក្នុងអត្ថបទសារណាខាងលើ។ ប៉ុន្តែបញ្ហានឹងកើតមាននៅត្រង់ថាពេលដែលភាគីបានបង្ហាញឆន្ទៈរំលាយរួចរាល់ទៅកាន់ភាគីម្ខាងទៀត តែភាគីទៀតនោះបែរជាមិនយល់ព្រមក្នុងការធ្វើបដិទានត្រឡប់នូវកម្មវត្ថុផ្សេងៗដែលខ្លួនបានទទួលឱ្យទៅកាន់ម្ចាស់ដើមវិញ ឬនិយាយឱ្យខ្លីថាគេមិនទទួលស្គាល់នូវអានុភាពការរំលាយហេតុនេះក្រមរដ្ឋប្បវេណីបានបើកសិទ្ធិឱ្យភាគីអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការបាន។ ថ្វីត្បិតតែអានុភាពនៃកិច្ចសន្យាត្រូវឱ្យភាគីធ្វើបដិទានត្រឡប់ទៅរកស្ថានភាពដើមក៏ពិតមែន ប៉ុន្តែក្រមរដ្ឋប្បវេណីក៏មិនអនុញ្ញាតដែរ បើការរំលាយកិច្ចសន្យានោះនឹងធ្វើឱ្យខូចខាតប្រយោជន៍ត្រឹមត្រូវរបស់តតិយជន។ នេះជាគោលបំណងដើម្បីការពារទៅ ស្ថេរភាពនៃសុវត្ថិភាពខាងជំនួញ។ យ៉ាងណាមិញយើងក៏ឃើញដែលថាមិនមានបញ្ញត្តិណាមួយដែលចែងឱ្យច្បាស់លាស់ទៅលើលក្ខណៈនៃផលប្រយោជន៍ត្រឹមត្រូវបែបណា ដែលនឹងអាចទទួលបានការការពារពីច្បាប់នោះទេ។ ហេតុនេះមានតែទុកទៅលើយុទ្ធសាស្ត្រតុលាការកម្ពុជាជាអ្នកដោះស្រាយវិនិច្ឆ័យផ្អែកតាមស្ថានការណ៍ជាក់ស្តែងនាពេលអនាគត។

ជារួមមក កិច្ចសន្យានីមួយៗ មិនថាតែកិច្ចសន្យាលក់ទិញប៉ុណ្ណោះទេ សុទ្ធតែកើតឡើងពីការព្រមព្រៀង ឬអាចហៅថាជាច្បាប់របស់គូភាគីក្នុងការចងលក្ខខណ្ឌ ឬកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ ដូច្នេះនៅពេលដែលកិច្ចសន្យាមានសុពលភាព និងអានុភាពពេញលេញហើយ គប្បីតែគូភាគីព្យាយាមអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅនឹងឆន្ទៈដែលបានបង្ហាញសម្រាប់ការបង្កើតកិច្ចសន្យាមួយនេះឡើង ដើម្បីបញ្ចៀសនូវរាល់វិវាទផ្សេងៗដែលកើតមានរហូតឈានដល់មានការរំលាយកិច្ចសន្យាពីភាគីណាម្ខាង ព្រោះតែការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលទង្វើនេះវាអាចធ្វើឱ្យប៉ះពាល់ទៅលើភាគីម្ខាងដូចជា ការខាតបង់ពេលវេលា បាត់បង់ទំនុកចិត្ត ឬបាត់បង់នូវទ្រព្យសម្បត្តិដោយសារតែការខកខានបំពេញកាតព្វកិច្ចរបស់យើង។ មិនត្រឹមតែប៉ុណ្ណោះវារឹតតែបង្កភាពស្មុគស្មាញទៅដល់ស្ថាប័នតុលាការថែមទៀតផង បើគូភាគីមិនអាចដោះស្រាយនូវវិបត្តិរបស់ខ្លួនពាក់ព័ន្ធទៅលើការរំលាយកិច្ចសន្យានេះនៅក្រៅប្រព័ន្ធតុលាការបាន។ ហើយប្រសិនបើមានករណីវិវាទកើតឡើងទាក់ទងនឹងការមិនអនុវត្តកាតព្វកិច្ច ឬការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ភាគីនៃកិច្ចសន្យាលក់ទិញ អាចជ្រើសរើសវិធានសង្គ្រោះកិច្ចសន្យាដើម្បីយកមកអនុវត្តបាន ដែលក្នុងនោះរួមមាន ការអនុវត្តដោយបង្ខំ ការរំលាយកិច្ចសន្យា និងការទាមទារសំណងនៃការខូចខាត។ ប៉ុន្តែវិធានសង្គ្រោះទាំងអស់នេះ មិនអាចសុទ្ធតែអនុវត្តជាន់លើគ្នាបានទេ ជាឧទាហរណ៍ ការអនុវត្តដោយបង្ខំ មិនអាចអនុវត្តជាមួយការរំលាយកិច្ចសន្យានោះ ដោយឡែកប្រសិនបើភាគីអនុវត្តសិទ្ធិរំលាយ ឬការអនុវត្តដោយបង្ខំ ច្បាប់មិនបានហាមឃាត់ ភាគីក្នុងការទាមទារសំណងនៃការខូចខាតឡើយ។ ដោយសង្ខេប ការរំលាយកិច្ចសន្យាលក់ទិញ ពិតជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមសព្វថ្ងៃយ៉ាងពិតប្រាកដមែន ដើម្បីការពារប្រយោជន៍ស្របច្បាប់របស់ភាគី និងលើកស្ទួយវិស័យយុត្តិធម៌នៅក្នុងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

ដោយសារតែតម្រូវការរបស់សង្គម និងការដើរទៅមុខយ៉ាងរហ័សលើគ្រប់វិស័យ រួមមានវិស័យការងារ វិស័យឧស្សាហកម្ម វិស័យអាជីវកម្ម វិស័យពាណិជ្ជកម្ម ព្រមទាំងមានការវិនិយោគទុនទាំងក្នុង និងក្រៅប្រទេស បុគ្គលគ្រប់រូបគួរគប្បីយល់ដឹង ឬមានចំណេះដឹងខ្លះទាក់ទងនឹងកិច្ចសន្យា ជាពិសេសគឺកិច្ចសន្យាលក់ទិញ។ ជាក់ស្តែងការលក់ទិញ ឬពាក្យបច្ចេកទេស ការធ្វើពាណិជ្ជកម្ម ឬអាជីវកម្ម បានដើរតួនាទីយ៉ាងសំខាន់ និងមានវិសាលភាពគ្របដណ្តប់ស្ទើរគ្រប់វិស័យទាំងអស់ ហើយប្រសិនបើគ្មានការលក់ទិញនោះទេ ប្រទេសជាតិក៏គ្មានការរីកចម្រើនផងដែរ។ ហេតុដូច្នេះ ក្នុងនាមជាប្រជាពលរដ្ឋក្នុងសង្គមមួយ ដើម្បីចូលរួមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិ និងឃឿនសេដ្ឋកិច្ចជាតិ គួរគប្បីបានយល់ដឹងអំពីកិច្ចសន្យាលក់ទិញ លើសពីនេះទៅទៀតការយល់ដឹងអំពីកិច្ចសន្យាលក់ទិញ ក៏ដូចជារបាំងការពារពីការខាតបង់ផលប្រយោជន៍ឯកជនផ្ទាល់ខ្លួនផងដែរ។

ក្នុងចំណោមអត្ថន័យ និងខ្លឹមសាររបស់សារណានេះ ចំណុចដែលសំខាន់ដែលត្រូវកត់ចំណាំ និងសំគាល់ទុកនោះរួមមាន៖

១.មូលហេតុដែលនាំឱ្យកើតមានសិទ្ធិរំលាយកិច្ចសន្យាលក់ទិញ៖ ក្រោយពេលកិច្ចសន្យាលក់ទិញមានអានុភាព និងសុពលភាពតាមផ្លូវច្បាប់ហើយ ប្រសិនបើមានភាគីម្ខាង បានបំពានករណីយកិច្ចដែលកើតមានក្រោមអានុភាពនៃកិច្ចសន្យាលក់ទិញ ទោះជាករណីយកិច្ចកំណត់ដោយច្បាប់ ឬករណីយកិច្ចកំណត់ដោយគូភាគីក្តី សិទ្ធិរំលាយកិច្ចសន្យាលក់ទិញត្រូវបានផ្តល់ឱ្យភាគីម្ខាងទៀត។

២.វិធីនៃការរំលាយកិច្ចសន្យាលក់ទិញ៖ ក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី បានកំណត់យ៉ាងជាក់ច្បាស់ថា ការរំលាយកិច្ចសន្យាអាចធ្វើឡើង ហើយមានអានុភាពដោយគ្រាន់តែភាគីដែលមានសិទ្ធិរំលាយជូនដំណឹងអំពីការរំលាយកិច្ចសន្យាទៅភាគីម្ខាងទៀតប៉ុណ្ណោះ ក្នុងន័យនៃក្រមរដ្ឋប្បវេណីមិនបានតម្រូវឱ្យភាគីមានការសម្រេចពីតុលាការដើម្បីធ្វើការរំលាយកិច្ចសន្យានោះទេ។ ប៉ុន្តែប្រសិនបើមានវិវាទបានកើតឡើង ក្រមរដ្ឋប្បវេណីមិនបានហាមភាគីដែលមានសិទ្ធិស្នើសុំការអន្តរាគមន៍ពីតុលាការនោះដែរ។

៣.ការរលត់សិទ្ធិរំលាយកិច្ចសន្យា៖ សិទ្ធិរំលាយកិច្ចសន្យាមិនអាចនៅឋិតថេរជានិរន្តន៍នោះទេ ក្នុងករណីដែលភាគីដែលមានសិទ្ធិរំលាយបានធ្វើដោយបំពាន ឬអាជ្ញាយុកាលនៃការអនុវត្តសិទ្ធិរំលាយត្រូវបានរលត់ ភាគីដែលមានសិទ្ធិមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានទៀតឡើយ។

ហេតុដូច្នេះ ការរំលាយកិច្ចសន្យាមួយអាចសម្រេចបានដោយជោគជ័យ បីចំណុចខាងលើ ចាំបាច់ត្រូវយកមកអនុវត្តឱ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងការខាតបង់ប្រយោជន៍ស្របច្បាប់របស់ខ្លួន និងបញ្ហានៅថ្ងៃក្រោយ ជាពិសេសអ្នកដែលមានសិទ្ធិរំលាយ ឬអ្នកដែលយល់ថាកិច្ចសន្យារបស់ខ្លួនត្រូវបានបំពានយ៉ាងធ្ងន់ធ្ងរនោះ មិនគួរមើលរំលងឡើយ។

# ឯកសារយោង


១. ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

២. ក្រមនីតិវិធីរដ្ឋប្បវេណី នស/រកម/០៧០៦/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

៣. ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគទី ១, កែសម្រួលលើការបោះពុម្ពលើកទី ១, ឆ្នាំ២០១៣។

៤. ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, កែសម្រួលលើការបោះពុម្ពលើកទី ១, ឆ្នាំ២០១៣។

៥. ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មាធិការទទួលបន្ទុកការពាំរសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគី១, ការកែសម្រួលបោះពុម្ពលើកទី១, ឆ្នាំ២០១៣។

៦. ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មាធិការទទួលបន្ទុកការពាំរសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, ការកែសម្រួលបោះពុម្ពលើកទី១, ឆ្នាំ២០១៣។

៧. ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មាធិការទទួលបន្ទុកការពាំរសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣, ឆ្នាំ២០១០។

៨. គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, សេចក្តីកំណត់ចំពោះមាត្រានីមួយ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ឆ្នាំ២០១១

៩. សន្ទានុក្រមរដ្ឋប្បវេណី

១០. សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ, វចនានុក្រមច្បាប់ខ្មែរតាមបទដ្ឋានគតិយុត្តិ, បោះពុម្ពលើកទី៣, ឆ្នាំ២០១៨

១១. សមិទ្ធផលរបស់គម្រោងនៃប្រព័ន្ធច្បាប់ និងតុលាការ, ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១, ឆ្នាំ២០១៥។

១២. ក្រុមការងារគណៈមេធាវី នៃកិច្ចប្រជុំក្រុមការងារចម្រុះលើកទី៣, បទបង្ហាញអំពីកិច្ចការពារគតិយជនពាក់ព័ន្ធនឹងការលុបចោល ការរំលាយកិច្ចសន្យា។

១៣. សាស្ត្រាចារ្យ ជិន វណ្ណារ៉ា, នីតិកិច្ចសន្យា, ឆ្នាំ២០១៣។

១៤. សាស្ត្រាចារ្យ FUKUOKA FUMIE និង UMEMOTO YUMI, បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី។

១៥. សាស្ត្រាចារ្យសេង នាង និងលោកស្រីមេធាវី ទេព បូផល, ការរំលាយកិច្ចសន្យា, ឆ្នាំ ២០១៩។

១៦. សាស្ត្រាចារ្យ UMEMOTO YUMI, ការរំលាយកិច្ចសន្យា, , (ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ)។

១៧. លោកសាស្ត្រាចារ្យ គង់ សុភ័ក្រ្ត, សុពលភាពនៃកិច្ចសន្យា មោឃភាព និងការលុបចោល, ឆ្នាំ២០១៩។

១៨. លោកមេធាវី ប៉ោ ហ៊ុយ, នីតិវិធីជម្រះក្តីលើកទី១។

១៩. លោក គង់ សុភ័ក្រ្ត, មេរៀនការសង្គ្រោះកិច្ចសន្យា, ឆ្នាំ២០១៩។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>កិច្ចសន្យាទិញ - លក់រថយន្ត</u>

កិច្ចសន្យាទិញ-លក់រថយន្ត(កិច្ចសន្យា) ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២១ ខែ ០៥ ឆ្នាំ ២០១៩ **រវាង:**

ឈ្មោះ [redacted] ភេទ ប្រុស ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ថ្ងៃខែឆ្នាំកំណើត ២១-១១-១៩៩៣ កាន់អត្តសញ្ញាណប័ណ្ណលេខ: ០១១២៩៦៨០១ (០១) មានទីលំនៅផ្ទះលេខ ៣៤E០ ភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ លេខទូរស័ព្ទ: ០៩៨ ៣៤៥៦ ៧៧ តទៅក្នុងកិច្ចសន្យាហៅថា **អ្នកលក់ ឬ ភាគី "ក"** ។

**និង**

ឈ្មោះ [redacted] ភេទ ស្រី ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ថ្ងៃខែឆ្នាំកំណើត ០៣-០៤-១៩៨៧ កាន់អត្តសញ្ញាណប័ណ្ណលេខ: ០៥១៥៥៨១៦៥៧ ចុះថ្ងៃទី [illegible] ខែ ០៦ ឆ្នាំ [illegible] មានអាសយដ្ឋាននៅផ្ទះលេខ ១៨៨B ភូមិ ស្វាយសាក់ ឃុំ ពោធិ៍ទី ស្រុក ស៊ីធរកណ្តាល ខេត្តព្រៃវែង លេខទូរស័ព្ទ: ០៩៣ ២២២ ២២៨ តទៅក្នុងកិច្ចសន្យាហៅថា **អ្នកទិញ ឬ ភាគី "ខ"** ។

ភាគីទាំងពីរបានឯកភាព និងយល់ព្រមប្រតិបត្តិដោយស្ម័គ្រចិត្តនូវរាល់ប្រការ និងខចែងទាំង ឡាយដូចខាងក្រោម:

**<u>ប្រការ ១:</u> កម្មវត្ថុនៃកិច្ចសន្យា**

ភាគី "ក" បានឯកភាព និងយល់ព្រមលក់ផ្តាច់ ហើយភាគី "ខ" ក៏បានឯកភាព និងយល់ព្រមទិញពីភាគី "ក" នូវរថយន្ត ដែលមានភិនភាគដូចខាងក្រោម៖

រថយន្តចង្កូតឆ្វេងម៉ាក : Rolls Royce Ghost
រថយន្តសេរីឆ្នាំ : 2019
រថយន្តពណ៌ : ខ្មៅ និងទឹកមាស
ក្នុងរថយន្តពណ៌ : ខ្មៅ
ផលិតនៅប្រទេស : អង់គ្លេស
ជារថយន្តថ្មីចេញពីរោងចក្រ Rolls-Royce
រថយន្តខាងលើនេះមានតម្លៃ USD 840,000 (ប្រាំបីសែនបួនម៉ឺនដុល្លារអាមេរិក)
(មានរូបថតភ្ជាប់ជាឧបសម្ព័ន្ធ)

**<u>ប្រការ ២:</u> ការបង់ប្រាក់ថ្លៃទិញរថយន្ត**

ភាគី "ខ" មានកាតព្វកិច្ចបង់ប្រាក់ថ្លៃទិញរថយន្ត ដែលមានទឹកប្រាក់សរុបចំនួន USD 840,000 (ប្រាំបីសែនបួនម៉ឺនដុល្លារអាមេរិក) ទៅឲ្យភាគី "ក" ដោយធ្វើការទូទាត់ជាបីដំណាក់កាលដូចតទៅ:

-**ដំណាក់កាលទី១៖** ភាគី "ខ" បានប្រគល់ប្រាក់កក់ (ទូទាត់ដៃ) ចំនួន USD 30,000 (បីម៉ឺនដុល្លារអាមេរិក) ទៅឲ្យភាគី "ក" កាលពីថ្ងៃទី១៩ ខែ ០៥ ឆ្នាំ២០១៩ ។

-<u>ដំណាក់កាលទី២:</u> ភាគី "ខ" ត្រូវទូទាត់ប្រាក់បន្ថែមចំនួន USD 222,000 (ពីរសែនពីរម៉ឺនពីរពាន់ដុល្លារអាមេរិក)ទៀត ដើម្បីបង្គ្រប់ចំនួន ៣០%(សាមសិបភាគរយ) ទៅឲ្យភាគី "ក" នៅថ្ងៃទី២១ ខែ០៥ ឆ្នាំ ២០១៩ ជាថ្ងៃចុះកិច្ចសន្យាទិញលក់នេះ ។ គិតចាប់ពីថ្ងៃចុះកិច្ចសន្យានេះទៅ រយៈពេល ៣២ ថ្ងៃ (ថ្ងៃប្រតិទិន) ភាគី "ក" ត្រូវមានរថយន្តដើម្បីប្រគល់ជូនភាគី "ខ" ។ ក្នុងរយៈពេល៣២ ថ្ងៃនេះប្រសិនបើភាគី "ក" មិនមានរថយន្តដើម្បីប្រគល់ជូនភាគី "ខ" ទេ នោះភាគី "ក"សុខចិត្តប្រគល់ប្រាក់ដែលបានទទួលទាំងអស់ជូនភាគី "ខ" វិញ និងបញ្ចប់កិច្ចសន្យានេះ ។

-<u>ដំណាក់កាលទី៣:</u> ភាគី "ខ" ត្រូវទូទាត់ប្រាក់ដែលនៅសល់ចុងក្រោយចំនួន ៧០% (ចិតសិបភាគរយ) ស្មើនឹងទឹកប្រាក់ចំនួន USD 588,000 (ប្រាំសែនប្រាំបីម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ទៅឲ្យភាគី "ក" នៅពេលដែលភាគី "ក" បានប្រគល់រថយន្តជូនភាគី "ខ" ជាកម្មសិទ្ធិ ព្រមទាំងឯកសារលិខិតស្នាមផ្សេងៗរបស់រថយន្ត ។

**<u>ប្រការ ៣:</u> សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី "ក"**

៣-១ ភាគី "ក" ត្រូវធានាថារថយន្តនៃកិច្ចសន្យាទិញ-លក់នេះ ពិតជាកម្មសិទ្ធិរបស់ខ្លួនប្រាកដមែន ហើយពុំមានជាប់ពាក់ព័ន្ធទៅនឹងការទិញ-លក់ កក់ ជួល បញ្ចាំ ប្រវាស់ ផ្ទេរកម្មសិទ្ធិ បណ្ដឹងនៅ តុលាការ ឬ ធ្វើអច្ច័យទានទៅឲ្យតតិយជនផ្សេងឡើយ ក្នុងករណីមានវិវាទកើតឡើងទៅលើ រថយន្តនេះ ភាគី "ក" ត្រូវទទួលខុសត្រូវដោះស្រាយលើរាល់ការខូចខាតទាំងនោះ ហើយរាល់ការចំណាយ ដែលទាក់ទិននឹងវិវាទនេះ ជាបន្ទុករបស់ភាគី "ក" ។

៣-២ ភាគី "ក" ត្រូវធានា និងសន្យារ៉ាប់រងរាល់ការចំណាយទៅលើបែបបទលិខិតស្នាមរដ្ឋបាល បង់ពន្ធប្រថាប់ត្រា និងការបង់ពន្ធផ្សេងៗ ។

**<u>ប្រការ ៤:</u> សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី "ខ"**

៤-១ ភាគី "ខ" ត្រូវធានា និងសន្យាទូទាត់បង់ប្រាក់ថ្លៃទិញរថយន្តនេះ ឲ្យទាន់ពេលកំណត់ និងតាមដំណាក់កាលដូចមានចែងក្នុងប្រការ ២ នៃកិច្ចសន្យានេះ ។

៤-៣ ក្នុងករណីភាគី "ខ" កែប្រែឈប់ទិញ នោះប្រាក់ដែលបានទូទាត់ ត្រូវទុកជាប្រយោជន៍របស់ភាគី "ក" ។

៤-៤ រាល់សោហ៊ុយចំណាយក្នុងការធ្វើប័ណ្ណកម្មសិទ្ធិ ( ស្លាកលេខ )រថយន្តជាបន្ទុករបស់ភាគី "ខ" ។

**<u>ប្រការ ៥:</u> ការរំលោភបំពានកិច្ចសន្យា**

ក្នុងករណីដែលភាគីណាមួយពុំបានបំពេញភាតព្វកិច្ចទៅតាមប្រការ និងខចែងទាំងឡាយនៅ ក្នុងកិច្ចសន្យានេះ នឹងត្រូវចាត់ទុកជាការរំលោភកិច្ចសន្យា ហើយភាគីនោះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសំណងការខូចខាត ដល់ភាគីរងគ្រោះ ។

**<u>ប្រការ ៦:</u> ទាយាទ និងអ្នកស្នងបន្ត**

ករណីភាគីណាមួយមិនអាចបន្តភាតព្វកិច្ចនៃកិច្ចសន្យានេះបានដោយមូលហេតុមួយចំនួន នោះទាយាទ ឬ អ្នកស្នងបន្តដែលមានសិទ្ធិតាមច្បាប់អាចបន្តសកម្មភាពនៃកិច្ចសន្យាបានរហូតដល់ចប់ ។

**<u>ប្រការ ៧:</u> ជំលោះ និងដំណោះស្រាយ**

ក្នុងករណីមានវិវាទកើតឡើងទាក់ទិននឹងកិច្ចសន្យានេះ ភាគីទាំងពីរត្រូវដោះស្រាយគ្នាដោយសន្តិវិធីក្នុងការដោះស្រាយជំលោះនេះ ។ ក្នុងករណីវិវាទពុំអាចដោះស្រាយតាមសន្តិវិធីបាន វិវាទនេះនឹងត្រូវលើកយកទៅដោះស្រាយនៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៨:** កិច្ចសន្យានេះត្រូវបានធ្វើឡើងជាភាសាខ្មែរមានចំនួន ០៤ច្បាប់ដើម ហើយច្បាប់នីមួយៗ មាន សុពលភាព និងខ្លឹមសារដូចគ្នា ។ ភាគីទាំងពីរត្រូវរក្សាទុកម្នាក់ ០១ច្បាប់ និង០២ច្បាប់រក្សាទុក នៅការិយាល័យមេធាវី ។ គូភាគីទាំងពីរក្រោយពីបាន អាន ស្តាប់ ពិនិត្យ និងពិចារណាលើខ្លឹមសារនៃកិច្ចសន្យាខាងលើនេះ ភាគីទាំងពីរបាន ឯកភាពយល់ព្រមដោយ ស្ម័គ្រចិត្តក្នុងការអនុវត្តន៍ទៅតាមប្រការ និងខចែង នៃកិច្ចសន្យានេះ ដោយផ្តិតមេ ដៃស្តាំទុកជាភស្តុតាង ។

**ស្នាមមេដៃស្តាំភាគី "ក"** | សាក្សី | **ស្នាមមេដៃស្តាំភាគី "ខ"**

[redacted] [redacted]

**បានឃើញ និងបញ្ជាក់ថា:**

ភាគីទាំងពីរពិតជាបានផ្តិតមេដៃនៅចំពោះមុខមេធាវីប្រាកដមែន។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ០៥ ឆ្នាំ២០១៩

**ហត្ថលេខា និងត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

[redacted]

[redacted]

**ឧបសម្ព័ន្ធទី ២**

crystal
condominium

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៖ PSCCLO-009-1

## <u>លិខិតជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់</u>

គម្រោងខុនដូគ្រីស្តាល់ មានការិយាល័យលេខ ១២០០ ផ្លូវលេខ ១០BT ភូមិសង្កាត់សេង ១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**<u>សូមគោរពជូន</u>**

[redacted]

អាស័យដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ 239 ផ្លូវ ម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ ( អ្នកទិញ )។

**<u>កម្មវត្ថុ៖</u>** ជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់រំលោះថ្លៃទិញលក់ខុនដូនិងស្នើសុំអោយមានការបង់ប្រាក់ឡើងវិញស្របតាមកិច្ចព្រមព្រៀងទិញលក់ខុនដូ។

**<u>យោង៖</u>** កិច្ចព្រមព្រៀងលក់-ទិញខុនដូ បន្ទប់ S3-601 ចុះថ្ងៃទី 19 ខែ សីហា ឆ្នាំ2015។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ សូមជម្រាបជូន លោក មេត្តាជ្រាបថា៖ លោក បានខកខានមិនបានបង់ប្រាក់ថ្លៃលក់-ទិញខុន ចំនួន 03 ខែ។ ហេតុដូច្នេះនាងខ្ញុំស្នើអោយ លោក មេត្តាអញ្ជើញមកធ្វើការបង់ប្រាក់ ស្មើនឹងចំនួន ដូចខាងក្រោម៖

- ប្រាក់ប្រចាំខែ វិច្ឆកា ឆ្នាំ 2016 ចំនួន 500 (ដុល្លារអាមេរិក)។
- ប្រាក់ប្រចាំខែ ធ្នូ ឆ្នាំ 2016 ចំនួន 500 (ដុល្លារអាមេរិក)។
- ប្រាក់ប្រចាំខែ មករា ឆ្នាំ 2017 ចំនួន 500 (ដុល្លារអាមេរិក)។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ នាងខ្ញុំស្នើអោយ លោក មេត្តា អញ្ជើញមកធ្វើការបង់ប្រាក់តាមចំនួនដូចបានរៀបរាប់ខាងលើដោយស្ម័គ្រចិត្ត ក្នុងអំឡុងពេល ០៧ ថ្ងៃ បន្ទាប់ពីថ្ងៃដែលចេញលិខិតនេះ។

សូម លោក មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ2017

ហត្ថលេខា និងត្រា

[redacted]

[redacted]

Activate Windows
Go to PC settings to activate Win

crystal
condominium

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៖ PSCCLO-017-1

# លិខិតជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់

គម្រោងខុនដូភីអេសគ្រីស្តាល់ មានអាសយដ្ឋានលេខ ១២០០ ផ្លូវលេខ ១០BT ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**<u>សូមគោរពជូន</u>**

[redacted]

អាសយដ្ឋានបច្ចុប្បន្ន៖ លោក សុខ គីមហាក់ សញ្ជាតិខ្មែរ អត្តសញ្ញាណប័ណ្ណលេខ 010873864 មានទីលំនៅផ្ទះលេខ239 ផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**<u>កម្មវត្ថុ៖</u>** ជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់រំលោះថ្លៃទិញលក់ខុនដូ និងស្នើសុំ អោយមានការបង់ប្រាក់ឡើងវិញស្របតាមកិច្ចព្រមព្រៀងទិញលក់ខុនដូ។

**<u>យោង៖</u>** កិច្ចព្រមព្រៀងលក់-ទិញខុនដូ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៥។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ សូមជម្រាបជូន លោក មេត្តាជ្រាបថា៖ លោក បានខកខានមិនបានបង់ប្រាក់ថ្លៃលក់-ទិញខុនដូតាំងពី ខែមិនា ២០១៨។ ហេតុដូច្នេះនាងខ្ញុំស្នើអោយ លោក មេត្តាអញ្ជើញមកធ្វើការបង់ប្រាក់ ស្មើនឹងចំនួន ដូចខាងក្រោម៖

- ប្រាក់បង់បញ្ចប់ខែ មិនា ឆ្នាំ 2018 ចំនួន 19,962 USD (ដុល្លារអាមេរិក)។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ នាងខ្ញុំស្នើអោយ លោក មេត្តា អញ្ជើញមកធ្វើការបង់ប្រាក់តាមចំនួនដូចបានរៀបរាប់ខាងលើដោយស្ម័គ្រចិត្ត ក្នុងអំឡុងពេល០៧ ថ្ងៃបន្ទាប់ពីថ្ងៃដែលចេញលិខិតនេះ។
សូម លោក មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី 11 ខែ មិថុនា ឆ្នាំ2018

ហត្ថលេខា និងត្រា

crystal
condominium

Activate Windows
Go to PC settings to activate Win

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតជូនដំណឹង

ខ្ញុំបាទមេធាវី [redacted] ជាមេធាវីនៃ **ការិយាល័យមេធាវី ត្រា រស្មីមរកត** (Tra Reaksmey Morokort Law Office ) មានការិយាល័យនៅផ្ទះលេខ០៦ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ លេខទូរស័ព្ទទំនាក់ទំនង [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ។

**ជម្រាបមក**

លោក កែវ វណ្ណា និងលោកស្រី [redacted] មានទីលំនៅបច្ចុប្បន្ននៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ។

**កម្មវត្ថុ:** សូមអញ្ជើញមកបង់ប្រាក់បំណុល ចំនួន USD 4,994 ( បួនពាន់ប្រាំបួនរយកៅសិបបួនដុល្លារអាមេរិកគត់ ) ឲ្យ
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក តាមកាលបរិច្ឆេទកំណត់នៃលិខិតជូនដំណឹងនេះ ។

**យោង:** -កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ និងចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ រវាងគ្រឹះស្ថានមីក្រូ
ហិរញ្ញវត្ថុ ប្រាសាក់ ម.ក ជាមួយនឹងលោក/លោកស្រីដែលត្រូវជា**ភាគីអ្នកខ្ចី** ។

តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំបាទជាមេធាវី** តំណាងដោយអាណត្តិឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
សូមជម្រាបមក លោក/លោកស្រី បានជ្រាបថា ៖ **លោក/លោកស្រី** បានខកខានមិនបានបង់ប្រាក់មកឲ្យ គ្រឹះស្ថានមីក្រូ
ហិរញ្ញវត្ថុ ប្រាសាក់ ម.ក ហួសរយៈពេល៣១៧ថ្ងៃហើយ គិតត្រឹមថ្ងៃទី **០៣ ខែ មីនា ឆ្នាំ ២០២១** ។ ការខកខាននេះជាចេតនា
របស់ **លោក/លោកស្រី** ដែលកំណត់ថា **លោក/លោកស្រី** មានបំណងគេចវេស និងបំពានកិច្ចសន្យា ជាហេតុនាំឲ្យមានការ
ទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ក្នុងនាមខ្ញុំ ជា**មេធាវីតំណាងដោយអាណត្តិ** ឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ខ្ញុំសូមអញ្ជើញ **លោក/លោកស្រី**
មកបង់ប្រាក់ ឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក តាមកម្មវត្ថុខាងលើ និងតាមការគណនាទឹកប្រាក់ត្រូវបង់ជាក់ស្តែង មិន
អោយលើសពី**ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២១ ជាកំហិត** ។ បើហួសរយៈពេលនៃការជូនដំណឹងនេះ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
ប្រាសាក់ ម.ក និងចាត់វិធានការតាមផ្លូវច្បាប់ ។

សូម លោក/លោកស្រី ទទួលនូវការគោរពអានពីខ្ញុំ ។

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ មីនា ឆ្នាំ២០២១

**ហត្ថលេខា និង ត្រាមេធាវី**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

[redacted]

ចម្លងជូន:

-ប្រធាននាយកប្រតិបត្តិ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
"ដើម្បីជ្រាប"

**ឧបសម្ព័ន្ធទី ៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតជូនដំណឹង</u>

លោក ផន់ វិបុល [redacted] កើតនៅឆ្នាំ១៩៧៥ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣០០៦៦២១៦ និងអ្នកស្រី ព្រហ្ម សុផ[redacted] កើតឆ្នាំ១៩៧៩ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣០០៣៦៧៣៤ មានទីលំនៅស្ថិតនៅក្នុងភូមិ២ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលជាម្ចាស់ផ្ទះ ឬភាគី ក ។

**<u>ជំរាបមក</u>**

លោកស្រី Zhang Xu[redacted]៩៦៨ សញ្ជាតិចិន មានលិខិតឆ្លងដែនលេខ: G33608615 មានអាសយដ្ឋានផ្ទះលេខ៨ ផ្លូវ២៨៥ សង្កាត់បឹងកេងកង១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតំណាងអោយក្រុមហ៊ុន ស៊ី ធី ស៊ីន [redacted]ត ឌេវ៉ឡុបមេន ជាអ្នកជួល ឬ ភាគី ខ ។

**កម្មវត្ថុ:** រំលាយកិច្ចសន្យាជួលចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ រវាងឈ្មោះ ផន់ យ៉ុត និងក្រុមហ៊ុន ស៊ីធីស៊ីន យាន រៀល អ៊ីស្តេក ។

**យោង:** - ប្រការ១៦.២ នៃកិច្ចសន្យាជួល ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៤។

-កិច្ចសន្យាជួល ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៦។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសជំរាបជូនលោកស្រី Zhang Xu[redacted]ក ស្រីបានមានការខកខានមិនបានបំពេញកាតព្វកិច្ចក្នុងនាមជាភាគី ដូចមានកំណត់ក្នុងកិច្ចសន្យាជួលចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៤ និងកិច្ចព្រមព្រៀងជួលសណ្ឋាគារចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ដែលជាហេតុនាំអោយយើងខ្ញុំបាត់បង់ផលប្រយោជន៍យ៉ាងខ្លាំង។

ហេតុដូចបានជំរាបជូនខាងលើ យើងខ្ញុំទុកពេលវេលានេះ អោយលោកស្រីមកបំពេញកាតព្វកិច្ចក្នុងនាមជាភាគីនៃកិច្ចព្រមព្រៀងខាងលើរយៈពេល ៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃយើងខ្ញុំ បានចុះនិងបិទផ្សាយលិខិតនេះជាសាធារណៈ ។

សូម លោកស្រី និងសាធារណៈ ជ្រាបជាព័ត៌មាន ។

ខេត្តព្រះសីហនុ.ថ្ងៃទី.16.ខែមករា ឆ្នាំ២០១៧

**ស្នាមមេដៃភាគី**

[redacted]

ផន់ វិបុ[redacted]   ព្រហ្ម សុ[redacted]

បញ្ជាក់ថា៖

ស្នាមមេដៃទាំងពីរនេះពិតជាស្នាមមេដៃ

របស់ឈ្មោះ ផន់ វិបុល [redacted] ព្រហ្ម

សុផ[redacted]ទ។

ថ្ងៃទី.16.ខែមករា ឆ្នាំ២០១៧

**ការិយាល័យ និមិត្តរា**

**មេធាវី**

មេធាវី.ហេង រិទ្ធី

Scanned by CamScanner

ខេមិន ការិយាល័យពិគ្រោះច្បាប់
LEGAL CONSULTING

## លិខិតជូនដំណឹងអំពីការរំលាយកិច្ចសន្យា

ខ្ញុំបាទ [redacted] ជាសហព័ទ្ធនៃការិយាល័យពិគ្រោះច្បាប់ ខេមិន មានអាសយដ្ឋាននៅ ផ្ទះលេខ ៦៣ឈ ភូមិបុរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងជាមេធាវីប្រចាំគម្រោង គីរអេសគ្រីស្តាល់ខុនដូ។ លេខទូរស័ព្ទ: ០៧៧ ៣៩ ៦៥ ៨៨, ០៩៦ ៥៥ ៥៥ ០៦៧។

**សូមគោរពជូន**

[redacted]

អាសយដ្ឋាន: ផ្ទះលេខ២៣៩ ផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ

កម្មវត្ថុ: សូមជូនដំណឹងអំពីការរំលាយកិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ដែលមានចំណែកឯកជនលេខ ៦០១ ស្ថិតនៅជាន់ទី៦ នៃអគារគីរអេសគ្រីស្តាល់ខុនដូ។

យោង: កិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន លោក មេត្តាជ្រាបថា ខ្ញុំបាទសរសេរលិខិតនេះក្នុងគោលបំណងជូនដំណឹងលោកអំពីការរំលាយកិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ គិតចាប់ពីថ្ងៃចេញលិខិតនេះតទៅ។ ការរំលាយកិច្ចសន្យានេះផ្អែកតាមមូលដ្ឋាន អង្គហេតុ និង ច្បាប់ដូចខាងក្រោម:

### ក. មូលដ្ឋានអង្គហេតុ

១) កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ លោក និងគម្រោងគីរអេសគ្រីស្តាល់ បានចុះកិច្ចព្រមព្រៀងទិញលក់ខុនដូ ទៅលើចំណែកឯកជនលេខ ៦០១ ជាន់ទី៦ ក្នុងតម្លៃ ៤៩,៩៦២ ដុល្លារអាមេរិក (សែសិបប្រាំបួនពាន់ ប្រាំបួនរយ ហុកសិបពីរ ដុល្លារអាមេរិក) ដោយធ្វើការបង់រំលស់ទៅតាមតារាងរំលស់ដែលមានចែងក្នុងកិច្ចព្រមព្រៀង។

Activate W
Go to PC set

(២) លោកបានធ្វើការបង់ប្រាក់សរុបជូនគម្រោងភីរេសត្រីស្កាល់ ចំនួន ២០,៤៦២ ដុល្លារអាមេរិក (ម្ភៃពាន់ បួនរយ ហុកសិបពីរ ដុល្លារអាមេរិក) និងនៅសល់ប្រាក់ចំនួន ១៩,៩៦២ ដុល្លារអាមេរិក (ដប់ប្រាំបួនពាន់ ប្រាំបួនរយ ហុកសិបពីរ ដុល្លារអាមេរិក) ដែលមិនទាន់បានបង់ ហើយការយឺតយ៉ាវនេះត្រូវបានអូសបន្លាយតិចចាប់តាំងពី ខែកុម្ភៈ ឆ្នាំ២០១៨ មក។

(៣) គម្រោងភីរេសត្រីស្កាល់ បានជូនដំណឹងជាលាយលក្ខណ៍អក្សរមកលោក នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ អោយលោកមកធ្វើការទូទាត់ប្រាក់តាមកិច្ចព្រមព្រៀង តែរហូតមកដល់បច្ចុប្បន្ន លោកនៅតែពុំបានធ្វើការបង់ប្រាក់។

(៤) ការយឺតយ៉ាវនេះធ្វើអោយគម្រោងភីរេសត្រីស្កាល់ ទទួលរងការខូចខាតដោយសារការជាប់គាំតាមរយៈការមិនបង់ប្រាក់តាមកិច្ចព្រមព្រៀង។

## ខ. មូលដ្ឋានច្បាប់

### ខ១. ការបំពានកិច្ចព្រមព្រៀង

យោងទៅលើអង្គហេតុខាងលើ ខ្ញុំបាទអាចសន្និដ្ឋានបានថា លោកបានបំពានកិច្ចព្រមព្រៀងយ៉ាងធ្ងន់ធ្ងរ ដែលកិច្ចព្រមព្រៀងត្រូវចាត់ទុកថាជាច្បាប់របស់គូភាគីនៃកិច្ចព្រមព្រៀងត្រូវអនុវត្តតាម។ ការបំពានកិច្ចព្រមព្រៀងយ៉ាងធ្ងន់ធ្ងរត្រូវបានកំណត់ដោយ ប្រការ ១១ និង ប្រការ ១២.២ នៃកិច្ចព្រមព្រៀងទិញលក់ខុនដូចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ដែលមានខ្លឹមសារដូចខាងក្រោមៈ

**ប្រការ១១៖**

*"ព្រឹត្តិការណ៍ជាអាទិ៍ដូចខាងក្រោមនេះត្រូវចាត់ទុកថាជាការខកខាន ការបំពាន ការមិនអនុវត្តតាម ខ និង លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ៖*

*ក. ការយឺតយ៉ាវមិនបង់ប្រាក់ថ្លៃទិញស្របទៅតាមផែនការបង់រំលោះដែលមានចែងក្នុងឧបសម្ព័ន្ធ ក"*

**ប្រការ ១២.២៖**

*"បើអ្នកទិញមិនបានបង់ប្រាក់ដែលយឺតយ៉ាវក្នុងរយៈពេល ១៥ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌខាងលើទេ អ្នកអភិវឌ្ឍន៍អចលនវត្ថុអាចលុបចោលកិច្ចព្រមព្រៀងហើយតាមរយៈកិច្ចព្រមព្រៀងនេះ អ្នកទិញយល់ព្រមអោយអ្នកអភិវឌ្ឍន៍លុបចោលកិច្ចព្រមព្រៀង ហើយតាមកិច្ចព្រមព្រៀងនេះអ្នកទិញយល់ព្រមអោយអ្នកអភិវឌ្ឍន៍រឹបអូសប្រាក់ដែលបានបង់រួចហើយទាំងអស់ ហើយអ្នកអភិវឌ្ឍន៍អចលនវត្ថុមានសិទ្ធិលក់ចំណែកទ្រព្យឯកជននោះទៅអោយអ្នកផ្សេង។"*


Activate Windows
Go to PC settings to a

## ៦២. សិទ្ធិក្នុងការរំលាយកិច្ចព្រមព្រៀងដែលកំណត់ដោយក្រមរដ្ឋប្បវេណី

មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់និយមន័យនៃការបំពានកិច្ចសន្យាដែរ។

### មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា៖

*"១. ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោម៖*

*ក. ភាគីម្ខាងបានដាស់តឿនភាគីម្ខាងដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ដោយកំណត់រយៈពេលសមរម្យដើម្បីអោយអនុវត្តកាតព្វកិច្ចហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុង រយៈពេល។*

*ខ. ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះបើភាគីមិនអនុវត្តកាតព្វកិច្ចតាមកាលកំណត់។*

*គ. ភាគីមិនអាចអនុវត្តករណីកិច្ចផ្តល់ការការពារចម្បងរបស់ខ្លួនបានទេ។*

*ឃ. ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើអោយបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាពេលអនាគតបាន។"*

បើផ្អែកលើមាត្រា ៤០៨ ត្រង់ចំនុច១.ក និង ឃ ក៏ឆ្លើយតបទៅនឹងស្ថានភាពរបស់លោកនាពេលបច្ចុប្បន្នព្រោះថា លោកមិនបានធ្វើការបង់ប្រាក់ជូនគម្រោងភីអេសគ្រីស្តាល់ ទោះបីជាគម្រោងភីអេសគ្រីស្តាល់បានព្យាយាមជូនដំណឹងអោយមកធ្វើការបង់ប្រាក់ក៏ដោយ។ កត្តានេះដែលនេះធ្វើអោយគម្រោងភីអេសគ្រីស្តាល់បាត់បង់ទំនុកចិត្ត ហើយមិនអាចជឿជាក់ថាលោកនឹងអនុវត្តកាតព្វកិច្ចនាពេលអនាគតបាន។

ចំពោះនីតិវិធីនៃការរំលាយកិច្ចសន្យា ក៏បានកំណត់ផងដែរក្នុង មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណីដែលបើកសិទ្ធិអោយអ្នកមានសិទ្ធិរំលាយធ្វើការរំលាយដោយមិនចាំបាច់ទៅតុលាការ។

មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា៖

*"១. ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន"*

## គ. សន្និដ្ឋាន

ផ្អែកតាមការរៀបរាប់ខាងលើ គម្រោងភីរេសត្រីស្តាល់ មានសិទ្ធិគ្រប់គ្រាន់ក្នុងការរំលាយកិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ គិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ហើយគម្រោងភីរេសត្រីស្តាល់ សម្រេចធ្វើការរឹបអូសយកប្រាក់ដែលលោកបានបង់រួចចំនួន ២០,៤៦២ ដុល្លារអាមេរិក (ម្ភៃពាន់ បួនរយ ហុកសិបពីរ ដុល្លារអាមេរិក) ស្របតាមប្រការ ១២.២ និងសម្រេចធ្វើការដាក់លក់ចំណែកឯកជនលេខ ៦០១ ជូនអ្នកដទៃ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា លោក នឹងយល់អំពីហេតុផលខាងលើ ហើយសូមលោកមេត្តាយល់ថា នេះគឺជាជម្រើសតែមួយគត់សម្រាប់ស្ថានភាពបច្ចុប្បន្នដែលគម្រោងភីរេសត្រីស្តាល់ ត្រូវធ្វើ។

ក្នុងករណីដែល លោក មានចម្ងល់ពាក់ព័ន្ធ នឹងលិខិត ជូនដំណឹងនេះ សូមលោក ធ្វើការទាក់ទងមកខ្ញុំបាទតាមរយៈទូរស័ព្ទលេខ ០៧៧ ៣៥ ៦៥ ៨៨, ០៩៦ ៥៥ ៥៥ ០៦៧។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

មេធាវីទទួលអំណាចដោយអាណត្តិ

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

[redacted]



Activate Windows
Go to PC settings

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>លិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាលក់-ទិញដី</u>

លោក [redacted] កើតឆ្នាំ១៩៤៧ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០១០៩៥១៦៧៦ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ១០ ផ្លូវបេតុង ភូមិពោធិ៍លំ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាអ្នកលក់ដី និងជា **ភាគី "ក"**។

**<u>សូមជម្រាបមក</u>**

លោក [redacted] កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០១១៣២៧៣១៩ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ និងលោក [redacted] កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០១០៤១៤៣៥០(០១) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ៥៩ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាអ្នកទិញដី និងជា **ភាគី "ខ"** ។

**<u>កម្មវត្ថុ៖</u>** ជូនដំណឹងស្តីពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ,កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០,កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមូលហេតុ **ភាគី "ខ"** បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

**<u>យោង៖</u>**
- កិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០។
- កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០។
- កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។
- កិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក [redacted] និងលោក [redacted] ជ្រាបថា៖ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្ញុំ ហើយនិងលោក បានព្រមព្រៀងគ្នាជាលើកចុងក្រោយនៅចំពោះមុខមេធាវីទាំងសងខាង ដោយកំណត់យកថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ ជាលើកចុងក្រោយនៃការប្រគល់-ទទួលប្រាក់ដំណាក់កាលទី៤ ដែលមានទឹកប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។ ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែពុំឃើញលោកមកអនុវត្តកាតព្វកិច្ចបង់ប្រាក់មកឱ្យខ្ញុំឡើយ យោងតាមកិច្ចសន្យាទិញ-លក់ដីខាងលើ ត្រង់ប្រការ៥ ចំណុច ៥.១ ចំណុច៥.៣ និងយោងតាមកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់ចំណុចទី៣ គឺលោកបាន<u>**បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ**</u> និងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្ញុំយ៉ាងខ្លាំងទៀតផង។ ហេតុដូច្នេះខ្ញុំសម្រេចចិត្តបង្ហាញឆន្ទៈរំលាយកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០, កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០, កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលធ្វើឡើងរវាងលោក និងខ្ញុំ ចាប់ពីពេលនេះតទៅ។ ចំណែកប្រាក់ដែលលោកបានទូទាត់ឱ្យខ្ញុំទាំងអស់កន្លងមក ត្រូវក្លាយជាកម្មសិទ្ធិរបស់ខ្ញុំ ដោយលោកគ្មានសិទ្ធិទាមទារមកវិញឡើយ ហើយខ្ញុំនឹងធ្វើការចូលគ្រប់គ្រង ចាត់ចែងអចលនវត្ថុខាងលើជាម្ចាស់កម្មសិទ្ធិវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកជា**ភាគី "ខ"** ជ្រាបជាព័ត៌មាន។

សូមលោកជា **ភាគី "ខ"** ទទួលនូវការរាប់អានអំពីខ្ញុំ។

ថ្ងៃ[illegible]ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០
ស្នាមមេដៃស្តាំ

[redacted]

**បានឃើញ**
ថ្ងៃ[illegible]ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០
ហត្ថលេខា និងត្រា

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

[redacted]

**ឧបសម្ព័ន្ធទី ៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០១៨

សាលាដំបូងរាជធានីភ្នំពេញ
បង់ពន្ធរួច
បង្កាន់ដៃលេខ ០០៤៤៨៤១
ចុះថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ២០១៨

## ពាក្យបណ្តឹង

**ដើមចោទឈ្មោះ** [redacted] ភេទស្រី ឆ្នាំកំណើត:១៩៩២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:០២០៨៩១៨៦៦ ដែលមានទីលំនៅបច្ចុប្បន្ន: ផ្ទះលេខ៨៧ ភូមិព្រៃពើហា សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។ លេខទូរស័ព្ទទំនាក់ទំនង: ០១២២៣២៧៩២/០៩៦៦៦៦១១១៧។

**អ្នកតំណាងដោយអាណត្តិ:** លោក [redacted] អត្តលេខ១៨៦៧T ជាមេធាវីនៃក្រុមហ៊ុនមេធាវី [redacted] LAW FIRM) និងជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យផ្ទះលេខ១៧CE0 ផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ (**ទីកន្លែងបញ្ជូន**)។ ទូរស័ព្ទទំនាក់ទំនង: (០១២/០១៥) ៨៨ ៥៥ ១២។

**ចុងចម្លើយឈ្មោះ:** [redacted] និង [redacted] តំណាងឈ្មោះ: [redacted] ភេទ ប្រុស ដែលមានទីតាំងការិយាល័យ: ផ្ទះលេខ៣៨ ផ្លូវ១ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ លេខទូរស័ព្ទទំនាក់ទំនង: ០៧០៦៥៥ ៨៥៥/០១១ ៧៥១ ០២៨

**តម្លៃកម្មវត្ថុនៃបណ្តឹង: ៤៦៧៥$** (បួនពាន់ប្រាំមួយរយចិតសិបប្រាំដុល្លារអាមេរិក) ។

**<u>សូមគោរពជូន</u>**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** សំណើសុំប្តឹងទាមទារឲ្យផ្តល់ការកាលិក។

តបតាមកម្មវត្ថុខាងលើ [redacted] សូមដាក់ពាក្យបណ្តឹងជាលាយល័ក្ខអក្សរដូចតទៅ៖

**១). ខ្លឹមសារនៃសាលក្រមទាមទារឲ្យតុលាការចេញ៖**

- បង្គាប់ឲ្យចុងចម្លើយ សងប្រាក់ចំនួន ៤៦៧៥$ (បួនពាន់ប្រាំមួយរយចិតសិបប្រាំដុល្លារអាមេរិក) នៃ ទិញដីឡូតិ៍លេខ៤០៥ ស្ថិតនៅភូមិសេរីសម្បត្តិ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ។
- សងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដែលភាគីចុងចម្លើយបានបំពានកិច្ចសន្យាលក់-ទិញដីឡូតិ៍។
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

**២). អង្គហេតុចាំបាច់បញ្ជាក់ពីការទាមទារ៖**

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦ នាងខ្ញុំបានទិញដីឡូតិ៍មួយកន្លែងលេខ៤០៥ ពីឈ្មោះ: [redacted] ង សេង ដាលីន តំណាងដោយឈ្មោះ: [redacted] មានទទឹង១០ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ ទំហំសរុប២០០ម៉ែ ការ៉េ (មួយរយម៉ែត្រការ៉េ) ក្នុងមួយឡូតិ៍ មានតម្លៃសរុប៨០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក) មានទីតាំងស្ថិតនៅភូមិ សម្បត្តិ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់៖ ខាងកើតទល់នឹងដីឡូតិ៍លេខ១២១ ៖

Activate Windows
Go to PC settings to activate

Scanned by CamScanner

លិចទល់នឹងផ្លូវ១០ម៉ែត្រ ខាងត្បូងទល់នឹងដីឡូត៍លេខ៤០៤ និងខាងជើងទល់នឹងដីឡូត៍លេខ៤០៦ តាមរយៈកិច្ចសន្យាទិញ-លក់ដីឡូត៍ លេខ០៥៣ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦ ដែលរៀបចំដោយភាគីលក់ដីឡូត៍។ ភាគីអ្នកលក់ [redacted] និង [redacted] តំណាងដោយឈ្មោះ [redacted] បានបំពានកិច្ចសន្យាទិញ-លក់ដីឡូត៍នេះ នៅត្រង់ចំណុចប្រការ៨នៃកិច្ចសន្យាទិញ-លក់ដីឡូត៍ខាងលើ។

**៣). មូលហេតុនៃអង្គហេតុចាំបាច់បញ្ជាក់ពីការទាមទារ៖**

នៅពេលព្រមព្រៀងគ្នា នាងខ្ញុំបានបង់ប្រាក់កក់ចំនួន៥០០$ (ប្រាំរយដុល្លារអាមេរិក) នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ហើយបន្ទាប់មកក៏បានធ្វើកិច្ចសន្យាទិញ-លក់ដីឡូត៍នៅ**ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦**។ នាងខ្ញុំក៏បានចាប់ផ្តើមបង់ប្រាក់ទិញដីឡូត៍ខាងលើចាប់ពី **ខែមិថុនា ឆ្នាំ២០១៦** រហូតមកដល់ **ខែមេសា ឆ្នាំ២០១៨** ដែលមានទឹកប្រាក់សរុបចំនួន**៤៦៧៥$**។ តែអ្វីដែលធ្វើឲ្យនាងខ្ញុំខកចិត្តយ៉ាងខ្លាំងនោះ គឺនៅពេលដែលនាងខ្ញុំបានសួររកទីតាំងដីឡូត៍លេខ៤០៥ ភាគីអ្នកលក់ដីឡូត៍មិនបានផ្តល់ព័ត៌មានពិតប្រាកដដល់នាងខ្ញុំឡើយ ចាប់តាំងពីនាងខ្ញុំបានបង់ប្រាក់ទិញដីឡូត៍នេះបានរយៈពេលមួយឆ្នាំ។ នៅ**ខែមីនា ឆ្នាំ២០១៨** បុគ្គលិកលក់ដីឡូត៍ម្នាក់បាននាំនាងខ្ញុំទៅមើលដីដែលនាងខ្ញុំកំពុងទិញនេះ តែមិនបានរកដីឡូត៍លេខ៤០៥នេះឃើញឡើយ។ នាងខ្ញុំបានសួរអំពីមូលហេតុនេះ បុគ្គលិកលក់ដីឡូត៍នោះបានឆ្លើយថា៖ **ខ្ញុំរកមិនឃើញដែរ** ។ នៅ**ខែឧសភា ឆ្នាំ២០១៨** នាងខ្ញុំបានប្រាប់ទៅភាគីអ្នកលក់ថា នាងខ្ញុំសម្រេចចិត្តលប់ចោលកិច្ចសន្យាទិញ-លក់ដីឡូត៍ និងឈប់បង់ប្រាក់ ដោយទាមទារប្រាក់ចំនួន**៤៦៧៥$** (បួនពាន់ប្រាំមួយរយចិតសិបប្រាំដុល្លារអាមេរិក) មកវិញពីភាគីអ្នកលក់ ទើបមានតំណាងភាគីអ្នកលក់បានទូរស័ព្ទមកប្រាប់នាងខ្ញុំថា ឲ្យនាងខ្ញុំទៅមើលដីនៅកន្លែងផ្សេងវិញ ព្រោះមានការដោះដូរដីឡូត៍។

**៤). មូលហេតុនៃអង្គហេតុបន្ទាប់បន្សំបញ្ជាក់ពីការទាមទារ៖**

នៅក្នុងអំឡុងខែឧសភា និង ខែមិថុនា ឆ្នាំ២០១៨ នាងខ្ញុំបានខំព្យាយាមជួបចរចាជាមួយភាគីលក់ដីឡូត៍ដែលមានភាគីឈ្មោះ **ស៊ឹម តាក** ជាតំណាងឲ្យភាគីលក់ដីឡូត៍ ដើម្បីប្រាប់ពួកគេអំពីមូលហេតុដែលនាងខ្ញុំលែងទទួលយកបានពីការភូតកុហករបស់ភាគីលក់ដីឡូត៍ និងទាមទារមកវិញ នូវចំនួនប្រាក់ខាងលើ ដែលនាងខ្ញុំបានបង់កន្លងមក ពោលគឺនាងខ្ញុំលែងចង់ទិញដីរបស់ភាគីលក់ដីឡូត៍នេះទៀតឡើយ។ តែភាគីលក់ដីឡូត៍ មិនបានឆ្លើយតបមកនាងខ្ញុំយ៉ាងណានោះឡើយរហូតមកដល់ពេលនេះ។

ហេតុដូច្នេះ សូមលោកប្រធានសាលាដំបូងរាជធានីភ្នំពេញ មេត្តាបង្គាប់ឲ្យភាគីចុងចម្លើយសងប្រាក់របស់នាងខ្ញុំមកវិញ ព្រមទាំងបង្គាប់ឲ្យសងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដូចមានចែងក្នុងខ្លឹមសារនៃសាលក្រមទាមទារឲ្យតុលាការចេញខាងលើ អោយនាងខ្ញុំដោយយុត្តិធម៌។

សូមលោកប្រធានសាលាដំបូងរាជធានីភ្នំពេញ ទទួលនូវក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃ.សុក្រ.៤រោច......ខែ.បឋមាសាឍ..ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

......ភ្នំពេញ..........ថ្ងៃទី.០៦......ខែកក្កដា.......ឆ្នាំ២០១៨

ស្នាមមេដៃស្តាំអ្នកប្តឹង



[redacted]

**ឯកសារភ្ជាប់ជូន៖**

- កិច្ចសន្យាទិញ-លក់ដីឡូត៍ ០១ច្បាប់។
- សក្ខីប័ត្របង់ប្រាក់ចំនួនចំនួន ២២សន្លឹក។
- តារាងសងប្រាក់ចំនួន០១ច្បាប់។

Activate Windows
Go to PC settings to activate

Scanned by CamScanner